ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



## មជ្ឈមណ្ឌល សន្តិភាពអន្លង់វែង

- ពិភពលោកអន្លង់វែង
- ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម
- កម្មសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស ឆ្នាំ២០២៣

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

លេខពិសេស ឆ្នាំ២០២៣

## មាតិកា

### ផ្នែកសំបុត្រ


◆ ពិភពលោកអន្លង់វែង........................១
◆ តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរ......... ៥


### ផ្នែកឯកសារ


◆ អ៊ុល ហាំ៖ កងស៊ើបការណ៍សម្ងាត់ ...... ១១


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ទួន ហម ៖ ខ្ញុំឃើញឈ្លបខ្មែរក្រហម..... ១៣
◆ ឯក គាប់ ៖ យោធា ........................ ១៥
◆ ញ៉ាណ ញ៉ក់ ៖ កងចល័ត...................១៧
◆ ម៉ិល ឈួន៖ នីរសារ ......................១៩
◆ គុន ឈិន៖ អតីតយោធា ..................២១
◆ វ៉ៃ ឈុន៖ សមាជិកគណៈស្រុកចំការលើ.. ២៣
◆ យុល អុន៖ ប្រជាជន .................... ២៥
◆ ម៉ែត សំអុល ៖ កម្មករលីសែងនៅ ...... ២៧
◆ ទួន សន៖ ប្រធានក្រុមនៅឃ្លាំងដាក់... ២៨
◆ ទេព ជីន៖ កម្មករឃ្លាំងរដ្ឋ............... ២៩
◆ តេ រ៉ិប ៖ អតីតគណៈស្រុកកោះញែក .... ៣០
◆ ថាប់ ឈាន៖ នីរសារ ......................៣១
◆ លៀន ចន្ទថ្លៃ៖ អតីតពេទ្យ .............. ៣២
◆ ហ៊ាន សែន៖ មិនដឹងថាតស៊ូ..............៣៣


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


◆ វេទិកាសហគមន៍នៅក្នុងភូមិទួលប្រាសាទ.. ៣៤
◆ ពិព័រណ៍ស្តីអំពីអំពើប្រល័យពូជសាសន៍ .. ៣៦
◆ ដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង សិទ្ធិមនុស្ស»មកកាន់តំបន់.......... ៤០
◆ វេទិកាថ្នាក់រៀន ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ..... ៤៣




កងកម្លាំងខ្មែរក្រហមចុងក្រោយដែលនៅសេសសល់នៅតំបន់អន្លង់វែងធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាផ្លូវការនៅអំឡុងខែកុម្ភៈ ឆ្នាំ១៩៩៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


◆ វេទិកាថ្នាក់រៀនស្តីពី ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិតេយ្យ (១៩៧៥-១៩៧៩) ....៤៥
◆ «វេទិកាលើកកម្ពស់សិទ្ធិស្ត្រី» ........... ៤៨
◆ វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) .. ៥១
◆ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ........៥៤
◆ សហប្រធានវេទិកាប្រវត្តិសាស្ត្រអន្តការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត... ៥៩


### ផ្នែកស្រាវជ្រាវរកគ្រួសារ


◆ ជា ហង់ ៖ កូន និង យាយរបស់ខ្ញុំ......... ៦១



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, ស្លួត វិចិត្រ, ហ៊ាន ពិសី, មេក វិន, សោម ប៊ុនថន និង លី សុខឃាង
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ពិភពលោកអន្លង់វែង

ឆាំង យុ




១ សម្តេចពិជ័យ សេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ២ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេស សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ ៣ លោក ហោ ជិនវិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង និង ៤ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅលើខ្នងភ្នំដងរែក ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លាតសន្ធឹងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ, អន្លង់វែងផ្តល់នូវឱកាស និងបទពិសោធន៍ក្នុងការឈ្វេងយល់អំពីប្រវត្តិសាស្ត្រជាលក្ខណៈបុគ្គល តាមរយៈការសន្ទនាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការធ្វើទស្សនកិច្ចទៅកាន់តំបន់ប្រវត្តិសាស្ត្រចំណាស់នានា និងការឈ្វេងយល់អំពីតំបន់នេះ ដែលស្ថិតនៅក្នុងភាពដាច់សង្វែងនៅឡើយ។

ប្រសិនបើប្រៀបធៀបជាមួយនឹងរាជធានីភ្នំពេញ ឬគោលដៅទេសចរណ៍ដ៏ចម្បងនៅក្នុងខេត្តសៀមរាប ចំណុចពិសេសរបស់អន្លង់វែង ដែលបម្រើដល់ការសិក្សាអំពីប្រវត្តិសាស្ត្រ បរិស្ថានឬវប្បធម៌ មិនស្តែងចេញមកភ្លាមៗទេ ក៏ប៉ុន្តែទីតាំងរបស់អន្លង់វែងក៏ដូចជាប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនៃស្រុកនេះ គឺជាធនធានដ៏វិសេសវិសាលមួយ។ អន្លង់វែងស្ថិតនៅក្នុងរយៈចម្ងាយកៀកទៅនឹងប្រាង្គប្រាសាទមួយចំនួន ដែលមានភាពលេចធ្លោ និងជាកេរមរតក

លេខពិសេស ឆ្នាំ២០២៣

នៃអាណាចក្រអង្គរពីបុរាណកាល ព្រមទាំងជាតំបន់បេតិកភណ្ឌវប្បធម៌ពិភពលោកទៀតផង។ អន្លង់វែងស្ថិតនៅរយៈចម្ងាយប្រមាណ ១ម៉ោងនិង៣០នាទីតែប៉ុណ្ណោះ ប្រសិនបើធ្វើដំណើរតាមរថយន្តពីខេត្តសៀមរាប និងតំបន់ប្រាសាទព្រះវិហារដែលជាបេតិកភណ្ឌពិភពលោក និង ២ម៉ោងនិង៣០នាទីទៅ៣ម៉ោង ពីប្រាសាទកោះកេរ ដែលស្ថិតនៅជាប់ពីគេ និងជាអតីតរាជធានីនៃអាណាចក្រខ្មែរ។

ក្រៅពីប្រវត្តិសាស្ត្រពីបុរាណកាល តំបន់អន្លង់វែង ត្រូវបានស្គាល់ជាទូទៅថា ជាតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម និងជាចំណុចផ្តោតមួយដ៏សំខាន់នៃគោលនយោបាយ ឈ្នះ-ឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាទីតាំងតស៊ូ តំបន់នេះត្រូវបានធ្វើប្រតិបត្តិការជាទីស្នាក់ការកណ្តាលរបស់មេដឹកនាំដែលមានឈ្មោះអសោចមួយចំនួនរបស់ចលនាតស៊ូខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត។ តំបន់នេះ ប្រមូលផ្តុំទៅដោយកេរដំណែលជាច្រើនបន្សល់ទុកពីចលនាតស៊ូ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ក្នុងនោះរួមមានប្រវត្តិសាស្ត្រនានាទាក់ទងនឹងស្តេចគ្រាញ់នៅមូលដ្ឋានម្នាក់ឈ្មោះ តាម៉ុក។ ដោយសារតែអន្លង់វែងមានសារសំខាន់ក្រៃលែងចំពោះភាពស៊ិតស្វាញនៃចលនាតស៊ូរបស់ខ្មែរក្រហម តំបន់នេះគឺជាទីតាំងនិមិត្តរូបតំណាងឲ្យជ័យជម្នះចុងក្រោយនៃគោលនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា។

គោលនយោបាយ ឈ្នះ-ឈ្នះ គឺជាយុទ្ធវិធីនយោបាយ ជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការបំបែកកងទ័ពខ្មែរក្រហម តាមរយៈកត្តាជំរុញទឹកចិត្តផ្នែកសេដ្ឋកិច្ច និងនយោបាយដែលរុញច្រានទៅកាន់សន្តិភាព និងសមាហរណកម្មសាជាថ្មីទៅក្នុងសង្គមកម្ពុជា។ គោលនយោបាយ ឈ្នះ-ឈ្នះ តែងតែពិចារណាលើបរិបទនយោបាយរបស់ប្រទេសកម្ពុជា ក៏ប៉ុន្តែក្នុងកាលៈទេសៈផ្សេងៗគ្នា គោលនយោបាយនេះតំណាងឲ្យកត្តាដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រសន្តិសុខក្នុង




ប្លង់គោលស្រុកអន្លង់វែង ក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។
(ដេវ៉ា កាង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

តំបន់អាស៊ីអាគ្នេយ៍។ គោលនយោបាយ ឈ្នះ-ឈ្នះ ត្រួសត្រាយផ្លូវដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការតបតជាមួយនឹងសម្ពាធពីប្រជាជាតិអាស៊ាន ជាពិសេស ពីប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី និងប្រទេសថៃមកលើរដ្ឋាភិបាលនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ ក្នុងកាលៈទេសៈជាច្រើនគោលនយោបាយនេះ មិនទាន់ត្រូវបានធ្វើការសិក្សាស្រាវជ្រាវឲ្យបានសមស្រប ឬមិនត្រូវបានទទួលសាទរឲ្យបានសក្តិសមនៅឡើយទេ។ ការសិក្សាស៊ីជម្រៅមួយអំពីគោលនយោបាយ ឈ្នះ-ឈ្នះ តាមរយៈប្រវត្តិសាស្ត្រអន្លង់វែង




ាក់កាលទី១ និងដំណាក់កាលទី២
និងមជ្ឈមណ្ឌលឯកសារកម្ពុជា

PLAN PHASE 1 AND PHASE 2
MENTATION CENTER OF CAMBODIA



របងនៅតាមច្រាកភ្នំសាងសង់ដើម្បីការពារសុវត្ថិភាពភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិដែលអញ្ជើញមកខ្នងភ្នំដងរែកនៃស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ការសាងសង់របងនេះនឹងបង្កើតជាផ្លូវថ្មើរជើងថ្មីសម្រាប់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ របងនេះរចនាឡើងដោយ ដេវីត កាន ដែលបង្កើតនូវផ្ទាំងទស្សនីយភាពប្លែកដល់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិអាចសម្លឹងមើលឃើញផ្ទាំងទស្សនីយភាពនៃស្រុកអន្លង់វែងទាំងមូល។ (ដេវីត កាន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អាចនឹងផ្តល់ជាគោលគំនិត មេរៀនជាបទពិសោធន៍ និងការអនុវត្តជាក់ស្តែងដ៏ប្រសើរបំផុត ដល់ប្រទេសដទៃទៀត ជាពិសេស ថាតើគោលនយោបាយនេះមានប្រសិទ្ធភាពយ៉ាងដូចម្តេចក្នុងការបញ្ចប់ជម្លោះផ្នែកនយោបាយ និងផ្នែកយោធា នៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ។

ដោយសារតែតំបន់អន្លង់វែង គឺជាទីស្នាក់ការកណ្តាលដ៏សំខាន់នៃចលនាតស៊ូរបស់ខ្មែរក្រហម នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ តំបន់នេះក៏ជាទីតាំងពិសេសមួយនៃប្រវត្តិសាស្ត្រពិភពលោក ដោយតំណាងឲ្យចំណុចប្រសព្វនៃមនោគមវិជ្ជារបស់សហរដ្ឋអាមេរិក សហភាពសូវៀត ចិន និងវៀតណាម ព្រមទាំងកងកម្លាំង និងរបៀបវារៈនយោបាយជាច្រើនប្រភេទ ដែលរួមផ្សំបង្កើតបានជាតំបន់អាស៊ីអាគ្នេយ៍ក្នុងសតវត្សរ៍ទី២០។ អន្លង់វែង មិនត្រឹមតែរំលេចនូវជម្លោះរវាងនយោបាយ ទាក់ទងនឹងភូមិសាស្ត្រនៃក្រុមបក្សសម្ព័ន្ធតែប៉ុណ្ណោះទេ ក៏ប៉ុន្តែតំបន់នេះបង្ហាញអំពីជម្លោះរវាងកងយោធា និងសំណល់ប្រវត្តិសាស្ត្រដែលកំណត់នូវបច្ចុប្បន្នកាលរបស់យើង។ តំបន់អន្លង់វែងជាសម្បុកនៃសំណល់សង្គ្រាម និងកេរដំណែលនៃយុគសម័យដែលហាក់ដូចជាត្រូវបានបំភ្លេចចោល។

ជាចុងក្រោយ អន្លង់វែង គឺជាតំបន់ប្រកបទៅដោយសម្រស់ស្រស់ត្រកាល។ ដោយរួមផ្សំនូវទឹកធ្លាក់ ទន្លេ ព្រៃព្រឹក្សា និងភ្នំដងរែក អន្លង់វែងផ្តល់ជាទីតាំងសម្រាប់ការដើរភ្នំ និងដំណើរផ្សងព្រេងនានាទៅកាន់តំបន់ដែលស្ថិតនៅជាប់សង្វែងពីទិសដៅទេសចរណ៍ដ៏ពេញនិយមផ្សេងៗនៃខេត្តសៀមរាប។

ភ្នំដងរែក ផ្តល់នូវតម្លៃជាសកលមិនអាចកាត់ថ្លៃបានតាមរយៈគោលគំនិតនៃប្រវត្តិសាស្ត្របរិស្ថាន និងសម្រស់ធម្មជាតិ។ នាពេលបច្ចុប្បន្ន ទោះបីជាជួរភ្នំដងរែកមានតួនាទីជាព្រំប្រទល់ធម្មជាតិ ខណ្ឌចែកប្រទេសកម្ពុជា និងប្រទេសថៃយ៉ាងណាក៏ដោយ ជួរភ្នំនេះធ្លាប់ជាទីសម្រាកលំហែមួយក្នុងចំណោមទីតាំងដទៃទៀត ស្ថិតនៅប៉ែកឧត្តរក្នុងអាណាចក្រខ្មែរ។ ជួរភ្នំដងរែកពោរពេញទៅដោយសំណល់បុរាណវិទ្យា

លេខពិសេស ឆ្នាំ២០២៣



ចេញពីទស្សនទាននៃសាលាបុណ្យដែលមានដំបូលប្រក់ផ្ទរ ប៉ុល ពត ត្រូវបានរចនាឡើងដើមដោយ ដេវ៉ា កាង ដើម្បីថែរក្សា និងអភិរក្សសម្រាប់សិស្សានុសិស្សបានមកទស្សកិច្ច និងសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម។ (ដេវ៉ា កាង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាច្រើនរួមបញ្ចូល ទាំងចម្លាក់ឆ្លាក់ជាប់នឹងថ្ម ជ្រលងគាស់យកថ្មនាបុរាណកាល ក៏ដូចជា ទីសក្ការតំណាងឲ្យព្រលឹងដូនតា និងប្រាង្គប្រាសាទនានា។ ភ្នំដងរែក អាចចាត់ចូលជាទីតាំងបេតិកភណ្ឌវប្បធម៌ពិភពលោក ក្រោមមូលហេតុជាច្រើនទៀត។

ប្រវត្តិសាស្ត្រអាចនឹងត្រូវលើកយកមកបង្ហាញក្នុងសណ្ឋានជាច្រើន ដោយសារមូលហេតុនេះហើយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានខិតខំប្រឹងប្រែងក្នុងការបង្កើតជាដំណើរទស្សនកិច្ចទៅកាន់តំបន់អន្លង់វែង។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលផ្តួចផ្តើមបង្កើតឲ្យមានដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឲ្យមានមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលរួមមានបន្ទប់អំណាន និងថ្នាក់រៀន នៅក្នុងអតីតអគារខ្មែរក្រហម។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ថែមទាំងបានផ្តល់ជាវគ្គបណ្តុះបណ្តាល ស្តីអំពីប្រវត្តិសាស្ត្រក្នុងតំបន់ និងថ្នាក់ជាតិ ដល់មគ្គុទេសក៍ទេសចរណ៍ និងអ្នកសម្របសម្រួលនៅក្នុងតំបន់នេះយ៉ាងទៀងទាត់ទៀតផង។

កិច្ចសន្ទនាតទល់គ្នាជាមួយអតីតយុទ្ធជនខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាទស្សនកិច្ចធ្វើដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រនានា សុទ្ធសឹងជាកិច្ចផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមសហការជាមួយនឹងក្រសួងទេសចរណ៍ ដើម្បីបង្កើតជាទិសដៅទេសចរណ៍ថ្មីមួយដែលមិនធ្លាប់ត្រូវបានដាក់បញ្ចូលជាទិសដៅទស្សនារបស់អ្នកទេសចរណ៍ពីមុនមក។

ដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង បង្កើតឲ្យមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន ដែលជាក្រុមគ្រួសារ និងជាអតីតកម្មាភិបាលខ្មែរក្រហម ឬអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានចំនួនស្ទួចស្ទើងក្នុងតំបន់ និងមិនមែនជាផ្នែកមួយនៃរបបនេះ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏ផ្តល់ជាបទបង្ហាញស្តីអំពីប្រវត្តិសាស្ត្រ និងកិច្ចពិភាក្សាជាក្រុមលើប្រធានបទស្តីពីសន្តិភាពនិងថាតើប្រវត្តិសាស្ត្រក្នុងស្រុកមានទំនាក់ទំនងជាមួយនឹងប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប យ៉ាងដូចម្តេចខ្លះ។

ដូចគ្នានឹងតំបន់ដទៃជាច្រើនផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសក្រោយជម្លោះ អន្លង់វែង គឺគ្រាន់តែជាផ្នែកតូចមួយដែលត្រូវបានរួមបញ្ចូលទៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសនិងតំបន់តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក្តី ក្នុងនាមជាករណីសិក្សាគំរូ អន្លង់វែងមិនត្រឹមតែជាបង្គួចភ្ជាប់ទៅកាន់ប្រវត្តិសាស្ត្រជាតិជារួមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែបង្ហាញអំពីបទពិសោធន៍ជាលក្ខណៈបុគ្គល និងមនុស្សជាតិជារួម ហើយសមាសធាតុទាំងនេះសក្តិសមបំផុតចំពោះការយល់ដឹងអំពីអនាគតរបស់យើង។ ដោយសារមូលហេតុទាំងអស់នេះ អន្លង់វែង គឺជាផ្នែកមួយនៃប្រវត្តិសាស្ត្រ និងអនាគតពិភពលោក។



ផែនទីជ្រលងភ្នំដងរែកនៅថ្ងៃអនាគត ស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ដេវ៉ា កាង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម

ឆាំង យុ



វេទិកាលើកកម្ពស់សិទ្ធិស្ត្រីនៅក្នុងភូមិយាងខាងត្បូង នៃស្រុកអន្លង់វែង កាលពីខែមករា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បេសកកម្មមួយក្នុងចំណោមបេសកកម្មជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តោតលើការលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ គម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍បានក្លាយជាសកម្មភាពចម្បងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីជំរុញឲ្យមានការជាសះស្បើយ យុត្តិធម៌ ការផ្សះផ្សា និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ សៀវភៅសិក្សាគោលមួយសម្រាប់គម្រោងនេះមានចំណងជើងថា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ សៀវភៅសិក្សានេះ និងអត្ថបទពាក់ព័ន្ធដទៃទៀត មានដូចជាសៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងបានក្លាយជាអត្ថបទគន្លឹះសម្រាប់កម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នេះដែរ។

សៀវភៅសិក្សាប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងមានគោលបំណងតភ្ជាប់ប្រវត្តិសាស្ត្រ «មុនពេល» និង «ក្រោយពេល» របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដើម្បីបង្ហាញទស្សនវិស័យទូលំទូលាយ

 លេខពិសេស ឆ្នាំ២០២៣

ស្ដីពីព្រឹត្តិការណ៍ដែលបណ្ដាលឲ្យកើតមានរបបខ្មែរក្រហម ព្រមទាំងប្រវត្តិសាស្ត្រដែលបានកើតឡើងបន្តបន្ទាប់មកទៀត តាមរយៈការផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើរយៈកាលក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារប្រវត្តិសាស្ត្រនេះមានទំនាក់ទំនងជាមួយសហគមន៍អន្លង់វែង។

អន្លង់វែងគ្រាន់តែជាភូមិឋានដ៏ស្ងាត់ជ្រងំដែលមានខ្លឹមសារតិចតួចណាស់ផ្នែកប្រវត្តិសាស្ត្រ រហូតដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីឆ្នាំ១៩៧៩ និងជាពិសេសបន្ទាប់ពីឆ្នាំ១៩៨៩ ដែលនៅពេលនោះកងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា ភូមិសាស្ត្រទាំងឡាយនៅជុំវិញអន្លង់វែងបានចាប់ផ្ដើមស្គាល់ថាជាតំបន់តស៊ូសំខាន់មួយរបស់ចលនាខ្មែរក្រហម។ សហគមន៍នេះមានទីតាំងស្ថិតនៅកៀកនឹងជួរភ្នំដងរែក និងបណ្ដោយព្រំដែនកម្ពុជាថៃ ដែលជាមូលហេតុសំខាន់សម្រាប់ការសម្រេចចិត្តរបស់ខ្មែរក្រហមក្នុងការបង្កើតមូលដ្ឋានយោធានៅក្នុងតំបន់នេះ។ អន្លង់វែងគឺជាតំបន់តស៊ូចុងក្រោយនៃចលនានេះហើយបានក្លាយទៅជាទីតាំងសំខាន់មួយរហូតដល់ថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហម។

ខ្មែរក្រហមគឺជាឈ្មោះដែលព្រះអង្គម្ចាស់ សីហនុ បានដាក់ឲ្យក្រុមកុម្មុយនីស្តនៅកម្ពុជា។ បក្សកុម្មុយនីស្តកម្ពុជាបានព្យាយាមអនុវត្តបដិវត្តន៍សង្គមនិយមបែបឆាប់រហ័ស នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីកំណែទម្រង់បែបលទ្ធិម៉ៅ និងម៉ាក្សលេនីន។ នៅពេលខ្លួនឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំសង្គមឡើងវិញនៅលើគ្រប់វិស័យទាំងអស់ ដោយចាប់ផ្ដើមពីការជម្លៀសប្រជាជនចេញពីទីប្រជុំជន។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនភាគច្រើនត្រូវបានបណ្ដេញដោយបង្ខំចេញពីផ្ទះសម្បែងរបស់ខ្លួនទៅកាន់តំបន់ដាច់ស្រយាលនៅតាមទីជនបទ។ គោលនយោបាយនៃការជម្លៀសប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត (ការជម្លៀសដោយបង្ខំ) បានបង្កឲ្យមានការឈឺចាប់ និងប៉ះពាល់យ៉ាងខ្លាំងលើប្រជាជននិងសហគមន៍។ ក្នុងរយៈពេល៤៥ខែ របបខ្មែរក្រហមបានធ្វើការជម្លៀសដោយបង្ខំជាច្រើនដងរវាងតំបន់និងតំបន់ផ្សេងទៀត។

ក្រៅពីនេះ លុយ ទីផ្សារសេរី និងទ្រព្យឯកជនត្រូវបានហាមឃាត់។ ការគោរពប្រតិបត្តិសាសនានិងវប្បធម៌ក៏ត្រូវបានហាមប្រាម ហើយសាលាសាធារណៈ វត្តអារាម វិហារអ៊ីស្លាម វិហារសាសនាគ្រឹស្ត និងហាងលក់ទំនិញត្រូវបានបិទ ឬប្រែក្លាយទៅជាមន្ទីរឃុំឃាំង ជំរំកែប្រែឡើងវិញ ឬគោលដៅផ្សេងៗរបស់របបនោះ។ មិនមានសេវាកម្មដឹកជញ្ជូនសាធារណៈ ឬឯកជនឡើយ ហើយសកម្មភាពកម្សាន្តផ្សេងៗត្រូវបានហាមឃាត់យ៉ាងតឹងរឹង។ ប្រជាជនត្រូវបានដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួនហើយមិនអនុញ្ញាតឲ្យចេញពីប្រទេសឡើយ។ ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ជំរំការងារពលកម្មត្រូវបានបង្កើតឡើងហើយសង្គមធ្វើឲ្យក្លាយទៅជាសមូហភាព។ ខ្មែរក្រហមជឿថា តាមរយៈកម្មវិធីតាមបែបកែប្រែទាំងស្រុងនេះខ្មែរក្រហមអាចមានលទ្ធភាពធ្វើឲ្យមានទិន្នផលកសិកម្មទទួលបានច្រើនសម្បូរបែប ហើយជឿថា អាចសម្រេចទៅបានទៀតផង។

រឿងរ៉ាវផ្ទុយស្រឡះបានកើតឡើងខណៈពេលដែលប្រជាជនជាច្រើនបានស្លាប់ដោយសារគ្រោះទុរ្ភិក្ស អត់ឃ្លាន អស់កម្លាំង ឬការកើតមានជំងឺ។ ក្រៅពីនេះដើម្បីការពារបក្សពីសត្រូវខាងក្នុង និងសត្រូវខាងក្រៅ ហើយដើម្បីដោះស្រាយភាពបរាជ័យនៃគោលនយោបាយកែប្រែទាំងស្រុងរបស់ខ្លួនខ្មែរ




១ ឯកឧត្តមទេសរដ្ឋមន្ត្រី គន់ គីម
២ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា
នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




① សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ② ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេស សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ ③ ឯកឧត្តម ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រហមបានបង្កើតនូវកម្មវិធីសន្តិសុខដ៏រឹងមាំដែលកំណត់មុខសញ្ញាមនុស្សទាំងឡាយណាដែលជាប់ពាក់ព័ន្ធទៅនឹងរបបមុនៗ បញ្ញវន្ត អ្នកមាន ព្រមទាំងអ្នកទាំងឡាយណាដែលខ្មែរក្រហមសង្ស័យ។ ប្រជាជនត្រូវបានចាប់ខ្លួន ហើយជារឿយៗត្រូវបានសម្លាប់ ឬត្រូវបានអស់កម្លាំងល្ហិតល្ហៃស្លាប់នៅក្នុងមន្ទីរសន្តិសុខ ឬជំរំកែប្រែ ដែលអ្នកទោសទាំងអស់នោះបានទទួលរង ហើយបានស្លាប់។ ខ្មែរក្រហមមិនបានស្ទាក់ស្ទើរក្នុងការប្រើប្រាស់ទម្រង់ធ្វើទារុណ-កម្មដ៏ឃោរឃៅបំផុតដើម្បីធ្វើឲ្យមានភាពអាម៉ាស់ បំផ្លិចបំផ្លាញ ធ្វើឲ្យលែងមានភាពជាមនុស្ស និងកម្ទេចអ្នកទាំងឡាយណាដែលសង្ស័យថាជាខ្មាំង។ របបនេះក៏មិនស្ទាក់ស្ទើរក្នុងការអនុវត្តយុទ្ធនាការឃោរឃៅទៅលើជនរងគ្រោះគ្រប់ប្រភេទ។ ស្ត្រី កុមារ និងសមាជិកដ៏ស្មោះស្ម័គ្ររបស់របបនេះក៏ទទួលរងនូវអំពើទារុណកម្ម និងការកាប់សម្លាប់ដែរ។ ក្រុមជនជាតិភាគតិចខាងសាសនានិងជាតិពន្ធុត្រូវបានទទួលរងគ្រោះ ហើយរបបខ្មែរក្រហមមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើអ្នកណាដែលមានប្រវត្តិរូបជាវៀតណាម ឬ (មិនមែនជា ខ្មែរ)។

អន្លង់វែងត្រូវបានបង្កើតឡើងតាំងពីយូរអង្វែងណាស់មកហើយ មុនពេលដែលតំបន់នេះក្លាយទៅជាតំបន់កាន់កាប់ចុងក្រោយដ៏ល្បីល្បាញរបស់ចលនាកុម្មុយនីស្តខ្មែរក្រហម។ នៅឆ្នាំ១៩០៧ តំបន់អន្លង់វែង




① ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក Patrick Murphy
② លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា
③ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទស្សនកិច្ចសារមន្ទីរផ្ទះតាម៉ុកនៅអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ត្រូវបានទទួលស្គាល់ដោយអ្នកគូរផែនទីជនជាតិបារាំង នៅពេលដែលអ្នកគូរផែនទីបង្កើតខ្សែរបន្ទាត់ព្រំដែនកម្ពុជា ជាមួយនឹងប្រទេសជិតខាងភាគខាងជើង។ ដូចសហគមន៍ផ្សេងៗទៀត ដែលត្រូវបានបង្កើតឡើងនៅតាមបណ្តោយព្រំដែនខាងទឹកដីថៃដែរ

លេខពិសេស ឆ្នាំ២០២៣



ឯកអគ្គរដ្ឋទូតហ្វីលីពីន AMELITA AQUINO អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ទស្សនកិច្ចទីតាំងផ្ទះរបស់ ប៉ុល ពត នៅក្បាលទន្សោង ស្ថិតក្នុងស្រុកអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តំបន់អន្លង់វែងមានជនជាតិខ្មែររស់នៅ ដែលបានចំណាកស្រុកមកពីភាគខាងត្បូងនៃទឹកដីសៀម ដែលបច្ចុប្បន្នស្ថិតនៅក្នុងខេត្តស៊ីសាកេតរបស់ប្រទេសថៃ។ នៅចន្លោះឆ្នាំ១៩៤១ដល់ឆ្នាំ១៩៤៦ អន្លង់វែងបានដាក់បញ្ចូលទៅក្នុងខេត្តប្លែកភីប៊ុនសង់ក្រាម របស់ថៃ។ ថៃ បានគ្រប់គ្រងទៅលើអ្វីដែលធ្លាប់ជាខេត្តសៀមរាប និងខេត្តបាត់ដំបង របស់ខ្មែរ រហូតដល់ឆ្នាំ១៩៤៦ នៅពេលដែលបារាំង និងថៃ ចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាព្រំដែន ដែលបានប្រគល់ខេត្តទាំងពីរមកឲ្យកម្ពុជាវិញ។ ចាប់ពីឆ្នាំ១៩៤៦ តំបន់នេះបានក្លាយទៅជាផ្នែកមួយនៃប្រទេសកម្ពុជា។

បារាំង បានបង្កើតប៉ុស្តិ៍ប៉ូលិសព្រំដែនតូចមួយនៅតាមបណ្តោយព្រំដែននេះដើម្បីការពារ ការវាយប្រហារពីក្រុមចោរព្រៃ ដែលបង្កជាបញ្ហាខ្លាំងនៅក្នុងតំបន់នោះ។ នៅឆ្នាំក្រោយៗមកទៀត ភាពដាច់ស្រយាលរបស់អន្លង់វែងបានធ្វើឲ្យតំបន់នេះក្លាយទៅជាគោលដៅងាយស្រួលបំផុតសម្រាប់ការជ្រៀតចូល និងការកាន់កាប់របស់ខ្មែរក្រហម។ ខ្មែរក្រហមបានគ្រប់គ្រងអន្លង់វែងនៅក្នុងឆ្នាំ១៩៧០ ហើយនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមប្រជាជនអន្លង់វែងក៏បានមើលឃើញពីការផ្លាស់ប្តូរទាំងស្រុង នៃរបៀបរបបរស់នៅតាមបែបប្រពៃណីរបស់ខ្លួន។ មនោគមវិជ្ជាបដិវត្តន៍របស់ខ្មែរក្រហម បានតម្រូវឲ្យប្រជាជនបោះបង់ចោលនូវវប្បធម៌ និងការគោរពប្រតិបត្តិផ្សេងៗរបស់សហគមន៍។

ជីវភាពរស់នៅមានការលំបាកយ៉ាងខ្លាំងនៅក្រោមរបបខ្មែរក្រហម។ មិនមានអាហារហូបចុកគ្រប់គ្រាន់ទេ ហើយប្រជាជនរស់នៅក្នុងភាពភ័យខ្លាច អ្វីក៏ដោយក៏អាចបង្កទៅជាការសង្ស័យដែរ។ ឧទាហរណ៍៖ អ្នករស់រានមានជីវិតម្នាក់បាននិយាយរំលឹកឡើងវិញថាធ្លាប់បានឃើញមនុស្សត្រូវបានដឹកតាមរទេះ ហើយបានទម្លាក់នៅកន្លែងសម្លាប់មួយកន្លែង ដោយគ្រាន់តែជនរងគ្រោះនោះចំណាយពេលយូរពេកនៅក្នុងបន្ទប់ទឹក ឬនៅកន្លែងការដ្ឋានការងារ។ ទីកន្លែងសម្លាប់នោះគឺ នៅក្នុងស្រុកត្រពាំងប្រាសាទ ហើយត្រូវបានជឿថា នៅក្បែរឡពិឃាតភ្នំទ្រង់បាត្រ។ នៅទីតាំងនោះ មានការរាយការណ៍មកថាមនុស្សរាប់រយនាក់ ហើយប្រហែលជារាប់ពាន់នាក់ដែលត្រូវបានយកទៅសម្លាប់។ ក្នុងរយៈកាលនៃរបបខ្មែរក្រហម អន្លង់វែងត្រូវបានបោះបង់ចោលដោយសារតែមនុស្សនៅក្នុងសហគមន៍នេះត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីកន្លែងរស់នៅទៅកាន់តំបន់កសិកម្ម។ នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅត្រឹមខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ។ នៅពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅនៅដើមឆ្នាំ១៩៧៩ ប្រជាជនអន្លង់វែងបានត្រឡប់មកកាន់សហគមន៍របស់ខ្លួនវិញ ដែលបន្ទាប់មកប្រជាជនទាំងអស់នោះក៏ប្រឈមនឹងការលំបាកម្តងទៀតដោយត្រូវបានស្ថិតនៅចន្លោះកណ្តាលនៃកងកម្លាំងទ័ពដែលមានភាពស្មោះស្ម័គ្រនឹងកងកម្លាំងរដ្ឋាភិបាល និងកងកម្លាំងខ្មែរក្រហម។ កម្លាំងសេសសល់របស់ខ្មែរក្រហមក៏បានស្វែងរកទីជ្រកកោននៅតាមតំបន់ជួរភ្នំដងរែក ខណៈពេលដែលកងកម្លាំង នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាមបានដណ្តើមកាន់កាប់តំបន់អន្លង់វែងទាំងមូល។

ចាប់ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ កងទ័ពខ្មែរក្រហម និងប្រជាជនរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ឬនៅតាមជំរំភៀសខ្លួនផ្សេងៗនៅក្នុងទឹកដីថៃ។

មូលដ្ឋានរបស់កងទ័ពខ្មែរក្រហមធំៗចំនួនពីរ ដែលមានសម្ព័ន្ធភាពជាមួយនឹងតំបន់អន្លង់វែង ត្រូវបានស្គាល់ថាជាភ្នំ១០០១ និងភ្នំ១០០៣។ ចំពោះប្រជាជនដែលរស់នៅតាមជួរភ្នំដងរែក ឬអន្លង់វែង គឺមានស្ថានភាពរស់នៅលំបាកយ៉ាងខ្លាំង។ ប្រជាជនទាំងអស់នោះបានពណ៌នាអំពីជីវិតរបស់ខ្លួនថាជាការរស់នៅប្រកបដោយភាពភ័យខ្លាច និងគ្មានទីជម្រកច្បាស់លាស់។ ការប្រយុទ្ធគ្នារវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងវៀតណាម បានកើតឡើងជាញឹកញាប់ ហើយដើម្បីការពារសហគមន៍របស់ខ្លួន ស្ត្រីនិងកុមារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ត្រូវធ្វើការងារមួយចំនួន ដូចជា បិតចម្រូង និងដឹកជញ្ជូនស្បៀង ឬគ្រឿងសព្វាវុធផ្សេងៗ ។

ដោយសារតែកងទ័ពវៀតណាមបានដកចេញនៅក្នុងឆ្នាំ១៩៨៩ ខ្មែរក្រហមបានបើកការវាយលុក និងធ្វើការគ្រប់គ្រងនូវតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា។ នៅចុងឆ្នាំ១៩៨៩ ខ្មែរក្រហមនៅភ្នំ១០០៣ ដែលស្ថិតនៅក្រោមការដឹកនាំរបស់មេបញ្ជាការកងទ័ពថ្នាក់កណ្តាលឈ្មោះ ឈិត ជឿន ឬហៅថា តាម៉ុក បានធ្វើការវាយលុកដណ្តើមកាន់កាប់អន្លង់វែង។ ខ្មែរក្រហមបានកាន់កាប់អន្លង់វែងនៅក្នុងខែធ្នូ ឆ្នាំ១៩៨៩ ហើយតាម៉ុក បានចាប់ផ្តើមប្រមែប្រមូលប្រជាជនជាច្រើនមកពីជំរំជនភៀសខ្លួនឲ្យមករស់នៅអន្លង់វែង។ នៅពេលដែលអន្លង់វែងចាប់ផ្តើមមានមនុស្សរស់នៅ សារជាថ្មី ខ្មែរក្រហមក៏បានរៀបចំភូមិស្ថានឲ្យស្របទៅតាមរចនាសម្ព័ន្ធកងទ័ពនីមួយៗ។

សហគមន៍នេះ បានពឹងផ្អែកយ៉ាងខ្លាំងទៅលើតាម៉ុក បើទោះបីជា តាម៉ុក ធ្លាប់មានកិត្តិនាមថាជាមនុស្សឃោរឃៅក៏ដោយ។ កងកម្លាំងរបស់ តាម៉ុក បានទទួលខុសត្រូវលើការសម្លាប់ប្រជាជន និងកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិភាគបូព៌ា កាលពីជំនាន់របបកម្ពុជាប្រជាធិបតេយ្យ ហើយ តាម៉ុក ក៏ត្រូវបានស្គាល់ថា «តាម៉ុកៈមេពជ្ឈឃាដ» ។ ទោះបីជាមានកិត្តិនាមបែបនេះក៏ដោយ តាម៉ុកក៏ត្រូវបានស្គាល់ថាជាមនុស្សគួរឲ្យគោរពនៅក្នុងសហគមន៍នេះដែរ។ ភាគច្រើនតាម៉ុកបានចំណាយពេលជាមួយនឹងប្រជាជននៅតាមមូលដ្ឋាន ហើយគាត់បានអនុវត្តនូវគម្រោងសាងសង់ជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍។

ដោយមានការគាំទ្រពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (ហៅកាត់ថា អ៊ុនតាក់) រដ្ឋាភិបាលកម្ពុជាបានរៀបចំឲ្យមានការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣។ ការបោះឆ្នោតនេះ ត្រូវបានខ្មែរក្រហមធ្វើពហិការមិនព្រមចូលរួម។ បន្ទាប់ពីការបោះឆ្នោតនេះបញ្ចប់ទៅ ជំនួយគាំទ្ររបស់បរទេសមកកាន់ខ្មែរក្រហម ក៏ត្រូវបានកាត់ផ្តាច់ទាំងស្រុង ហើយចលនាខ្មែរក្រហមក៏បានបាត់បង់កម្លាំងរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ ដែលកម្រិតនៅត្រឹមតំបន់តូចមួយ។ សមាជិកជាន់ខ្ពស់មួយចំនួនរបស់ខ្មែរក្រហម (ប៉ុល ពត, សុន សេន, នួន ជា, ខៀវ សំផន និងតាម៉ុក) ចាប់ផ្តើមមានជម្លោះផ្ទៃក្នុង និងសង្ស័យថាមានការក្បត់គ្នាទៅវិញទៅមក។ នៅល្ងាចថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ ប៉ុល ពត បានបញ្ជូនមេបញ្ជាការរបស់គាត់ឈ្មោះ សារឿន ឲ្យទៅសម្លាប់ សុន សេន និងប្រពន្ធរបស់គាត់ ដែលរស់នៅក្នុងផ្ទះមួយដែលកសាងដោយតាម៉ុក។ នៅក្នុងអំឡុងម៉ោងប្រហែល ១១យប់ សារឿន បានដឹកនាំទាហានមួយក្រុមដោយមានគ្នាប្រមាណជា ២០-៣០នាក់ ធ្វើដំណើរទៅកាន់ផ្ទះ សុន សេន។ ក្រុមទាហានទាំងនោះបានបាញ់សម្លាប់ សុន សេន ព្រមទាំងក្រុមគ្រួសារទាំងមូល។ នៅពេលទទួលបានព័ត៌មានអំពីការស្លាប់របស់ សុន សេន តាម៉ុក បានបញ្ជាឲ្យប្រមូលកម្លាំង ហើយជម្លោះ៥ថ្ងៃក៏បានកើតឡើងរវាងកងកម្លាំងដែលស្មោះស្ម័គ្រជាមួយនឹងតាម៉ុក និងកងកម្លាំងដែលស្មោះស្ម័គ្រជាមួយនឹង ប៉ុល ពត ។ បន្ទាប់ពីការវាយប្រយុទ្ធអស់រយៈពេល៥ថ្ងៃ កងកម្លាំងរបស់ ប៉ុល ពត បានសុំចុះចាញ់ ហើយ ប៉ុល ពត និងមេបញ្ជាការកងទ័ពរបស់ខ្លួន ព្រមទាំងមេដឹកនាំផ្សេងៗទៀត ក៏ត្រូវបានចាប់ខ្លួន។ មេបញ្ជាការកងទ័ពមួយចំនួនត្រូវបានដាក់ក្នុងទ្រុងដែកចំនួនពីរ ដែលបច្ចុប្បន្នយើងអាចឃើញទ្រុងដែកនេះនៅផ្ទះក្បែរមាត់បឹងរបស់តាម៉ុក។ ប៉ុល ពត ក៏ត្រូវបានថ្កោលទោសនៅចំពោះមុខតុលាការប្រជាជនដែលជាការរៀបចំឡើងដោយខ្មែរក្រហម។ តុលាការនេះមានទម្រង់បែប

ជាការសូត្រសុទ្ធរកថា ដើម្បីផ្ដោលទោស ប៉ុល ពត។ នៅទីបញ្ចប់ ប៉ុល ពត ត្រូវបានកាត់ទោសឲ្យជាប់ទោសអស់មួយជីវិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក។

នៅក្នុងអំឡុងពេលឈានទៅដល់ការបោះឆ្នោតជាតិ ដែលជាការរៀបចំដោយអង្គការសហប្រជាជាតិនៅកម្ពុជាកាលពីឆ្នាំ១៩៩៣ មេបញ្ជាការកងទ័ពខ្មែរក្រហមក៏បានសហការជាមួយ នឹងមន្ត្រីរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬរដ្ឋកម្ពុជា។ មេបញ្ជាការរបស់ខ្មែរក្រហម ទាំងអស់នេះបានបង្កើតនូវទំនាក់ទំនងល្អ និងសម្របសម្រួលឲ្យមានការចរចាដើម្បីធ្វើសមាហរណកម្មចុងក្រោយនៃកងកម្លាំងខ្មែរក្រហមនៅអន្លង់វែង។ ក្នុងការចរចានេះមានការព្រមព្រៀងគ្នា ដើម្បីផ្ដាច់ខ្លួនចេញពីការគ្រប់គ្រងរបស់តាម៉ុក។ នៅពេលដែលការព្រមព្រៀងគ្នានេះបានលេចឮទៅដល់តាម៉ុក បានធ្វើឲ្យកើតមានការប្រយុទ្ធគ្នារវាងអ្នកដែលផ្ដាច់ខ្លួន និងកម្លាំងដែលស្មោះស្ម័គ្រជាមួយតាម៉ុកនៅក្នុងខែមីនា ឆ្នាំ១៩៩៨។ ការប្រយុទ្ធគ្នានេះបានបន្តអស់រយៈពេលជាច្រើនខែ។ នៅក្នុងអំឡុងពេលនៃការប្រយុទ្ធគ្នានេះ ប៉ុល ពត ដែលកំពុងមានសុខភាពទន់ខ្សោយ ក៏បានស្លាប់ដោយសារជំងឺគាំងបេះដូង។ ដោយសារតែកង្វះអុកស៊ីសែន និងថ្នាំពេទ្យ ទើបធ្វើឲ្យកងកម្លាំង តាម៉ុក មិនអាចមើលថែទាំ ប៉ុល ពត បានឡើយ។ ក្នុងអំឡុងពេលនៃការដកថយរបស់កងទ័ព ប៉ុល ពត ក៏បានស្លាប់នៅលើគ្រែក្នុងថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយមានប្រពន្ធវ័យក្មេង និងកូនស្រីនៅក្បែរគាត់។ ពីរថ្ងៃក្រោយមក សពរបស់ ប៉ុល ពត ត្រូវបានបូជានៅលើគ្រែ រួមជាមួយ នឹងសម្បកកង់ឡាន។

បន្តិចម្ដងៗក្រុមទាហានរបស់ តាម៉ុក បានចុះចូល ព្រោះកងកម្លាំងរបស់តាម៉ុកកាន់តែមានភាពទន់ខ្សោយ និងបាត់បង់ស្មារតីក្នុងការប្រយុទ្ធ។ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៨ ភាគីទាំងសងខាងបានឈានដល់ការព្រមព្រៀងគ្នាធ្វើសមាហរណកម្មចុងក្រោយបង្អស់នៃកងកម្លាំងខ្មែរក្រហម និងធ្វើការរំលាយអង្គភាពទ័ពខ្មែរក្រហមទាំងអស់។ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ពិធីសមាហរណកម្មផ្លូវការត្រូវបានធ្វើឡើងនៅក្នុងស្រុកអន្លង់វែង។ ដំបូងឡើយ តាម៉ុក ត្រូវបានឃុំខ្លួននៅក្នុងផ្ទះ។ ប៉ុន្តែក្រោយមក តាម៉ុកក៏ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់តុលាយោធានៅក្នុងទីក្រុងភ្នំពេញ ដើម្បីរង់ចាំការកាត់ទោស។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ តាម៉ុកក៏បានស្លាប់នៅក្នុងអាយុ៨០ឆ្នាំ។ សពរបស់គាត់ត្រូវបានបញ្ជូនត្រឡប់ទៅកាន់អន្លង់វែងវិញ ហើយពិធីបុណ្យសពក៏បានធ្វើឡើងយ៉ាងអធិកអធម។ ចេតិយយ៉ាងធំរបស់តាម៉ុក ត្រូវបានកសាងឡើងនៅក្នុងវត្តស្រះឈូក។

ទីតាំងដែលត្រូវទស្សនកិច្ចនៅក្នុងស្រុកអន្លង់វែង ដោយមានការសហការពីក្រសួងទេសចរណ៍ សហគមន៍មូលដ្ឋាន និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានកំណត់ទីតាំងចំនួន១៤ដែលមានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រ ឬបរិស្ថាន។ សម្រាប់ដំណើរទស្សនកិច្ចដែលមានរយៈពេលកន្លះថ្ងៃ អ្នកទេសចរណ៍ទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យធ្វើទស្សនកិច្ចទៅកាន់ទីតាំងមួយចំនួនដូចខាងក្រោម៖

- ផ្ទះតាម៉ុក ឬសារមន្ទីរតាម៉ុក និង
- ផ្ទះតាម៉ុក (ផ្ទះកណ្ដាលរបស់តាម៉ុក នៅលើខ្នងភ្នំដងរែក) ហើយក៏ជាទីតាំងនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

ដោយរាប់បញ្ចូល ទាំងទីតាំងផ្សេងៗទៀត៖ (ក). ទីតាំងបូជាសព សុន សេន និងគ្រួសារ (ខ). ទីតាំងបូជាសព ប៉ុល ពត (គ). បឹងអន្លង់វែង និង(ឃ). ស្ពានតាម៉ុក។



ឯកអគ្គរដ្ឋទូតសិង្ហបុរី Teo Lay Cheng អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ទស្សនកិច្ចទីតាំងផ្ទះរបស់ ប៉ុល ពត នៅក្បាលទន្សោង ស្ថិតក្នុងស្រុកអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុល ហាំះ កងស៊ើបការណ៍សម្ងាត់ សេ-អ៊ី-អា នៅតំបន់៥ ភូមិភាគពាយ័ព្យ

ស្លូត វិចិត្រ



កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុល ហាំ មានអាយុ២៨ឆ្នាំនៅក្នុងឆ្នាំ១៩៧៧ មានទីកន្លែងកំណើតនៅក្នុងឃុំចន្ទាសដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប ស្ថិតនៅតំបន់ ១០៦ ភូមិភាគឧត្តរ។

នៅឆ្នាំ១៩៦៨ ខ្ញុំចាកចេញពីឪពុកម្តាយហើយទៅរស់នៅក្នុងវត្តស្នួល អស់រយៈពេលមួយឆ្នាំ។ បន្ទាប់មក ខ្ញុំក៏បានវិលត្រឡប់ទៅរស់នៅជួបជុំក្រុមគ្រួសារវិញរហូតដល់ខ្ញុំធំដឹងក្តី។

ក្រោយមកនៅឆ្នាំ១៩៧២ ខ្ញុំបានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមនៅក្នុងកងអនុសេនាធំលេខ១០៥ តំបន់៥ ភូមិភាគពាយ័ព្យ ដោយមានតួនាទីគឺជាអ្នកកាន់ផ្នែកសេដ្ឋកិច្ច។ រយៈពេលពីរខែក្រោយមក ខ្ញុំផ្លាស់ទៅកាន់អនុសេនាធំលេខ១០៩ ក្រោមការគ្រប់គ្រងរបស់ ធន ដោយធ្វើការចុះពិនិត្យពីស្ថានភាពរបស់ប្រជាជននៅក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប។ ធនបានណែនាំឲ្យខ្ញុំចូលរួមទៅក្នុងចលនាបំផុសបំផុលប្រជាជនក្នុងមូលដ្ឋានជាមួយនឹងខ្សែ សេ-អ៊ី-អា។ ធន ចាត់តាំងខ្ញុំធ្វើការទំនាក់ទំនងជាមួយនឹងឈ្មោះ គឿន គឺជាអតីតសិស្សរៀននៅសាលាបាត់ដំបង ដើម្បីឲ្យដឹងពីសភាពការណ៍ផ្សេងៗរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហម។ គឿន ផ្តល់ដំណឹងមកខ្ញុំថា យើងត្រូវរាយការណ៍ឲ្យកងយន្តហោះរបស់ លន់ នល់ មកទម្លាក់គ្រាប់បែកនៅភូមិរំលំស្វាយ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ មួយថ្ងៃក្រោយមក យន្តហោះស្ទាបកាត់ចំនួន ២គ្រឿងក៏បានទៅទម្លាក់គ្រាប់បែកនៅទីនោះមែន ដោយបានសម្លាប់ប្រជាជនអស់មួយចំនួន។ នៅពេលនោះ ធន បញ្ជូនខ្ញុំនិង គឿន ឲ្យស្វែងរកមន្ទីរបដិវត្តន៍របស់ខ្មែរក្រហម ដើម្បីទម្លាក់គ្រាប់បែកបន្តទៀត។ លុះដល់ចុង

*ឆ្នាំ១៩៧៣ ខ្ញុំបន្តស៊ើបការណ៍នៅក្នុងភូមិសសែពង ស្រុកក្រឡាញ់ ខេត្តសៀមរាប និងរាយការណ៍ឲ្យយន្តហោះទៅទម្លាក់គ្រាប់បែកនៅទីនោះដែលបណ្តាលឲ្យកងទ័ពខ្មែរក្រហមចំនួន៣នាក់ ស្លាប់បាត់បង់ជីវិត។*

*រហូតដល់ខែមេសា ឆ្នាំ១៩៧៤ ខ្ញុំបន្តធ្វើសកម្មភាពបំផុសបំផុលឲ្យយុទ្ធជនចាកចេញពីកងអង្គភាពលេខ១០៩ ទៅកាន់ផ្ទះរបស់ខ្លួន អស់ចំនួន ២នាក់និង១នាក់ទៀតរត់ទៅតំបន់ខ្លាំង ព្រមទាំងធ្វើសកម្មភាពបន្ទុចបន្ទាក់ទៅលើផែនការរបស់ខ្មែរក្រហម។ នៅក្នុងឆ្នាំដដែលនោះ អង្គភាពរបស់ខ្ញុំក៏បានផ្លាស់ខ្ញុំទៅកាន់ស្រុកថ្មពួក ខេត្តបាត់ដំបង ដោយភ្ជាប់មកជាមួយនូវសំបុត្រមួយច្បាប់ទៅកាន់ ឌុន គឺជាភ្នាក់ងារសេ-អ៊ី-អា ចាស់នៅតំបន់ខ្លាំង ដើម្បីបន្តខ្សែរយៈក្នុងដើរបំផុសបំផុលប្រជាជន និងកងទ័ព នៅក្នុងអង្គភាពមួយចំនួនទៀត។*

*រហូតដល់ខែកក្កដា ឆ្នាំ១៩៧៤ ខ្ញុំបានទាក់ទងជាមួយនឹងខ្សែរយៈសេ-អ៊ី-អា ចំនួន៦នាក់ទៀត ដើម្បីពង្រឹកកម្លាំង និងបន្តសកម្មភាពរបស់ខ្លួន ដោយក្រោយមក ខ្ញុំរៀបចំផែនការកម្ទេចកងកម្លាំងបដិវត្តន៍ខ្មែរក្រហមដោយរាយការណ៍ឲ្យមានការទម្លាក់គ្រាប់បែកទៅលើភូមិត្រពាំងថ្ម។ កងទ័ពខ្មែរក្រហមចំនួន ៦នាក់ បានស្លាប់បាត់បង់ជីវិត និង ៤នាក់ផ្សេងទៀតទទួលរងរបួស។ ក្នុងហេតុការណ៍នេះ ខ្ញុំបានបញ្ជូនកម្លាំងក្បត់ សេ-អ៊ី-អា ចំនួន ២នាក់ ដើម្បីដាក់មីនទៅលើកងកម្លាំងថ្មើរជើងនៅក្នុងភូមិជ្រាប់ ស្រុកព្រះនេត្រព្រះ ដោយបានសម្លាប់កងទ័ពខ្មែរក្រហមចំនួន៥នាក់ទៀត។*

*លុះដល់ចុងឆ្នាំ១៩៧៤ ខ្ញុំរាយការណ៍ទៅកាន់ គឿន និង យ៉ាន អំពីសភាពការណ៍របស់កងទ័ពខ្មែរក្រហមនៅខាងកើតភូមិភាស់ និងបញ្ជូនគោលដៅឲ្យយន្តហោះទៅទម្លាក់គ្រាប់បែកនៅទីនោះ។ មនុស្សចំនួន ៩នាក់បានស្លាប់ និងកុមារចំនួន១នាក់ទៀតបានទទួលរងរបួស។*

*រហូតដល់ខែមករា ឆ្នាំ១៩៧៥ ខ្ញុំពិភាក្សាជាមួយនឹងកងស៊ើបការណ៍សម្ងាត់របស់ សេ-អ៊ី-អា ម្តងទៀតដើម្បីកម្ទេចកងកម្លាំងបដិវត្តន៍ខ្មែរក្រហមនៅត្រង់ភូមិស្វាយចេក ស្រុកថ្មពួក ខេត្តបាត់ដំបង ដែលបណ្តាលឲ្យកងទ័ពខ្មែរក្រហមប្រមាណជាចំនួន ១៨នាក់ បានស្លាប់ និង ៣២នាក់ទៀតទទួលរងរបួស។ ដល់ខែឧសភា ខ្ញុំផ្លាស់ប្តូរទៅកាន់កងអង្គភាពទ័ពភូមិភាគ វរសេនាតូចលេខ៤១៥ វរសេនាធំលេខ៤០ កងពលទី១ នៃភូមិភាគពាយ័ព្យវិញ ដោយមានតួនាទីជាអនុសេនាធំ នៅក្នុងកងវរសេនាតូចលេខ៤១៥។ នៅពេលនោះ ហ៊ឹង គឺជាគណៈតំបន់៥ ណែនាំឲ្យខ្ញុំធ្វើសកម្មភាពបំផុសបំផុលក្នុងជួរកងទ័ពបន្តទៀតជាមួយនឹងខ្សែ សេ-អ៊ី-អា។ ខែសីហា យើងរៀបចំផែនការទំនាក់ទំនងជាមួយកងទ័ពសៀម និងកងកម្លាំងទ័ព អ៊ិនតាំ តាមរយៈចាប់ប្រជាជនខ្មែរណាដែលឧស្សាហ៍ចេញ-ចូលទៅក្នុងប្រទេសសៀមឲ្យនាំផ្លូវយើងទៅជួបនឹងកងកម្លាំងរបស់ អ៊ិនតាំ។ ក្រោយមក យើងភ្ជាប់ទំនាក់ទំនងជាមួយនឹងកងកម្លាំងរបស់អ៊ិនតាំ បានជោគជ័យ និងណាត់ជួបគ្នានៅម្តុំបង្គោល ឡាក់លេខ៣៥។ ម្យ៉ាងទៀត កងកម្លាំងរបស់ខ្ញុំ ធ្វើការជួបជាមួយនឹងកងទ័ពរបស់អ៊ិនតាំ នៅផ្លូវគោកខ្សង ផ្លូវបង្គោល ឡាក់លេខ៣៧ដែរ។*

*រហូតដល់ឆ្នាំ១៩៧៦ កងកម្លាំងរបស់ខ្ញុំស្វែងរកជំនួយគាំទ្រពីកងកម្លាំងរបស់ អ៊ិនតាំ នៅក្នុងទឹកដីសៀម ទាំងផ្នែកសព្វាវុធ, ស្បៀងអាហារ សំម្លៀកបំពាក់ និងការឃោសនាដទៃផ្សេងទៀតដើម្បីពង្រឹកកម្លាំង និងវាយប្រហារពីចំណុចមិនល្អរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ ក្រោយមក ដោយសារមានជំនួយមួយចំនួន កងកម្លាំងរបស់យើងបានបន្តសកម្មភាព ដើម្បីបំផុសបំផុលប្រជាជននៅតាមសហករណ៍ រហូតដល់កងទ័ពបដិវត្តន៍ខ្មែរក្រហមចាប់ខ្លួនខ្ញុំនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ AVDC-CAM 0869។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ អ៊ុល ហាំ ពិតបុយ៉ាងណានោះទេ?***

# ទួន ហម ៖ ខ្ញុំឃើញឈ្លបខ្មែរក្រហមបណ្តើរមនុស្សយកទៅសម្លាប់

***ហ៊ាន ពិសី***



ទួន ហម អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទួន ហម អាយុ៦០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិបឹងបាសាក់ ឃុំសំបួរមាស ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បច្ចុប្បន្ន ហម រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ហម បានចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមថា «នៅឆ្នាំ១៩៧៥ ខ្មែរក្រហមជ្រើសរើសខ្ញុំឲ្យធ្វើជាកងចល័ត។ កិច្ចការងារខ្ញុំពេលនោះគឺរែកដីនៅតាមការដ្ឋាន និងលើកទំនប់។ ប៉ុន្តែខ្ញុំមិនបានចល័តទៅណាឆ្ងាយពីស្រុកកំពង់សៀមទេ។ ក្រោយមកនៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមរើសយុវជនដែលមានវ័យជំទង់ៗនៅក្នុងកងចល័តឲ្យទៅធ្វើកងទ័ព ដោយខ្មែរក្រហមជ្រើសយកតែអ្នកដែលស្អាតស្អំ និងមានប្រវត្តិល្អ ដែលក្នុងនោះមានខ្ញុំម្នាក់ដែរ។ ប៉ុន្តែឪពុកមាខ្ញុំដែលជាប្រធានកងធំនៅស្រុកកំពង់សៀមមិនឲ្យខ្ញុំទៅធ្វើការនៅកន្លែងផ្សេងទេ។ ដូច្នេះខ្ញុំក៏ត្រូវនៅធ្វើការ និងស្នាក់នៅជាមួយឪពុកមារបស់ខ្ញុំរហូត។

ថ្ងៃមួយឪពុកមាខ្ញុំ ប្រើខ្ញុំឲ្យទៅរកត្រីនៅមាត់ទន្លេ។ កាលណោះខ្ញុំទៅជាមួយនឹងបងប្អូនជីដូនមួយខ្ញុំពីរនាក់ទៀត។ ប៉ុន្តែចៃដន្យពេលដែលត្រឡប់មកវិញ ខ្ញុំបានឃើញឈ្លបខ្មែរក្រហមចំនួនបីនាក់កំពុងបណ្តើរមនុស្សប្រហែល៥០នាក់។ ខ្ញុំបានលាក់ខ្លួនពួននៅក្នុងគុម្ពស្បូវដើម្បីលបចាំមើលថាតើឈ្លប

ខ្មែរក្រហមនាំមនុស្សទាំងនោះទៅណា។ ប៉ុន្តែខ្ញុំពុំបាននៅយូរទេព្រោះខ្ញុំខ្លាចឈ្លបខ្មែរក្រហមឃើញ ខ្ញុំដូច្នេះខ្ញុំនាំគ្នាត្រឡប់មកសហករណ៍វិញដើម្បីប្រាប់រឿងនេះដល់ឪពុកមាររបស់ខ្ញុំ។ ឪពុកមាររបស់ខ្ញុំបានហាមខ្ញុំមិនឲ្យនិយាយអ្វីទាំងអស់ ឬប្រាប់រឿងនេះទៅនរណាឲ្យដឹងឡើយ។ លុះរំលងបានបីថ្ងៃក្រោយ ខ្ញុំនិងបងប្អូនជីដូនមួយពីរនាក់ទៀត បានដើរកាត់កន្លែងនោះម្តងទៀតដើម្បីទៅរកត្រីដូចរាល់ដង។ ខ្ញុំលួចចូលទៅមើលកន្លែងដែលខ្មែរក្រហមនាំមនុស្សយកទៅកាលពីលើកមុនម្តងទៀត។ នៅពេលទៅដល់ ខ្ញុំបានឃើញរណ្តៅមួយ ដែលមានសាកសពស្លាប់គលើគ្នាពេញមួយរណ្តៅ។ នៅពេលនោះខ្ញុំភិតភ័យខ្លាំងណាស់ និងមិនអាចធ្វើអ្វីបានទេ។ ខ្ញុំក៏រត់ត្រឡប់ទៅសហករណ៍វិញដោយមិនហ៊ាននិយាយអ្វីទាំងអស់»។



ទូន ហម (រូបខាងឆ្វេង) ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវរបស់គាត់ដែលបានឆ្លងកាត់របបខ្មែរក្រហម ដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯក គាប់ ៖ យោធា

**មេក ខិន**



ឯក គាប់ អង្គុយលើគ្រែនៅចំហៀងផ្ទះរបស់គាត់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឯក គាប់ ភេទប្រុស អាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ។ សព្វថ្ងៃខ្ញុំរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរ-មានជ័យ។ នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវខ្មែរក្រហមកេណ្ឌឲ្យចូលធ្វើជាកងទ័ព។ កាលនោះយុវជននៅក្នុងភូមិខ្ញុំចំនួន១០នាក់ផ្សេងទៀត ត្រូវបានកេណ្ឌមកចូលជាកងទ័ពរំដោះជាមួយខ្ញុំដែរ។ បន្ទាប់ពីប្រមូលកម្លាំងនៅភូមិបានហើយខ្មែរក្រហមបញ្ជូនឲ្យទៅនៅកន្លែងហ្វឹកហាត់នៅភ្នំឧដុង្គ។ កម្លាំងដែលយកចេញពីភូមិខ្ញុំទាំងចំនួន១០នាក់បានរត់ចេញពីជួរកងទ័ពអស់ចំនួន៨នាក់ ដោយសារតែមិនអាចទ្រាំនឹងការលំបាកបាន។ ខ្ញុំនិងមិត្តខ្ញុំម្នាក់ទៀតបានហ្វឹកហាត់រហូតចេញទៅវាយនៅសមរភូមិប៉ុន្តែជាការសោកស្តាយមិត្តរបស់ខ្ញុំត្រូវស្លាប់នៅពេលធ្វើសង្គ្រាម។

ក្រោយពីខ្ញុំចូលធ្វើជាកងទ័ពខ្ញុំត្រូវបែកឆ្ងាយពីឪពុក ម្តាយ និងបងប្អូនរហូតដោយគ្មានដំណឹងពីគ្នាទាល់តែសោះ។ ខ្ញុំបន្តវាយនៅភ្នំឧដុង្គឆ្ពោះទៅគោលដៅវត្តឃ្មុញ អស់រយៈពេលមួយឆ្នាំជាងទើបអាចវាយចូលក្នុងទីក្រុងភ្នំពេញ។ បន្ទាប់ពីវាយចូលទីក្រុងភ្នំពេញប្រជាជនដែលរស់នៅទីនោះរៀបចំអីវ៉ាន់ចេញពីភ្នំពេញ។ ខណៈពេលនោះ ខ្ញុំឃើញទិដ្ឋភាពប្រជាជនបណ្តើរគ្នាមានកូន ចៅ ប្រពន្ធប្តីស្តាយរបស់របរប្រើប្រាស់ដើរតាមផ្លូវឆ្ពោះទៅទីជនបទៗ អស់រយៈពេលមួយសប្តាហ៍ប្រជាជនជម្លៀស

ចេញពីភ្នំពេញអស់ ខ្ញុំរួមទាំងកងទ័ពជាច្រើននាក់ទៀតបន្តរស់នៅទីក្រុងភ្នំពេញអស់រយៈពេល៣ឆ្នាំ។ កាលណោះ ខ្ញុំនៅក្នុងកង៩២០។ រស់នៅភ្នំពេញ ការងារដែលខ្ញុំធ្វើគឺខាងចុងភៅ ដាំបាយឲ្យកងទ័ព។ ជីវភាពប្រចាំថ្ងៃរបស់កងទ័ពជិទង់ៗដូចជាខ្ញុំ ពេលព្រឹកឡើងក្រោកហាត់ប្រាណ ដល់ថ្ងៃត្រង់ហូបបាយហើយសម្រាក រហូតដល់ល្ងាចហូបបាយហើយសម្រាកបន្តទៀត។ ចំណែកកងទ័ពធំៗ បន្ទាប់ពីហាត់ប្រាណហើយ បន្តទៅហ្វឹកហាត់បន្ថែមទៀត។ ការហូបចុកខ្ញុំទទួលរបបគ្រប់គ្រាន់មិនមានការខ្វះខាតអ្វីទេ។

នៅឆ្នាំ១៩៧៨ អង្គភាពខ្ញុំត្រូវបញ្ជូនទៅខេត្តក្រចេះ។ ពេលទៅដល់ទីនោះកងទ័ពត្រូវធ្វើស្រែដាំដំណាំ រកត្រី សត្វ ផ្គត់ផ្គង់ជីវភាពខ្លួនឯង។ ខ្ញុំនៅទន្លេស្រែពក បានមួយរយៈអង្គការបញ្ជូនទៅខាងកោះញែកវិញ។ ពេលទៅដល់កោះញែក មានផ្ទះប្រជាជនរស់នៅច្រើនជាងខាងទន្លេស្រែពក។ ខ្ញុំនៅកោះញែក រហូតដល់ឆ្នាំ១៩៧៩ វៀតណាមវាយចូលមកដល់ អង្គភាពខ្ញុំរត់ចូលទៅក្នុងព្រៃចាស់។ បន្ទាប់ពីរស់នៅក្នុងព្រៃចាស់បានមួយរយៈ ប្រធានកងពលប្រមូលកម្លាំងឡើងទៅភ្នំដងរែក។ ការធ្វើដំណើរអស់រយៈពេល១ខែទើបទៅដល់ព្រំដែនថៃ។ ខ្ញុំបន្តរស់នៅលើភ្នំដងរែករហូតដល់មានការផ្សះផ្សាររវាងកងទ័ពខ្មែរក្រហម និងកងទ័ពរាជរដ្ឋាភិបាល ទើបខ្ញុំចុះមកនៅក្នុងស្រុកត្រពាំងប្រាសាទរហូតដល់បច្ចុប្បន្ន។



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កំពុងបើកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) បង្ហាញទៅ ឯក តាប់ បន្ទាប់ពីវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញ៉ាណ ញ៉ក់ ៖ កងចល័ត

## សួត វិចិត្រ




ញ៉ាណ ញ៉ក់ ចង្អុលរូបប្រជាជនលើកទំនប់ក្នុងរបបខ្មែរក្រហមប្រាប់ សួត វិចិត្រ បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ញ៉ាណ ញ៉ក់ ភេទប្រុស អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិកោះគល់ ឃុំកោះមិត្ត (ឬកោះរការ) ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បច្ចុប្បន្ន ញ៉ក់ រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ញ៉ក់បានចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមថា នៅមុនឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានបម្រើការជាទាហាន លន់ នល់ ដូច្នេះម្ដាយរបស់ខ្ញុំបានសម្រេចចិត្តចាកចេញពីភូមិកំណើតរួចនាំកូនៗទៅរស់នៅជាមួយប្ដីនៅឯទីរួមខេត្តកំពង់ចាម។ នៅទីនោះ ខ្ញុំបានបន្តការសិក្សារហូតដល់យោធាខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ភ្លាមៗនោះ យោធាខ្មែរក្រហមបានចាប់ឪពុករបស់ខ្ញុំយកទៅសម្លាប់ចោល ហើយបញ្ជូនក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនដែលរស់នៅក្នុងទីរួមខេត្តទាំងអស់ ទៅកាន់ស្រុកកំពង់សៀម។

នៅអំឡុងពេលនោះ ខ្មែរក្រហមបានចាត់ឲ្យខ្ញុំទៅលើកទំនប់នៅតាមការដ្ឋានផ្សេង និងបានចាត់ទុកគ្រួសារខ្ញុំគឺជា «ប្រជាជនថ្មី ឬ ប្រជាជន១៧ មេសា»។ យើងបានរស់នៅ និងធ្វើការដោយស្ថិតនៅក្រោមការឃ្លាំមើលពីឈ្លប និងមិនទទួលបានភាពស្មើគ្នាដូចនឹងប្រជាជនមូលដ្ឋានឡើយ។ ខ្មែរក្រហមបានបែងចែកប្រជាជនមូលដ្ឋានរស់នៅដោយឡែកពីប្រជាជនថ្មី ឬ ប្រជាជន១៧ មេសា ហើយប្រជាជនថ្មីច្រើនណាស់តែងតែបាត់ខ្លួនជារឿយៗបន្ទាប់ពីរស់នៅក្នុងភូមិបានមួយរយៈ។

ខ្ញុំបានធ្វើការងារលើកទំនប់ ដែលមានឈ្មោះថា «ទំនប់កែប្រែ» ដែលមានកម្ពស់១៨ម៉ែត្រ។ ក្នុងមួយថ្ងៃ ប្រជាជនម្នាក់ៗត្រូវរែកដីឲ្យបានបីម៉ែត្រគុប ហើយនៅពេលដែលទំនប់កាន់តែមានកម្ពស់ខ្ពស់ យើងត្រូវរែកដីឆ្អែលឡើងលើកាន់តែឆ្ងាយដែលយ៉ាងហោចណាស់មានចម្ងាយប្រហែលកន្លះគីឡូម៉ែត្រ ទម្រាំដល់ខ្នងទំនប់។ ការរស់នៅ និងធ្វើការងារនៅពេលនោះ ខ្ញុំជួបការលំបាក ដោយសារត្រូវធ្វើការងារហួសកម្លាំង ការហូបចុកមិនគ្រប់គ្រាន់ និងខ្វះអនាម័យ។ ខ្ញុំតែងតែក្បង់ទឹកអូរ ទឹកថ្លុក និងទឹកដែលដក់នៅតាមស្នាមភ្លោះយកមកផឹកនៅពេលដែលស្រេកទឹកខ្លាំង។ ប្រជាជនភាគច្រើនកើតជំងឺហើម ដោយសារខ្វះជីវជាតិ ហើយខ្មែរក្រហមបានឲ្យប្រជាជនដែលមានជំងឺទាំងនោះហូបនំលូ ដើម្បីព្យាបាលជំងឺ។



ញ៉ាណ ញ៉ក់ អាយុ៦១ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ុល ឈួន ៖ នីរសារ

**ហ៊ាន ពិសី**



ម៉ុល ឈួន ចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ុល ឈួន ភេទប្រុស អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បច្ចុប្បន្នម៉ុល ឈួនរស់នៅភូមិប្រោក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ម៉ុល ឈួន និយាយថា៖ « សង្គ្រាមធ្វើឲ្យខ្ញុំមិនបានរៀនសូត្រ។ ដោយសារពេលនោះមានការធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ឲ្យចុះចេញពីតំណែង ជាហេតុធ្វើឲ្យប្រជាជនខ្មែរជាច្រើនដែលគាំទ្រនិងស្រឡាញ់ព្រះអង្គ បានចូលរួមតស៊ូក្នុងព្រៃម៉ាគី តាមរយៈការឃោសនារបស់សម្តេច។ នៅអាយុ១៨ឆ្នាំខ្ញុំចូលហាត់ធ្វើជាកងទ័ពនៅកំពង់ថ្ម និងនៅជិតប្រាសាទសម្បូរព្រៃគុក។ ប្រហែលពីរខែក្រោយមកខ្ញុំត្រូវបានបញ្ជូនទៅខ្សែត្រៀមដើម្បីត្រៀមប្រយុទ្ធ។ ឆ្នាំ១៩៧៥ ខ្មែរក្រហមវាយដាច់ភ្នំពេញ ខ្ញុំមកធ្វើជានីរសារឲ្យ តាប្រាន។ តាប្រាន មានតួនាទីជាគណៈស្រុក មកពីភូមិភាគនិរតី។ ការងាររបស់ខ្ញុំនៅពេលនោះគឺធ្វើជាអ្នករត់សំបុត្រ ដោយជិះសេះ និងមានកាំភ្លើងមួយដើមសម្រាប់ការពារខ្លួន។ ខ្ញុំមិនដែលដឹងអំពីខ្លឹមសារនៅខាងក្នុងសំបុត្រទេ ដោយសារមានការវេចខ្ចប់ស្រោមសំបុត្រយ៉ាងជិតល្អ។ ពេលទំនេរពីការរត់សំបុត្រ ខ្ញុំធ្វើជាអ្នកដឹកស្បៀងអង្ករពីឃ្លាំងនៅក្នុងស្រុកដាក់តាមសហករណ៍។ យើងមានក្រុមដឹកជញ្ជូនតាមរទេះសេះ ហើយមួយសហករណ៍

ទទួលបានអង្ករ១០បាវ។ ការរស់នៅជាមួយ តា ប្រាន យើងទទួលបានបាយ ហូបគ្រាប់គ្រាន់មិនដែល ហូបបបរទេ។

នៅឆ្នាំ១៩៧៦ ខ្ញុំចូលធ្វើទ័ពហើយខ្ញុំត្រូវបាន ខ្មែរក្រហមបញ្ជូនឲ្យទៅឈរជើងនៅខាងភូមិភាគបូព៌ាក្នុងស្រុកមេមត់ ដែលមាន សុខ សារឿន គឺជាប្រធាន។ ការរស់នៅទីនោះ ភាគច្រើនខ្ញុំមិនសូវបានចូលវាយនៅសមរភូមិមុខទេ ខ្ញុំច្រើនតែធ្វើជាអ្នកយកបាយឲ្យកងទ័ពដែលកំពុងប្រយុទ្ធនៅសមរភូមិមុខ។ យើងអាចជញ្ជូនបាយទៅឲ្យកងទ័ពបានតែពេលយប់ប៉ុណ្ណោះ ទើបសត្រូវមើលយើងមិនឃើញ។ បាយនៅជំនាន់សង្គ្រាមខុសពីបាយធម្មតា។ ដោយសារបាយដែលត្រូវយកទៅឲ្យកងទ័ពនៅតាមលេណដ្ឋាន គឺត្រូវកិនបាយនោះឲ្យស្អិតរមួតចូលគ្នា។ ក្នុងមួយកញ្ចប់មានទាំងបាយ និងម្ហូប រួមជាមួយ ទឹកដាក់ក្នុងបំពង់ដេកា ដែលអាចហូបបានបីនាក់និងពីរពេលសម្រាប់ពេលយប់និងព្រឹក។ នៅក្នុងចន្លោះចុងឆ្នាំ១៩៧៦ មានការបាត់ខ្លួនច្រើនជាពិសេសកម្មាភិបាលថ្នាក់លើ។ ឲ្យតែមានការកោះហៅប្រជុំ គឺដឹងតែបាត់ខ្លួនដោយគ្មានមូលហេតុ។ បន្ទាប់មកជំនួសដោយកម្មាភិបាលភូមិភាគនិរតី៨០១ មកដឹកនាំបន្ត។ ខ្ញុំនៅតស៊ូរហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមកយើងក៏បែកខ្ញែកគ្នា។ ខ្ញុំភៀសខ្លួនមកខាងភ្នំឱរ៉ាល់ ក្រោយមកចល័តរហូតមកដល់ស្រុកត្រពាំងប្រាសាទ។ មកដល់ត្រពាំងប្រាសាទខេត្តឧត្តរមានជ័យបានមួយសប្តាហ៍ យើងគ្មានអីហូបក្រៅពីគល់ចេក និងគល់ល្ហុង។ ក្រោយមក តាម៉ុក បញ្ជូនឲ្យខ្ញុំនិងកងកម្លាំងផ្សេងទៀតឡើងមកភ្នំដងរែក។ យើងធ្វើដំណើរមកដល់ច្រកណាំយឺនប្រទេសថៃ ហើយក៏រស់នៅទីនោះ។ គ្រាន់តែមកដល់ច្រកណាំយឺន ថៃដកកាំភ្លើងគ្រប់គ្នា។ ពីរថ្ងៃបន្ទាប់ខ្ញុំឃើញ ឡានដឹកស្បៀង ដែលមានអង្ករដំណើប និងប៊ីចេងយកមកឲ្យយើងហូប។ លុះឆ្នាំ១៩៨២ តាម៉ុកឲ្យយើងទៅនៅជាមួយ តាពក នៅ១០០១ ដែលមានកម្លាំងចំនួន១៥០០នាក់។ ប៉ុន្តែដោយសារកងទ័ពមួយចំនួនធំមានប្រពន្ធកូន ដូច្នេះ នាំគ្នារត់ចូលទៅធ្វើកងទ័ពប៉ារ៉ាអស់ចំនួន៥០០នាក់។ ក្រោយមកខ្មែរក្រហមដកខ្ញុំឲ្យរៀនគូលេខនៅ១០០៣។ ការរៀនគូលេខគឺ ខ្មែរក្រហមយកលេខជំនួសដោយអក្សរ ប្រើលេខសម្រាប់សរសេរសារ។ ដូច្នេះការបញ្ជូនសារមួយគឺសម្ងាត់ណាស់ ប្រសិនបើអង្គការគិតថារឿងសម្ងាត់បែកធ្លាយគឺមានតែអ្នកបកសារគូលេខហ្នឹងឯងគឺជាអ្នកក្បត់។ មិនយូរប៉ុន្មានខ្ញុំត្រូវដកឲ្យធ្វើនៅកងកម្លាំង៩១៦ បានប៉ុន្មានថ្ងៃក៏វិលត្រឡប់មករៀនគូលេខម្តងទៀត។ យូរៗទៅខ្ញុំហត់នឿយនឹងការរៀនគូលេខ ខ្ញុំក៏សុំប្តូរមកកាន់កាំភ្លើងចូលសមរភូមិវិញ។ ដល់ឆ្នាំ១៩៨៨ ខ្ញុំរៀបការប្រពន្ធ និងមានកូន។

នៅឆ្នាំ១៩៧៩ ប៉ុល ពត រៀបចំបង្កើតគណៈកម្មាធិការ១៩ថ្មី។ ដោយមេដឹកនាំចាស់ៗ ដូចជា ប៉ុល ពត, តាម៉ុក, ខៀវ សំផន, ដែលចូលនិវត្តន៍ជំនួសដោយអ្នកជំនាន់ថ្មីដូចជា តា សាន តា សារឿន តាឌុន តាញាន។ ការរៀបចំនេះត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត។ លទ្ធផលសន្លឹកឆ្នោត តា សាន ទទួលបានសំឡេងច្រើនជាងគេ។ ប៉ុន្តែ តា សាន មិនព្រមធ្វើក៏ផ្ទេរឲ្យទៅតា សារឿន ឡើងធ្វើជាអគ្គមេបញ្ជាការនៅក្នុងតំបន់អន្លង់វែង ជំនួសដោយសារតា សារឿនធ្លាប់ជាមេរបស់តា សាន។ ប៉ុន្តែ តាម៉ុក ចង់ឲ្យ តាឌុន គឺជាមនុស្សជំនិតឡើងគ្រប់គ្រងវិញ។ កាលនោះ ប៉ុល ពត គិតថាបើ តាម៉ុក ទៅចាប់កម្លាំងខាងប៉ៃលិនដែលបម្រុងផ្តាច់ខ្លួនបាន នោះ ប៉ុល ពត នឹងធ្វើតាមអ្វីដែល តាម៉ុក ចង់ឲ្យ តាឌុន ឡើងជាអ្នកដឹកនាំបន្ត។ ប៉ុន្តែ តាម៉ុក ពុំអាចយកឈ្នះកម្លាំងនៅប៉ៃលិន ហើយថែមទាំងត្រូវកម្លាំងខាងប៉ៃលិនដេញ តាម៉ុក រត់ត្រឡប់មកវិញទៀត។ ក្នុងអំឡុងពេលនោះ ប៉ុល ពត ចង់ជ្រើសរើស សុន សេន ឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រី ដែលជាមូលហេតុធ្វើឲ្យ តា សារឿន និង សុន សេន មានទំនាស់ជាមួយនឹងគ្នា។ ក្រោយមក ប៉ុល ពត ហាក់គិតមិនដល់ ក៏បញ្ជូនឲ្យ តា សារឿន ឡើងមកយក សុន សេន ឲ្យមកនៅជាមួយ។ ប៉ុន្តែ តា សារឿន ពុំបាននាំ សុន សេន មកទេ តែបែរជាទៅបាញ់សម្លាប់ សុន សេន និងគ្រួសារស្លាប់អស់ទៀត។ ទាំងនេះខ្ញុំគិតថាជាការដណ្តើមអំណាចគ្នាទើបធ្វើឲ្យខាងក្នុងមានការបែកបាក់គ្នា។ លុះឆ្នាំ១៩៩៨ ខ្ញុំហាក់នឿយណាយនឹងសង្គ្រាម ខ្ញុំក៏សម្រេចចិត្តផ្តាច់ខ្លួនតាំងពីពេលនោះមក»។

# គុន ឈិន ៖ អតីតយោធា

**ហេក ខិន**



គុន ឈិន ចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គុន ឈិន អាយុ៦២ឆ្នាំ កើតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ គុន ឈិន និយាយរៀបរាប់អំពីការតស៊ូរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមថា ខ្ញុំរស់នៅក្នុងគ្រួសារដែលមានជីវភាពខ្វះខាត ព្រោះឪពុកម្តាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការសម្រាប់ទ្រទ្រង់ជីវិត។ កាលពីក្មេងខ្ញុំមិនបានរៀនសូត្រទេ។ ការរស់នៅរបស់ប្រជាជនក្នុងភូមិ ប្រកបដោយសុខសន្តិភាព។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំនៅវ័យកុមារនៅឡើយ មិនទាន់ដឹងរឿងរ៉ាវប្រទេសជាតិច្បាស់លាស់ទេ។ ខ្ញុំគ្រាន់តែដឹងថា ជំនាន់នោះ សម្តេចព្រះ នរោត្តម សីហនុ តែងតែជិះយន្តហោះមកទម្លាក់ក្រណាត់នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។ រហូតដល់ចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ នៅក្នុងភូមិខ្ញុំចាប់ផ្តើមមានការទម្លាក់គ្រាប់បែកធ្វើឲ្យប្រជាជនបាត់បង់ទ្រព្យសម្បត្តិ និងខូចខាតសម្ភារអស់ជាច្រើន។ នៅចុងឆ្នាំ១៩៧៣ ខ្ញុំចូលធ្វើជាកងទ័ព។ កាលខ្ញុំចូលជាកងទ័ពខ្ញុំមានអាយុ១៥ឆ្នាំ ដោយសារតែខ្ញុំនៅតូចពេក អង្គការមិនសូវបង្ហាត់បង្រៀនច្រើនដូចគេធំៗទេ អង្គការបង្ហាត់បន្តិចបន្តួចពីរបៀបធ្វើសង្គ្រាម។ បន្ទាប់ពីខ្ញុំបានហាត់រៀនមួយរយៈ ហើយខ្ញុំក៏ត្រូវបានបញ្ជូនឲ្យទៅវាយនៅសមរភូមិមុខ។ កងទ័ពខ្ញុំវាយឆ្ពោះចូលទៅទីក្រុងភ្នំពេញ ការវាយជាមួយកងទ័ព លន់ នល់ បានធ្វើឲ្យកងទ័ពជាច្រើនត្រូវស្លាប់ក្រោមភ្លើងសង្គ្រាម។ ខ្ញុំបន្តវាយទៅមុខរហូតដល់វាយបែកភ្នំពេញនៅឆ្នាំ១៩៧៥ កងទ័ពទាំងអស់មានចិត្តសប្បាយរីករាយជាខ្លាំងពេលទទួលជ័យជម្នះ។ បន្ទាប់ពីទទួលជ័យជម្នះ ខ្ញុំបន្តឈរជើងនៅភ្នំពេញរយៈពេលកន្លះខែទើបខាងថ្នាក់លើបញ្ជូនកងពលខ្ញុំ៩២០ និងកងពល៨០១ ទៅខេត្តក្រចេះ។ ការធ្វើដំណើរទៅកាន់ខេត្តក្រចេះកងទ័ពទាំងអស់ត្រូវធ្វើដំណើរដោយជិះកាណូត។ កងទ័ពទាំងអស់ធ្វើដំណើរអស់រយៈពេលមួយថ្ងៃមួយយប់ទើបទៅដល់ខេត្តក្រចេះ។ បន្ទាប់ពីទៅដល់ទីនោះហើយ កងទ័ពបន្តដំណើរទៅខេត្តមណ្ឌលគិរី។ កាលខ្ញុំឈរជើងនៅមណ្ឌលគិរី អង្គការចាត់តាំងខ្ញុំរួមទាំងកងទ័ពទាំងអស់ធ្វើស្រែចម្ការប្រមូលផលទុកសម្រាប់ទ្រទ្រង់ជីវភាពកងទ័ពដោយខ្លួនឯង និងនៅការពារព្រំដែន។

ខ្ញុំរស់នៅខេត្តមណ្ឌលគិរី រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់ ទើបកងទ័ពខ្មែរក្រហមទាំងអស់ បានរត់ចូលព្រៃទាំងគ្មានស្បៀងអាហារ។ កងទ័ពខ្ញុំបានរស់នៅក្នុងព្រៃរង់ចាំអង្គការទាក់ទងមកអស់មួយរយៈពេល ទើបដឹងដំណឹងថា អង្គការទាំងអស់បានទៅរស់នៅលើភ្នំដងរែក។ បន្ទាប់ពីមានការទំនាក់ទំនងគ្នាបានហើយ ខ្ញុំនិងកងទ័ពដទៃទៀត ធ្វើដំណើរឆ្ពោះទៅកាន់ភ្នំដងរែក។ ពេលធ្វើដំណើរមកដល់ភ្នំដងរែកកងទ័ពទាំងអស់ចាប់ផ្តើមមានអាហារហូបចុកគ្រប់គ្រាន់ លែងមានការខ្វះខាតអាហារដូចពេលរស់នៅក្នុងព្រៃទៀតហើយ។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិប្រោក ឃុំផ្អាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។



ប្រជាកសិករនៅស្រុកត្រពាំងប្រាសាទ កំពុងហាលដំឡូងមី។
(បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វ៉ៃ ឈុនៈ សមាជិកគណៈស្រុកចំការលើ

ហ៊ាន ពិសី



វ៉ៃ ឈុន នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ខែសីហា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ វ៉ៃ ឈុន ភេទប្រុស អាយុ៨០ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកស្ទោង ខេត្តកំពង់ធំ។ បច្ចុប្បន្នខ្ញុំរស់នៅ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ឆ្នាំ១៩៧០ ខ្ញុំចូលតស៊ូនៅក្នុងព្រៃតាមការប្រកាសរបស់សម្ដេច ព្រះនរោត្តម សីហនុ។ ចូលតស៊ូរហូតដល់បានជ័យជម្នះនៅឆ្នាំ១៩៧៥ ខ្ញុំរត់ទៅផ្ទះប៉ុន្តែត្រូវចាប់ឲ្យមកវិញធ្វើជាអ្នកដឹកដែកនៅក្នុងសហករណ៍ដល់ឆ្នាំ១៩៧៦។ ក្រោយមក កែ ពក គឺជាគណៈភូមិភាគឧត្តរយកខ្ញុំឲ្យទៅជួយមើលប្រពន្ធគាត់ដែលទើបសម្រាលកូន។ ឆ្នាំ១៩៧៧ កែ ពក ឲ្យខ្ញុំចូលធ្វើជាសមាជិកគណៈស្រុកចំការលើដោយខ្ញុំទទួលតួនាទីជាអ្នកស្រង់ស្ថិតិប្រជាជន។ កាលណោះពិបាកណាស់ មិនថាចំនួនប្រជាជន ផ្ទះ សម្បែង ដីធ្លី សម្ភារ សត្វពាហនៈតូចធំនិងអ្វី ផ្សេងទៀតគឺត្រូវធ្វើស្ថិតិទាំងអស់គ្មានសល់។ ពេលមួយ នួន ជា បានហៅគណៈស្រុកទាំងអស់មកប្រជុំនៅពហុកីឡដ្ឋាននៅភ្នំពេញ។ ខ្ញុំបានជួបមុខ នួន ជា ជាលើកទីមួយគាត់មុខកាចណាស់។ ពេលនោះ នួន ជា ចាប់ផ្ដើមនិយាយអំពីផែនការឲ្យគណៈស្រុកទាំងអស់ធ្វើយ៉ាងណាដោះស្រាយជីវភាពប្រជាជនឲ្យបាន បើមិនបានទឹងមានបញ្ហា។ ក្នុងន័យនេះគឺ ត្រូវធ្វើយ៉ាងណាឲ្យប្រជាជនហូបឲ្យគ្រប់គ្រាន់មួយថ្ងៃបីពេល និងមួយសប្ដាហ៍ឲ្យហូបបន្ថែមម្ដង។ ដើម្បីឲ្យប្រជាជនខិតខំ

ប្រឹងប្រែងធ្វើការៗ ដាក់ស្តែងគ្មាននរណាអនុវត្តបានទៅតាមផែនការទេ ភាគច្រើនការហូបចុកនៅសហករណ៍តាមភូមិមានការខ្វះខាតៗ ធ្វើការហត់ហើយឲ្យហូបតែបបររាវ ។ កាលនោះអង្គការប្រើយុទ្ធសាស្ត្រយកមិត្តឲ្យវាយមិត្តបន្តគ្នា បើនរណានិយាយត្អូញៗ ផែនការនេះមិនដឹងចេញមកពីខាងណាទេ ពុតែអង្គការចាត់តាំងមកៗ ក្រោយមកខាងភូមិភាគឧត្តរត្រូវចោទថាក្បត់ ដូច្នេះគ្មាននរណាម្នាក់រួចខ្លួន ជាពិសេសប្រធាននៅតាមតំបន់ លើកលែងតែ កែ ពក ៗ ដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយលុកមកខ្លាំង ពេលនោះខ្ញុំប្រាប់ កែ ពក ឲ្យទៅចាំនៅមាត់ស្ទឹងជីនិតមុន ចំណែកខ្ញុំទៅប្រមូលកម្លាំងពីស្រុកទៅតាមក្រោយៗ ខ្ញុំទៅប្រមូលកម្លាំងទ័ពមួយចំនួន នាំគ្នាឡើងមកជួប សុន សេន នៅ១០០១ៗ ដល់ឆ្នាំ១៩៨១ កងកម្លាំងខ្ញុំបានឡើងជាកងពលឯករាជ្យៗ ដល់ឆ្នាំ១៩៩៨ ខ្ញុំត្រូវបានបញ្ចូលទៅក្នុងកងខេមរភូមិន្ទ ហើយមកដល់ពេលនេះខ្ញុំចូលនិវត្តន៍ៗ




វ៉ៃ ឈុន ទទួលប្រអប់អនុស្សាវរីយ៍ពី ហ៊ាន ពិសី ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីខែសីហា ឆ្នាំ២០២២ៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុល អុន ៖ ប្រជាជន

***ហ៊ាន ពិសី***



យុល អុន នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យុល អុន ភេទប្រុស អាយុ៨០ឆ្នាំ មានទីកន្លែងកំណើតនៅឃុំស្វាយទាប (បច្ចុប្បន្នស្រុកស្វាយទាប) ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ការរស់នៅរបស់ប្រជាជនពីមួយជំនាន់ទៅមួយជំនាន់សុខសប្បាយអាស្រ័យលើគំនិតនៃការដឹកនាំរបស់មេដឹកនាំប្រទេសនីមួយៗ។ ឧទាហរណ៍ថា អ្នកដឹកនាំមួយគិតថាដឹកនាំបែបនេះបានល្អ ដល់មេដឹកនាំផ្សេងទៀតថាបែបនេះបានល្អ។ ដូច្នេះតាមដែលខ្ញុំធ្លាប់ឆ្លងកាត់មកឃើញថា កាលពីជំនាន់សម្តេចព្រះនរោត្តម សីហនុ សម្បូរសប្បាយមួយបែបទៅប្រជាជនមានសេរីភាពនៅក្នុងការរស់នៅ ប្រទេសជាតិអភិវឌ្ឍន៍ទៅតាមសម័យកាលហ្នឹងដែរ។ ដោយសារសម្តេច ទ្រង់ប្រកាន់យកអព្យាក្រឹត្យដើម្បីមកដឹកនាំប្រទេស។ ដល់នៅឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ចេញពីតំណែង។ លន់ នល់ ឡើងកាន់អំណាច ការរស់នៅប្រជនប្រែទៅជាលំបាក។ ប្រជាជនស្លាប់អស់ច្រើនដោយសារការទម្លាក់គ្រាប់បែក។ កាលនោះអាមេរិកបានផ្តល់ជំនួយឲ្យ លន់ នល់ នូវគ្រឿងសព្វាវុធច្រើនក្នុងការធ្វើសង្គ្រាមជាមួយខ្មែរក្រហម។ ឆ្នាំ១៩៧៥ លន់ នល់ ក៏ចាញ់ខ្មែរក្រហម។ ខ្មែរក្រហមដឹកនាំប្រទេសតាមបែបកុម្មុយនីស្ត ដឹកនាំតាមតែចិត្តនឹក

ឃើញ ច្បាប់នៅលើមាត់គឺជាអ្នកកំណត់ៗ ខ្មែរក្រហមគិតថាប្រជាជនខ្មែរទាំងអស់ត្រូវរស់នៅដោយស្មើ\ភាពគ្នាទាំងអស់ គ្មានអ្នកមាន គ្មានអ្នកក្រ ហើយអ្វីៗគ្រប់យ៉ាង គឺត្រូវរួមគ្នាក្នុងសហករណ៍តែមួយ។ ហេតុនេះហើយប្រជាជនខ្មែរត្រូវលំបាកវេទនា បែកបាក់គ្រួសារ ត្រូវធ្វើការគ្មានថ្ងៃសម្រាកហើយថែមទាំងបង្អត់បាយ នរណាហ៊ានប្រឆាំងសម្លាប់ចោលទាំងអស់ៗ លុះចូលដល់សម័យ តេជោ ហ៊ុនសែន ប្រទេសជាតិលែងមានសង្រ្គាម ប្រជាជនមានសេរីភាព ប្រទេសមានការអភិវឌ្ឍន៍ដូចសព្វថ្ងៃនេះគឺល្អណាស់សម្រាប់ខ្ញុំ។ ដូច្នេះខ្ញុំគិតថាប្រវត្តិសាស្ត្រទាំងអស់ នេះគឺជាមេរៀនមួយសម្រាប់កូនចៅជំនាន់ក្រោយគួរតែគិតពិចារណាៗ ថាតើយើងគួរធ្វើយ៉ាងណាឲ្យប្រទេសយើងមានសុខសន្តិភាព ដឹកនាំល្អ គ្មានសង្រ្គាមដូចពីសម័យកាលកន្លងមកៗ ចំពោះខ្ញុំផ្ទាល់ដើម្បីក្លាយជាអ្នកដឹកនាំដែលល្អ គឺជាអ្នកដឹកនាំដែលអាចគ្រប់គ្រងហើយប្រជាជនរស់នៅសុខសប្បាយ ប្រជាជនមានសិទ្ធិគ្រប់គ្រាន់ក្នុងការរស់នៅ រស់នៅទៅតាមសមត្ថភាពរបស់យើងរៀងៗខ្លួនៗ



ឃុល អុន កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង អំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារកាលពីខែសីហា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ែត សំអុល ៖ កម្មករលីសែងនៅក្រសួងពាណិជ្ជកម្មតំបន់

*ហ៊ាន ពិសី*



*រូបខាងឆ្វេង ៖ ម៉ែត សំអុល អាយុ៦១ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ថតរូបជុំគ្នាជាមួយក្រុមការងាររមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ម៉ែត សំអុល ភេទប្រុស អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិត្រពាំងជ្រៃ ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បច្ចុប្បន្ន អុល រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ អុល និយាយរៀបរាប់ថា ក្រោយពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមកធ្វើជាកម្មករលីសែងនៅក្នុងក្រសួងពាណិជ្ជកម្មតំបន់។ កម្មករទាំងអស់ដែលនៅទីនោះសុទ្ធតែត្រូវបានខ្មែរក្រហមចម្រាញ់យកអ្នកដែលស្អាតស្អំ មិនមានជាប់និន្នាការនយោបាយជំនាន់ចាស់។

កាលនោះខ្មែរក្រហមបានយកវត្តពាមជីកងធ្វើជាឃ្លាំងដាក់ស្បៀង និងធ្វើជាកំពង់ផែដោយសារវត្តនោះនៅជិតមាត់ទន្លេ។ ប្រធានពាណិជ្ជកម្មឈ្មោះ អូន គឺជាកម្មាភិបាលមកពីភាគនិរតី គ្រប់គ្រងសមាជិកប្រមាណ ៤០នាក់។ គ្រឿងឧបភោគទាំងអស់ត្រូវបានដឹកជញ្ជូនតាមកប៉ាល់ធំៗ ដែលខ្ញុំគិតថាដឹកមកពីក្រុងភ្នំពេញ រួមមាន អង្ករ អំបិល ប្រហុក ស្ករស និងស៊ីម៉ង់ត៍។

នៅពេលដែលកប៉ាល់មកដល់ផែ ខ្ញុំនិងកម្មករជាច្រើនត្រូវជញ្ជូនស្បៀង និងសម្ភារទាំងនោះដាក់នៅក្នុងឃ្លាំងដើម្បីរក្សាទុក និងចែកចាយទៅតាមតំបន់ឬសហករណ៍ផ្សេងៗ។ កប៉ាល់ចូលមកចតនៅផែមួយអាទិត្យពីរដង។ ក្រៅពីជញ្ជូនអង្ករចេញពីកប៉ាល់ ខ្ញុំក៏ត្រូវជញ្ជូនអង្ករចេញពីឃ្លាំងដាក់លើរថយន្ត ដែលមកចាំទទួលយកទៅដាក់នៅតាមតំបន់ផ្សេងៗ។ ចំពោះការហូបចុកវិញ ខ្ញុំបានហូបគ្រប់គ្រាន់ពុំមានខ្វះខាតឡើយ។ ប៉ុន្តែប្រជាជនដែលនៅតាមភូមិនិងសហករណ៍ដូចជាឪពុកម្តាយរបស់ខ្ញុំ គឺមិនបានហូបចុកគ្រប់គ្រាន់ទេ។ ដូច្នេះពេលទៅលេងឪពុកម្តាយនៅផ្ទះម្តង ខ្ញុំឆ្លៀតលួចយកអង្ករដែលធ្លាយចេញពីបាវយកទៅផ្ញើគ្រួសាររបស់ខ្ញុំ។ សម័យនោះ ប្រជាជនថ្មី ឬ ប្រជាជន ១៧ មេសា ត្រូវបានខ្មែរក្រហមបំបែកឲ្យរស់នៅដាច់ដោយឡែកពីប្រជាជនចាស់។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាជនថ្មីជាច្រើនត្រូវបានខ្មែរក្រហមបញ្ជូនទៅនៅភ្នំប្រុស ភ្នំស្រី ដោយខ្ញុំមិនដឹងមានរឿងអ្វីកើតឡើងទេ។ នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ខ្ញុំបានត្រឡប់មកជួបជុំគ្រួសារនៅភូមិវិញ។

# ទួន សន ៖ ប្រធានក្រុមនៅឃ្លាំងដាក់សម្ភារ ក្នុងក្រុងភ្នំពេញ

*មេក ឌិន*



ទួន សន អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទួន សន ភេទស្រី អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិបឹងបាសាក់ ឃុំសំបួរមាស ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ សព្វថ្ងៃ សនរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សនបាននិយាយរៀបរាប់ពីការចងចាំរបស់ខ្លួននៅក្នុងសម័យខ្មែរក្រហមថា នៅឆ្នាំ១៩៧២ ខ្ញុំបានសម្រេចចិត្តចូលធ្វើជាយុទ្ធនារីខ្មែរក្រហម។

កាលណោះ ក្រុមរបស់ខ្ញុំមានសមាជិកចំនួន១២នាក់សុទ្ធតែនារីៗ ខ្ញុំចូលដំបូងនៅល្ហាងគៀនស្រី បន្ទាប់មកទៀតខ្ញុំបានចូលនៅក្នុងកងពិសេសនារីវរសេនាតូចលេខ១១៤ ដែលមានយាយជុំជាអ្នកគ្រប់គ្រង។ កម្លាំងនារីសរុបមានគ្នាចំនួន៣០០នាក់ដែលជាកម្លាំងចល័តគ្រប់តំបន់ដូចជា សៀមរាប និង កំពង់ធំ។ នៅពេលដែលធ្វើដំណើរក្នុងព្រៃពេលយប់កងទ័ពមិនមានភ្លើងសម្រាប់បំភ្លឺផ្លូវទេ កងទ័ពទាំងអស់តែងតែចាប់អំពិលអំពែកតាមផ្លូវកាន់ម្នាក់មួយ ដើម្បីមានពន្លឺដើរតាមគ្នាកុំឲ្យវង្វេងបុកបែកចេញពីក្រុម។

រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេចនៅពេលដែលខ្ញុំឡើងទៅវាយនៅសមរភូមិមុខគឺនៅពេលដែលយុទ្ធនារីខ្មែរក្រហមរៀបចំខ្សែត្រៀមដើម្បីវាយកងទ័ពលន់ នល់ បានធ្វើឲ្យមិត្តភក្តិនៅក្នុងអង្គភាពរបស់ខ្ញុំស្លាប់បាត់បង់ជីវិត។ កាលណោះ ទាហាន លន់ នល់ បានចាប់បានមិត្តភក្តិរបស់ខ្ញុំម្នាក់ រួចហើយបានកាត់ក្បាលមិត្តភក្តិរបស់ខ្ញុំយកទៅដោតបង្ហាញឲ្យមហាជនមើល។ ខ្ញុំមានអារម្មណ៍សោកស្តាយ និងយល់ថាកងទ័ព លន់ នល់ មានចិត្តព្រៃផ្សៃសម្លាប់មនុស្សដូចសត្វធាតុ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានធ្វើដំណើរចូលទៅទីក្រុងភ្នំពេញ។ បន្ទាប់ពីខ្ញុំបានមកដល់ក្រុងភ្នំពេញ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងឃ្លាំងដាក់សម្ភារនៅម្តុំទួលគោក។ កាលណោះខ្ញុំធ្វើជាមេក្រុមគ្រប់គ្រងសមាជិកចំនួន១២នាក់ លើកសម្ភារនិងស្បៀងដាក់ឡានបញ្ជូនទៅតាមតំបន់ផ្សេងៗ។ នៅក្នុងឃ្លាំងដែលខ្ញុំធ្វើការមានស្បៀងនិងសម្ភារជាច្រើន ដូចជា ស្រូវ អង្ករ កៅស៊ូ ស្បែកជើងបារីក្លួយ ក្រាស់សិតសក់ និងស៊ីម៉ងត៍។ សម្ភារទាំងអស់នេះខ្ញុំឃើញមាននៅឃ្លាំងស្រាប់។ ក្នុងមួយថ្ងៃខ្ញុំរួមទាំងសមាជិកក្រុមរបស់ខ្ញុំលីសែងសម្ភារឡើងឡានចំនួន២ ឡានធំៗ ដឹកចេញទៅដាក់នៅកប៉ាល់។ ខ្ញុំបានរស់នៅ និងធ្វើការនៅក្នុងឃ្លាំងដាក់សម្ភារនៅក្នុងទីក្រុងភ្នំពេញរហូតដល់ឆ្នាំ១៩៧៩។

# ទេព ជីន ៖ កម្មករឃ្លាំងរដ្ឋ

**មេក ទិន**



ទេព ជីន អាយុ៧២ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទេព ជីន ភេទប្រុស អាយុ៧២ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិសាគ្រាម ឃុំសាគ្រាម ស្រុកស្ទោង ខេត្តកំពង់ធំ។ បច្ចុប្បន្នជីនរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ជីន បាននិយាយរៀបរាប់អំពីការចងចាំរបស់គាត់នៅសម័យខ្មែរក្រហមថា ៖

នៅឆ្នាំ១៩៧១ ខ្ញុំបានចូលធ្វើជាឈ្លបភូមិ។ មួយរយៈក្រោយមក ខ្ញុំក៏ឡើងជាឈ្លបឃុំ។ បន្ទាប់មកខ្ញុំត្រូវបានបញ្ជូនឲ្យទៅសមរភូមិខាងស្រុកកំពង់ស្វាយ។ នៅទីនោះប្រធានអង្គភាពប្រើខ្ញុំឲ្យដឹកជញ្ជូនស្បៀងឲ្យកងទ័ពនៅសមរភូមិមុខ។ ដំបូងខ្ញុំនៅក្នុងកងពលទី១ បានរយៈពេលប្រហែលជា២ខែ ក៏ត្រូវបានបញ្ជូនទៅនៅកងពលទី២វិញ។ នៅទីនោះមេបញ្ជាការបានចាត់ឲ្យខ្ញុំកាន់កាំភ្លើងធំ។ ខ្ញុំកាន់កាំភ្លើងត្បាល់៦២មីលីម៉ែត្រ រហូតដល់វាយបែកទីក្រុងភ្នំពេញ។

កងកម្លាំងនៅក្នុងអង្គភាពរបស់ខ្ញុំបានចូលប្រមូលយកទ្រព្យសម្បត្តិដែលជារបស់ជ័យភណ្ឌ។ មួយរយៈក្រោយមកប្រធានអង្គភាពបានបញ្ជូនខ្ញុំទៅនៅឃ្លាំងរដ្ឋវិញ។ ការងារដែលខ្ញុំធ្វើជាប្រចាំគឺ លីសែងអង្ករ សម្ភារផ្សេងៗ ទៅដាក់លើកប៉ាល់ទឹក។ ជំនាន់នោះ ខ្ញុំដឹងថា អង្ករដែលអង្គការប្រមូលបាន គឺដឹកបញ្ជូនទៅស្រុកចិន។

នៅក្នុងឃ្លាំងរដ្ឋបែងចែកជាច្រើនផ្នែក មានឃ្លាំងស្រូវអង្ករ ឃ្លាំងស៊ីម៉ង់ត៍ និងកៅស៊ូ។ ទោះបីយ៉ាងណាខ្ញុំរួមទាំងកម្មករនៅទីនោះ មិនហ៊ានសួរដេញដោលច្រើនទេពីព្រោះខ្លាចខ្មែរក្រហមយកទៅរៀនសូត្រ ឬយកទៅសម្លាប់ចោល។ ជាក់ស្តែង មេក្រុមរបស់ខ្ញុំត្រូវបានយោធាខ្មែរក្រហមចាប់បញ្ចូលទៅក្នុងរថយន្តដោយមិនដឹងមូលហេតុ និងបាត់ខ្លួនរហូត។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានចាប់ឲ្យរៀបការ។ កាលណោះខ្ញុំ និងប្រពន្ធខ្ញុំ មិនបានស្រឡាញ់គ្នាទេ ប៉ុន្តែដោយសារតែអង្គការរៀបចំឲ្យដូច្នេះ ខ្ញុំត្រូវបង្ខំចិត្តរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃនេះ។



ទេព ជីន ទទួលប្រអប់អនុស្សាវរីយ៍ពី ហ៊ាន ពិសី បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# តេ វិច ៖ អតីតគណៈស្រុកកោះញែក

ហ៊ាន ពិសី



រូបទីពីររាប់ពីឆ្វេង ៖ តេ វិច អាយុ៨២ឆ្នាំ គឺជាជនជាតិភាគតិចព្នង បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តេ វិច ភេទប្រុស អាយុ៨២ឆ្នាំ គឺជនជាតិភាគតិចព្នង មានទីកន្លែងកំណើតនៅភូមិរយ៉ ឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ បច្ចុប្បន្នវិចរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ វិច បានចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមថា ៖

ខ្ញុំបានចូលធ្វើជាកងជីពល តាំងពីឆ្នាំ១៩៦៣។ លុះឆ្នាំ១៩៧០ ខ្ញុំបានភៀសខ្លួនចូលទៅក្នុងព្រៃដើម្បីធ្វើកងទ័ពជាមួយខ្មែរក្រហមនៅក្នុងស្រុកកោះញែក។ នៅខាងមណ្ឌលគិរី ភាគច្រើនយើងបានប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមខាងត្បូង (ធីវគី)។ កងកម្លាំងធីវគី បានលោតឆ័ត្រយោងចុះមកមណ្ឌលគិរីច្រើនណាស់ ដូច្នេះខ្មែរក្រហមបាញ់សម្លាប់កងទ័ពទាំងនោះអស់ច្រើនដែរ។

នៅឆ្នាំ១៩៧២ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាគណៈស្រុកកោះញែក ដោយគ្រប់គ្រងផ្នែកវប្បធម៌ និងអប់រំក្មេងៗទូទាំងស្រុកកោះញែក។ ជំនាន់នោះ ប្រធាន និងសមាជិកដែលធ្វើការនៅស្រុកកោះញែកភាគច្រើនត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលដោយសារសង្ស័យថាក្បត់។ ខ្ញុំបានរួចខ្លួន ដោយសារខ្ញុំចេះបត់បែននិងសម្របខ្លួនទៅតាមខ្មែរក្រហម ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំសហករណ៍ឡើងវិញ ហើយខ្ញុំក៏ត្រូវបានជ្រើសតាំងឲ្យធ្វើជាអ្នកគ្រប់គ្រងនៅក្នុងសហករណ៍ជឿនលឿន គឺជាក្រុមដែលធ្វើការបានលឿនទីងរហ័សទៅតាមការកំណត់របស់ខ្មែរក្រហម។ សហករណ៍ជឿនលឿននេះមានសមាជិក ១០០នាក់។ ចំណែកការហូបចុកវិញខ្ញុំពុំសូវខ្វះខាតទេ។ នៅឆ្នាំ១៩៧៥ ដដែល ខ្ញុំបានរៀបការជាមួយនឹងប្រពន្ធរបស់ខ្ញុំឈ្មោះ ចន្ទថ្ងៃ។ ថ្ងៃដែលខ្ញុំរៀបការមានទាំងអស់ចំនួន១០គូ។ ខ្ញុំបានជួបប្រពន្ធខ្ញុំដោយសារតែក្រុមពេទ្យរបស់ប្រពន្ធខ្ញុំមកប្រចាំការនិងព្យាបាលប្រជាជននៅក្នុងស្រុកកោះញែក។

នៅពេលកងទ័ពវៀតណាមវាយចូលមកនៅឆ្នាំ១៩៧៩ ខ្ញុំភៀសខ្លួនទៅរស់នៅ និងតស៊ូនៅក្នុងព្រៃ។ ខ្ញុំត្រូវចល័តគ្រប់ទីកន្លែង ដោយគ្មានទីកន្លែងស្នាក់នៅពិតប្រាកដនោះទេ។ ខ្ញុំមានតែក្តួចប៉ុណ្ណោះសម្រាប់ធ្វើជាអាហារចិញ្ចឹមជីវិត។ នៅឆ្នាំ១៩៩៣ ខ្ញុំបានធ្វើដំណើរមកដល់ភ្នំដងរែកនេះ។ ក្រោយយោធាខ្មែរក្រហមធ្វើសមាហរណកម្ម ចុះចូលជាមួយរាជរដ្ឋា-ភិបាល នៅឆ្នាំ១៩៩៨ ទើបខ្ញុំចុះមករស់នៅក្នុងភូមិអូរុន។ នៅឆ្នាំ២០០២ ខ្ញុំត្រូវបានប្រជាជនគាំទ្រឲ្យឡើងធ្វើជាមេឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចំនួន៣អាណត្តិ មកដល់ឆ្នាំ២០១៧។

# ថាប់ ឈាន ៖ នីរសារ

*ស្ងួត វិចិត្រ*



ថាប់ ឈាន អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថាប់ ឈាន ភេទប្រុស អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិស្រយង់ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ។ បច្ចុប្បន្ន ឈានបានរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ឈានបាននិយាយរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួនចងចាំនៅក្នុងរបបខ្មែរក្រហមថា ៖

នៅឆ្នាំ១៩៧២ ខ្ញុំបានចងចាំថា មានជនជាតិថៃមួយក្រុមប្រដាប់ដោយកាំភ្លើងគ្រប់ដៃបានចូលទឹកដីតំបន់ប្រាសាទកោះកេរលួចយកក្បាលអ្នកតា ហើយក៏មានការបាញ់តទល់គ្នារវាងកងកម្លាំងខ្មែរក្រហមនិងក្រុមថៃនោះ។ បន្ទាប់មក ខ្ញុំរួមទាំងបងប្អូនបង្កើតទាំង៤នាក់ បានសម្រេចចិត្តចូលធ្វើជាកងទ័ពខ្មែរក្រហម។ ខ្ញុំបានចេញទៅវាយតទល់នឹងកងទ័ព លន់ នល់ នៅសមរភូមិមុខ រហូតបានទទួលជ័យជម្នះនៅទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់ពីទទួលបានជ័យជម្នះ ខ្ញុំបានត្រឡប់មកធ្វើជាកងទ័ពការពារស្រុកគូលែនវិញ។ កាលណោះ ចៅហ្វាយស្រុកគូលែនឈ្មោះ ធា។ ក្រោយពីធ្វើជាកងទ័ពការពារស្រុកគូលែន ខ្ញុំត្រូវរត់សំបុត្រពីស្រុកទៅភូមិនិងឃុំ និងទៅឲ្យមេៗ។ ពេលខ្លះខ្ញុំដើរ និងពេលខ្លះទៀតជិះសេះយកសំបុត្រទៅឲ្យភូមិនិងឃុំ ដូច្នេះខ្ញុំចេះជិះសេះចាប់តាំងពីពេលនោះមក។ ពេលទៅណាម្ដងៗខ្ញុំប្រើប្រាស់សេះជាយានជំនិះ។ រាល់ពេលដែលខ្ញុំយកសំបុត្រទៅឲ្យមេៗ ខ្ញុំតែងតែឃើញប្រជាជនធ្វើការដកស្ទូងនៅតាមវាលស្រែ។ ប្រជាជនខ្លះមានទឹកមុខស្លេកស្លាំង និងខ្លះទៀតមានរាងកាយស្គមស្គាំង។

ខ្ញុំបានធ្វើជាកងទ័ពការពារក្នុងស្រុកគូលែនរហូតដល់ឆ្នាំ១៩៧៧ ទើបកម្មាភិបាលនិងយោធាមកភូមិភាគនិរតីមកគ្រប់គ្រង និងបានចោទមេរបស់ខ្ញុំឈ្មោះ ឆើត ថាក្បត់។ បន្ទាប់មក កម្មាភិបាលនិងយោធាមកពីនិរតីទាំងនោះបានចាប់មេភូមិ គណៈឃុំ គណៈស្រុកទៅសម្លាប់ចោលបន្តទៀត។ ក្រោយពីចាប់មេៗទៅអស់ហើយ ខ្ញុំរួមទាំងកងទ័ពផ្សេងៗទៀត ត្រូវបញ្ជូនឲ្យទៅធ្វើស្រែវិញ។ កាលនោះ ការហូបចុកមិនមានការខ្វះខាតទេ ព្រោះត្រីសាច់ខ្ញុំអាចរកហូបខ្លួនឯងបាន។



រូបខាងឆ្វេង ៖ ថាប់ ឈាន ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# លៀន ចន្ទថ្លៃ ៖ អតីតពេទ្យ

ហ៊ាន ពិសី



លៀន ចន្ទថ្លៃ និងប្តីឈ្មោះ គេ វ៉ិច នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លៀន ចន្ទថ្លៃ ជនជាតិភាគតិចលាវ មានស្រុកកំណើតនៅខេត្តរតនគិរី បានរៀបរាប់ថា នៅឆ្នាំ១៩៦៨ ខ្ញុំនិងគ្រួសារនាំគ្នាភៀសខ្លួនចូលទៅក្នុងព្រៃប្រទេសវៀតណាម ហើយបានរស់នៅទីនោះ។ ក្រោយមកឪពុករបស់ខ្ញុំបានចូលធ្វើជាកងឈ្លបឲ្យវៀតណាម។ លុះដល់ឆ្នាំ១៩៧១ ខ្ញុំនិងក្រុមគ្រួសារបានត្រឡប់មករស់នៅកោះញែក ខេត្តមណ្ឌលគិរីវិញ។

នៅជំនាន់នោះខ្ញុំបានចូលហ្វឹកហាត់សិល្បៈ ហើយខ្ញុំអាចច្រៀងចម្រៀងបានបីភាសាគឺ ភាសាខ្មែរ ឡាវ និងវៀតណាម។ កាលណោះក្រុមសិល្បៈខ្ញុំក៏ត្រូវបានចាត់តាំងឲ្យទៅសម្តែងនៅក្នុងមន្ទីរ ១០០ របស់ប៉ុល ពត។ មន្ទីរ១០០នោះស្ថិតនៅក្នុងស្រុកតាវែង ខេត្តរតនគិរី។ ខ្ញុំច្រៀងដើម្បីទទួលគណៈប្រតិភូចិន និងមេដឹកនាំធំដែលប្រជុំរួមគ្នានៅទីនោះ។

រយៈពេលមួយឆ្នាំក្រោយមក ខ្មែរក្រហមជ្រើសរើសខ្ញុំឲ្យចូលរៀនពេទ្យជាមួយគ្រូពេទ្យជនជាតិចិន។ ខ្ញុំក៏រៀនពេទ្យផ្ទាល់ជាមួយ ជួន ជឿន គឺជាវេជ្ជបណ្ឌិតធំជាងគេនៅជំនាន់នោះ។ សិស្សដែលមករៀនពេទ្យមានច្រើនណាស់ ហើយមកពីគ្រប់ខេត្ត ដែលជាហេតុធ្វើឲ្យមានការខ្វះខាតផ្នែកការហូបចុក។

ខ្ញុំរៀនវិជ្ជាពេទ្យបានច្រើន ហើយក្រៅពីផ្សំថ្នាំព្យាបាល ខ្ញុំក៏អាចវះកាត់បានដែរ។ ថ្នាំសម្រាប់ព្យាបាលអ្នកជំងឺនៅជំនាន់នោះ គឺនាំចូលមកពីប្រទេសចិនទាំងអស់។ ក្រុមវះកាត់យើងកាលជំនាន់នោះមានគ្នា ៨ នាក់ គឺស្រីទាំងអស់។ កាលណោះបងថ្លៃខ្ញុំឈ្មោះ ស៊ុំ បូឡៃ គឺជាមេក្រុមវះកាត់។ អ្នកជំងឺភាគច្រើននៅពេលនោះគឺកងទ័ពដែលត្រូវរបួសនៅសមរភូមិ។ កងទ័ពខ្លះត្រូវកាត់ដៃជើង ខ្លះត្រូវវះកាត់ពោះវៀន ខ្លះទៀតវះកាត់យកអំបែងគ្រាប់បេញពីខ្លួន។ ជំងឺដែលខ្ញុំពិបាកវះកាត់ជាងគេ គឺជំងឺពោះវៀនដុះខ្នែង។

# ហ៊ាន សែន ៖ មិនដឹងថាគស៊ូកាន់កាំភ្លើងដើម្បីអ្វី

**មេក ខិន**



ហ៊ាន សែន រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ខែកញ្ញា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហ៊ាន សែន អាយុ៦០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិក្រយា ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ កាលខ្ញុំនៅកុមារ ខ្ញុំមិនបានរៀនសូត្រទេដោយសារតែស្រុកទេសកើតមានសង្គ្រាម។ នៅឆ្នាំ១៩៧២ ខ្ញុំចូលកងកុមារធ្វើការកាប់ទន្ទ្រានខេត្តធ្វើដីជញ្ជូនដីដំបូកកើបអាចម៍គោដាក់ស្រែ។ ដល់រដូវធ្វើស្រែអង្គការឲ្យរទេះគោមកខ្ញុំ និងក្មេងៗដទៃទៀតដឹកដីយកទៅបាចនៅស្រែ។ ក្រៅពីការងារធ្វើស្រែ ធ្វើដី ខ្ញុំត្រូវបញ្ជូនឲ្យទៅលើកទំនប់ ជីកប្រឡាយ។ ក្នុងមួយថ្ងៃខ្ញុំទទួលបានបបរចំនួនពីរពេល។ ខ្ញុំធ្វើការនៅក្នុងកងកុមាររហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលមកដល់សហករណ៍ក្នុងភូមិ ដូច្នេះកងខ្ញុំត្រូវបានរំសាយចោលចាប់តាំងពីពេលនោះមក។

បន្ទាប់ពីរំសាយសហករណ៍ខ្ញុំត្រឡប់ទៅរស់នៅក្នុងភូមិកំណើតវិញ។ ខ្ញុំមករស់នៅផ្ទះធ្វើស្រែបានមួយរយៈ កងទ័ពវៀតណាមសង្ស័យខ្ញុំដោយចោទថាជាខ្សែរយៈរបស់ខ្មែរក្រហម។ ខ្ញុំក៏រត់គេចខ្លួនទៅដេកនៅក្នុងព្រៃ និងរត់ទៅរស់នៅភូមិឆ្ងាយៗរហូតបានជួបជាមួយខ្មែរក្រហមដែលចូលភូមិមករកទិញអង្ករពីប្រជាជន។ ខ្ញុំក៏សម្រេចចិត្តចូលមកខាងខ្មែរក្រហមតែម្តង។ នៅឆ្នាំ១៩៨២ ខ្ញុំមកដល់លើភ្នំដងរែក។ កាលណោះ ខ្ញុំមកនៅជាមួយបងមុំ គឺជាប្រធានកងវរសេនាតូចដែលត្រូវទៅគ្រប់គ្រងទ័ពនៅខេត្តកំពង់ធំ។ ខ្ញុំចូលទ័ពបានរយៈពេល៣ឆ្នាំខ្មែរក្រហមក៏ហៅខ្ញុំទៅហ្វឹកហាត់ក្បួនកងទ័ពនៅអូរទឹកខៀវបន្ថែម។ កងទ័ពខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ តាញ៉ែន។

កាលនៅជាកងទ័ពខ្ញុំមានការលំបាក និងជួបឧបសគ្គច្រើនណាស់ ពេលខ្លះដាច់ស្បៀង ឯពេលខ្លះទៀតវាយប្រយុទ្ធគ្នាជាប់២-៣ថ្ងៃដាច់បាយដាច់ទឹកក៏មាន។ ខ្ញុំនៅជាកងទ័ពចេញទៅវាយជាមួយកងទ័ពវៀតណាមរហូតដល់ឆ្នាំ១៩៩៣ ទើបខ្ញុំបានឡើងជាប្រធានកងវរសេនាតូច ប៉ុន្តែនៅក្រោមការគ្រប់គ្រងរបស់តាញ៉ែនដដែល។ នៅឆ្នាំ១៩៩៦ ខ្ញុំរៀបការ។ បន្ទាប់ពីខ្ញុំមានគ្រួសារហើយខ្ញុំមករស់នៅក្នុងភូមិបុស្ស ដាំដំណាំ ចិញ្ចឹមសត្វ បង្កបង្កើនផលនៅផ្ទះ។ ក្រោយមកទៀតខ្ញុំដើរតាម តាតែម គឺជាអ្នកគ្រប់គ្រងនៅឃ្លាំងស្បៀង បើកអង្ករបើកសម្ភារឲ្យប្រជាជន។ ខ្ញុំបានឈប់ធ្វើទាហានតាំងពីឆ្នាំធ្វើសមាហរណកម្មផ្សះផ្សាគ្នារវាងកងទ័ពរាជរដ្ឋាភិបាលនិងកងទ័ពខ្មែរក្រហមនៅស្រុកអន្លង់វែង។

# វេទិកាសហគមន៍នៅក្នុងភូមិទួលប្រាសាទ

*ហ៊ាន ពិសី*



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាសហគមន៍នៅក្នុងភូមិទួលប្រាសាទ នៃស្រុកអន្លង់វែង ដោយផ្តោតទៅលើ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាសហគមន៍មួយនៅក្នុងភូមិទួលប្រាសាទ នៃស្រុកអន្លង់វែង ដោយផ្តោតទៅលើ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»។ វេទិកាសហគមន៍នេះត្រូវបានធ្វើឡើងនៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសាលាឆទានមួយនៃភូមិទួលប្រាសាទ ដោយមានការចូលរួមពីប្រជាជនចំនួន២៧ នាក់ រាប់បញ្ចូលទាំងកុមារ ដែលមានស្រី ១៥នាក់ និងប្រុស១៣នាក់។ ភូមិទួលប្រាសាទនេះត្រូវបានស្គាល់ថាជាភូមិចំណាស់មួយ ស្ថិតនៅក្នុងស្រុកអន្លង់វែង ដែលមានប្រជាជនរស់នៅសរុបចំនួន ៨៨គ្រួសារ។ ភាគច្រើនប្រជាជននៅទីនោះរស់នៅពឹងផ្អែកទៅលើរបរកសិកម្ម និងការធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។

បណ្ឌិត លី សុខឃាង ដែលជាអ្នកដឹកនាំនៅក្នុងការពិភាក្សានេះបានលើកយកនូវរឿងរ៉ាវទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ ក្រោយពេលដែលទទួលបានជ័យជម្នះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងទៅកាន់ទីជនបទ។ ក្នុងការដឹកនាំបែបផ្តាច់ការនៃ

របបនេះ បានធ្វើឲ្យប្រជាជនខ្មែរជាង២លាននាក់ត្រូវបានស្លាប់ ដោយសារការធ្វើទារុណកម្ម ការធ្វើការងារដោយបង្ខំ និងការបង្អត់អាហារ។ បន្ទាប់ពីរបបនេះ ត្រូវបានដួលរលំ អ្នកស្រាវជ្រាវបានរកឃើញថា មានរណ្តៅសាកសពជិត២ម៉ឺនរណ្តៅ នៅទូទាំងប្រទេសកម្ពុជាដែលសេសសល់ក្រោយសម័យសង្គ្រាម។ ដំណើរការនៃការស្វែងរកយុត្តិធម៌ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថា អ.វ.ត.ក បានធ្វើការកាត់ក្តីទៅលើមេដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិតេយ្យនេះ ដោយបែងចែកជាសំណុំរឿង០០១, ០០២, ០០៣ និង០០៤។ នៅខែកញ្ញា ឆ្នាំ២០២២ ដំណើរការនៃការស្វែងរកយុត្តិធម៌នេះក៏ត្រូវបានបិទបញ្ចប់ជាស្ថាពរ បន្ទាប់ពីតុលាការធ្វើការកាត់ទោសឲ្យ ខៀវ សំផន ដែលជាអតីតមេដឹកនាំខ្មែរក្រហមតែម្នាក់គត់ដែលនៅរស់ឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ក្នុងអំឡុងពេលនៃការធ្វើបទបង្ហាញនេះ សង្កេតឃើញថាប្រជាជនមួយចំនួននៅក្នុងភូមិស្គាល់ឈ្មោះមេដឹកនាំខ្មែរក្រហមយ៉ាងច្បាស់ដូចជាប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី និងមេដឹកនាំផ្សេងទៀត។

តាមរយៈការពិភាក្សាអំពីកេរដំណែលនៃតុលាការខ្មែរក្រហម បានបង្ហាញឲ្យឃើញថា ភាពស្មើគ្នាចំពោះមុខច្បាប់គឺមានសារសំខាន់ណាស់សម្រាប់ប្រជាជនគ្រប់រូប។ មិនតែប៉ុណ្ណោះ វេទិកានេះក៏បានផ្តល់ឱកាសឲ្យប្រជាជនធ្វើការចែករំលែកអំពីបទពិសោធជីវិតដែលខ្លួនធ្លាប់បានឆ្លងកាត់នៅក្នុងសម័យសង្គ្រាម រួមទាំងការជជែកពីបញ្ហាផ្សេងៗដែលប្រឈមនៅក្នុងសហគមន៍។ ប្រជាជនក៏បានលើកយកបញ្ហាប្រឈមចម្បងបំផុតចំពោះភូមិទួលប្រាសាទគឺ ស្ពានផ្លូវដែលជារៀងរាល់ឆ្នាំត្រូវបានជន់លិច និងខូចខាតដោយសារកម្លាំងទឹកហូរនាពេលរដូវវស្សា។ បញ្ហានេះបានធ្វើឲ្យប្រជាជនមានការលំបាក ជាពិសេសកុមារមិនអាចធ្វើដំណើរទៅរៀនបាន។ ក្នុងនោះប្រជាជនក៏បានលើកយកអំពីវិធីក្នុងការដឹកចម្លងអ្នកជំងឺឆ្លងទឹកតាមបែបបុរាណ ដែលខ្លួនធ្លាប់បានអនុវត្តនៅក្នុងអំឡុងពេលមានសង្គ្រាម។ ប្រជាជនបានយកតង់កៅស៊ូចងក្រប្ងួចទាំងសងខាងឲ្យមានរាងដូចជាទូក រួចយកស្លឹកឈើដាក់នៅក្នុងតង់កៅស៊ូនោះ ហើយឲ្យអ្នកជំងឺដេកនៅពីលើ។ បន្ទាប់មកត្រូវសែងតង់កៅស៊ូដែលមានមនុស្សដេកនោះ ទៅដាក់បណ្តែតលើទឹកដោយមានអ្នកហែលទប់នៅត្រង់កន្លែងចងក្រប្ងួចទាំងសងខាងនោះដើម្បីកុំឲ្យលិច។ ចុងបញ្ចប់នៃកម្មវិធីនេះ ប្រជាជនក៏បានលើកជាសំណើរមកកាន់ក្រុមការងារ ដើម្បីអំពាវនាវឲ្យមានការជួយឧបត្ថម្ភជាទូកដរមួយគ្រឿង ទុកចម្លងប្រជាជនក្នុងគ្រាមានអាសន្ន ឬពេលរដូវទឹកឡើង។







មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាសហគមន៍មួយនៅក្នុងភូមិទួលប្រាសាទ នៃស្រុកអន្លង់វែង ដោយផ្តោតទៅលើ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិព័រណ៌ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជា

សោម ប៊ុនថន




សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន។
(ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីអបអរពិធីខួប២៤ឆ្នាំ នៃទិវានយោបាយឈ្នះ ឈ្នះ អបអរសាទរខួប២៤ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨-ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ និងខួប៤ឆ្នាំនៃវិមានឈ្នះ ឈ្នះ មជ្ឈមណ្ឌលឯកសារកម្ពុជាមានកិត្តិយសដែលត្រូវបានផ្តល់ការអនុញ្ញាតឲ្យរៀបចំការតាំងពិព័រណ៌ ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជា រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នៅវិមានឈ្នះ ឈ្នះ ស្ថិតនៅក្នុងសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ពិធីនេះមានការអញ្ជើញចូលរួមពី សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ជាគណៈអធិបតី។

ពិព័រណ៌ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជាបាន



សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ថតរូបជុំគ្នាជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឱកាសចូលរួមពិធីតាំងពិព័រណ៍ ស្ដីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជា រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នៅវិមាន ឈ្នះ ឈ្នះ ដើម្បីអបអរពិធីខួប២៤ឆ្នាំ នៃទិវានយោបាយ ឈ្នះ ឈ្នះ អបអរសាទរខួប២៤ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយ ឈ្នះ ឈ្នះ ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨- ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ និងខួប៤ឆ្នាំនៃវិមាន ឈ្នះ ឈ្នះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រួមចំណែកដល់នយោបាយ ឈ្នះ ឈ្នះ ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា។

ខ្លឹមសារជាកម្មវត្ថុរួមនៃពិព័រណ៍ ស្ដីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជាដើម្បីបង្ហាញឲ្យឃើញពីដំណើរដើមទងនៃការឡើងកាន់អំណាចរបស់ខ្មែរក្រហម ការដួលរលំរបស់ខ្មែរក្រហម ការតស៊ូក្នុងសង្គ្រាមស៊ីវិលក្រោយការដួលរលំរបស់របបខ្មែរក្រហមឆ្នាំ១៩៧៩ រហូតដល់មានគោលនយោបាយ ឈ្នះ ឈ្នះ និងការរស់ឡើងវិញនៃប្រទេសកម្ពុជា។

នៅក្នុងខ្លឹមសារពិព័រណ៍ទាំងមូលមាន៣ផ្នែកសំខាន់ៗគឺ ទី១) អង្គការចាត់តាំងរបស់ខ្មែរក្រហមដែលមានរូបភាពចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលពីកម្មាភិបាលខ្មែរក្រហម មេដឹកនាំកំពូលៗ បានថតនៅទីតាំងព្រលានយន្តហោះ តាមមន្ទីរនានានៅក្នុងរដ្ឋធានីភ្នំពេញក្នុងរបបខ្មែរក្រហម ដែលបង្ហាញអំពីវត្តមានរបស់ខ្មែរក្រហមនៅទីនោះ ខណៈដែលមេដឹកនាំក្នុងរបបនេះបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយបារម្ភខ្លាចមានការទម្លាក់គ្រាប់បែកៗ ទាំងនេះ គឺជាការភូតកុហកៗ នៅក្នុងផ្នែកដដែលនេះក៏បានបង្ហាញថា នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្ដួលរំលំនៅក្នុងឆ្នាំ១៩៧៩ មេដឹកនាំ និងអ្នកដើរតាមរបបនេះបានភៀសខ្លួនទៅនៅតាមបណ្ដោយព្រំដែនកម្ពុជា ថៃ ដើម្បីប្រមូលកម្លាំងតស៊ូឡើងវិញ។ ទោះបីរបបខ្មែរក្រហមបានដួលរលំហើយក៏ដោយ ក៏ក្បាលម៉ាស៊ីនដឹកនាំ និងអង្គការចាត់តាំងរបស់ខ្មែរក្រហមនៅមានវត្តមាននៅឡើយ។ ម្យ៉ាងទៀត ប្រជាជនដែលរត់កាត់ព្រៃ និងឆ្លងកាត់គ្រោះថ្នាក់ផ្សេងៗទៅកាន់ព្រំដែន ក៏ទទួលរងគ្រោះដោយសារជំងឺ អត់អាហារ និងជាន់មីនផ្ទុះស្លាប់នៅតាមផ្លូវៗ ប្រជាជនមួយចំនួនទៀត ក៏បានចូលរួមក្នុងការតស៊ូនៅតាមព្រំដែនរហូតដល់ឆ្នាំ១៩៩៨។

ខ្លឹមសារនៅក្នុងផ្នែកទី២) បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបង្ហាញអំពីការធ្វើការងាររបស់



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ទស្សនាពិព័រណ៍ ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជា រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នៅវិមានឈ្នះ ឈ្នះ ដើម្បីអបអរពិធីខួប២៤ឆ្នាំ នៃទិវានយោបាយឈ្នះ ឈ្នះ អបអរសាទរខួប២៤ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨-ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ និងខួប៤ឆ្នាំនៃវិមានឈ្នះ ឈ្នះ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជននៅតាមសហករណ៍ ការដ្ឋាន លើកទំនប់ ជីកប្រឡាយ និង ប្រព័ន្ធធារាសាស្ត្រផ្សេងៗ ដែលសុទ្ធតែការងារដោយបង្ខំ និងភ័ស្តុតាងដែលបានកើតឡើង។ នៅក្នុងផ្នែកដដែលនេះ ក៏បង្ហាញអំពីទីតាំងបទឧក្រិដ្ឋ ដូចជា ការគាស់រណ្តៅសាកសពជនរងគ្រោះដែលខ្មែរក្រហមសម្លាប់ នៅតាមបណ្តាភូមិឋាននានានៅក្នុងប្រទេសកម្ពុជានៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០។ ទោះបីមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមរត់ភៀសខ្លួនទៅកាន់ព្រំដែនកម្ពុជា-ថៃ ក៏ប្រជាជនកម្ពុជានៅតែទទួលរងនូវសម្ពាធផ្លូវអារម្មណ៍ នូវការបែកបាក់ និងព្រាត់ប្រាស់ក្រុមគ្រួសារ ការស្វែងរកសាច់ញាតិ និងការគាស់រណ្តៅសាកសពរួម ដើម្បីធ្វើបុណ្យឧទ្ទិសកុសលតាមព្រះពុទ្ធសាសនា។ នៅក្នុងផ្នែកនេះ ក៏បង្ហាញអំពីភស្តុតាងនៃអំពើទារុណកម្មនៅតាមមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ក្នុងនោះមានមន្ទីរសន្តិសុខស-២១ប្តូកុកទួលស្លែង ការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់ជាប្រព័ន្ធទៅលើប្រជាជនរាប់ពាន់នាក់។

ចុងក្រោយ គឺផ្នែកទី៣) បង្ហាញពីការរស់ឡើងវិញរបស់ប្រទេសកម្ពុជា ក្រោយការដួលរលំនៃរបបប្រល័យពូជសាសន៍ប៉ុល ពត។ ផ្នែកនេះគឺបង្ហាញអំពីការតស៊ូ និងការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន



ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ បានផ្តល់បទសម្ភាសន៍ដល់អ្នកសារព័ត៌មានអំពីពិធីខួប២៤ឆ្នាំ នៃទិវានយោបាយឈ្នះ ឈ្នះ អបអរសាទរខួប២៤ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨-ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ និងខួប៤ឆ្នាំនៃវិមានឈ្នះ ឈ្នះ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ទស្សនាពិព័រណ៍ ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជា រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នៅវិមានឈ្នះ ឈ្នះ ដើម្បីអបអរពិធីខួប២៤ឆ្នាំ នៃទិវានយោបាយឈ្នះ ឈ្នះ អបអរសាទរខួប២៤ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨-ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ និងខួប៤ឆ្នាំនៃវិមានឈ្នះ ឈ្នះ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីរំដោះជាតិចេញពីអំពើប្រល័យពូជសាសន៍ និងបង្ហាញអំពីជីវិតនៃការរស់ឡើងវិញនៅក្រោយឆ្នាំ១៩៧៩ រួមមានផ្នែក សិល្បៈតន្ត្រី មុខរបរអាជីព កាត់ដេរជីវិតដើរកម្សាន្តនៅតាមមាត់ទន្លេរមណីយដ្ឋានផ្សេងៗ រួមមានទាំងការស្វែងរកយុត្តិធម៌ តាមរយៈការកាត់ទោសមេដឹកនាំខ្មែរក្រហម ដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន ដាក់គុកអស់មួយជីវិតដោយកំបាំងមុខកាលពីខែសីហា ឆ្នាំ១៩៧៩, ការរស់ឡើងវិញនៃសាសនា សិក្សាធិការ ជនជាតិភាគតិច រួមមានជនជាតិភាគតិចតំបន់ភ្នំ និងជនជាតិភាគតិចចាមជាដើម។ ជារួម ផ្នែកនេះ គឺនិយាយអំពីការរស់ឡើងវិញក្រោយការដួលរលំនៃរបបប៉ុល ពត និងការកសាងសង្គមជាតិឡើងវិញបន្តិចម្តងៗ រហូតដល់ប្រទេសកម្ពុជាទទួលបានការរីកចម្រើនក្រោមដំបូលនៃសុខសន្តិភាពដូចនាពេលបច្ចុប្បន្ននេះ។ នៅក្នុងពិព័រណ៍នេះ ក៏មានការរំលេចនូវរូបថតរបស់សម្តេចតេជោ ហ៊ុន សែន នៅក្នុងដំណើរតស៊ូឆ្លងកាត់តំបន់អិច១៦ចូលទៅក្នុងប្រទេសវៀតណាម ដើម្បីស្នើសុំជំនួយដែរ។ នៅក្នុងរូបថតនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញនូវពាក្យស្លោកមួយឃ្លាដែលនិយាយអំពី «**ខ្សែលំហរមេឃ និងផែនដី គឺមិនមានឈ្នះ ឈ្នះ នៃមនុស្សជាតិដែលបានប្រសូត្រចេញពីដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត**»។



ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ទស្សនាពិព័រណ៍ ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជា រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នៅវិមានឈ្នះ ឈ្នះ ដើម្បីអបអរពិធីខួប២៤ឆ្នាំ នៃទិវានយោបាយឈ្នះ ឈ្នះ អបអរសាទរខួប២៤ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨-ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ និងខួប៤ឆ្នាំនៃវិមានឈ្នះ ឈ្នះ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណើរទស្សនកិច្ចសិក្សាស្ដីអំពី «សន្តិភាព និង សិទ្ធិមនុស្ស»មកកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង

*រមែក ទិន*



សិស្សានុសិស្សមកពីវិទ្យាល័យ គេដោ សែន សំរោង ធ្វើដំណើរមកទស្សនកិច្ចសិក្សាស្ដីពី«សន្តិភាពនិងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំទទួលស្វាគមន៍សិស្សានុសិស្សមកពីវិទ្យាល័យ គេដោ សែន សំរោង ចំនួន២៣នាក់ ក្នុងនោះមានសិស្សស្រីចំនួន១៣នាក់ និងសិស្សប្រុសចំនួន១០នាក់។ ទស្សនកិច្ចសិក្សានេះគឺដើម្បីឈ្វេងយល់អំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង»។

សិស្សានុសិស្សមួយចំនួនបានបង្ហាញពីចំណាប់អារម្មណ៍ខ្លាំងក្នុងការធ្វើដំណើរមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ ភន់ សុវណ្ណលីណាត លើកឡើងថា «តាមពិតទៅ ខ្ញុំមានចិត្តសប្បាយរីករាយយ៉ាងខ្លាំងនៅពេលទទួលដំណឹងថា ខ្ញុំបានមកទស្សនកិច្ចសិក្សានៅតំបន់អន្លង់វែង ជាស្រុកមួយនៅក្នុងខេត្តឧត្តរមានជ័យ ដែលមានភាពទាក់ទាញជាងគេ»។

រឿងរ៉ាវដែល សុវណ្ណលីណាត បានដឹងនោះគឺ អន្លង់វែងមានតំបន់ប្រវត្តិសាស្ត្រជាច្រើនដែលបានបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដំណើរទស្សនកិច្ចសិក្សានេះ គឺសិក្សាពីទីតាំងសារមន្ទីរផ្ទះ



សិស្សានុសិស្សមកពីវិទ្យាល័យ គេជោ សែន សំរោង ធ្វើដំណើរមកទស្សនកិច្ចសិក្សាស្តីពី«សន្តិភាពនិងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





តាម៉ុក ទីកន្លែងបូជាសពគ្រួសាររបស់ សុន សេន។ សុន សេន គឺជាមេដឹកនាំមួយរូបនៅជំនាន់ខ្មែរក្រហម ដែលមានតួនាទីគឺជាឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ។ សុន សេន មានប្រពន្ធឈ្មោះ យុន យ៉ាត ដែលមានឈ្មោះបដិវត្តន៍ហៅថា សមមិត្ត អាត។

យុន យ៉ាត បានរៀបការជាមួយ សុន សេន ហៅខៀវ គឺជាមេដឹកនាំជាន់ខ្ពស់មួយរូបក្នុងចំណោមមេដឹកនាំដទៃទៀតរបស់របបកម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា យុន យ៉ាត ហៅ អាត ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវលើកិច្ចការឃោសនាអប់រំទាំងផ្ទៃក្នុងបក្ស និងខាងក្រៅបក្ស។

ជាបន្តបន្ទាប់មកទៀតនៅឆ្នាំ១៩៧៧ យុន យ៉ាត ត្រូវបានតែងតាំងឲ្យធ្វើជារដ្ឋមន្ត្រីក្រសួងឃោសនាការនៃកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីមានការចាប់ខ្លួនអតីតរដ្ឋមន្ត្រី ហ៊ូ នឹម។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន ព្រមទាំងប្រពន្ធកូនស្រី នីរ សារ និងអ្នកបើកឡានរបស់គាត់ត្រូវបានបាញ់សម្លាប់យ៉ាងសាហាវឃោរឃៅ។ មិនត្រឹមតែប៉ុណ្ណោះ កូនស្រី ២នាក់របស់ សុន សេន ត្រូវបានអូសទៅរំលោភ និងសម្លាប់នៅក្បែរអូរ។

នៅក្នុងកម្មវិធីដំណើរទស្សនកិច្ចសិក្សានេះដែរ ក្រុមការងាររមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានដឹកនាំសិស្សានុសិស្សបន្តដំណើរដោយថ្មើរជើងទៅកាន់ចេតិយរបស់ តាម៉ុក ដែលស្ថិតនៅក្នុងវត្តស្រះឈូក ដើម្បីឲ្យសិស្សានុសិស្សបានស្គាល់ និងឃើញទីតាំងផ្ទាល់។ តមកសិស្សានុសិស្សទៅទស្សនកិច្ចសិក្សាទីតាំងដុតសពរបស់ ប៉ុល ពត នៅលើខ្នងភ្នំដងរែកនៃស្រុកអន្លង់វែង។ នៅឆ្នាំ១៩៩៧ ប៉ុល ពត ត្រូវបានតាម៉ុកចាប់ខ្លួន និងកាត់ទោសនៅចំពោះមុខតុលាការប្រជាជនដោយចោទថា ប៉ុល ពតបានបញ្ជាឲ្យសម្លាប់ សុន សេន និងក្រុមគ្រួសារ។ ប៉ុល ពតបានស្លាប់ដោយសារជំងឺចាស់ជរា នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨។

ចេញពីទីតាំងដុតសពរបស់ ប៉ុល ពត សិស្សានុ-សិស្សបានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (អតីតផ្ទះប្រជុំតាម៉ុក) នៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្នត្រូវប្រែក្លាយទៅជាទីកន្លែងអប់រំអំពីសន្តិភាព និងសិទ្ធិមនុស្ស ដល់យុវជនជំនាន់ក្រោយ។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបរាប់នូវខ្លឹមសារសំខាន់ៗទាក់ទងនឹងទីតាំងនេះទៅកាន់សិស្សានុសិស្សដែលបានចូលរួមថា ផ្ទះនេះគឺជាទីកន្លែងស្នាក់នៅ និងជាទីកន្លែងជួបប្រជុំរបស់តាម៉ុកជាមួយមេដឹកនាំកំពូលៗរបស់ខ្មែរក្រហម ដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, សុន សេន និងមេបញ្ជាការកងពលមួយចំនួនទៀត។

ម៉ា រិទ្ធី អាយុ១៨ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំពិតជាមានសេចក្តីត្រេកអរ និងរំភើបជាខ្លាំង នៅពេលដែលបានធ្វើដំណើរមកកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ ខ្ញុំចង់ដឹងពីប្រវត្តិរឿងរ៉ាវនៅទីនេះជាយូរមកហើយ។ ខ្ញុំទទួលបានចំណេះដឹងកាន់តែច្រើនអំពីតំបន់អន្លង់វែង និងមានការសោកស្តាយដែលប្រទេសជាតិធ្លាក់ចុះដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យ»។ ខ្ញុំក៏ចាប់អារម្មណ៍ទៅលើមជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែងនៅលើខ្នងភ្នំដងរែក និងវត្តអូរក្រញូង ដោយសារតែនៅទីនោះមានទេសភាពស្រស់ស្អាតប្លែកភ្នែក ជាពិសេសមានរូបបដិមា គួបផ្សំជាមួយខ្យល់ត្រជាក់ដែលធ្វើឲ្យខ្ញុំចង់មកម្តងទៀត។









សិស្សានុសិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង ធ្វើដំណើរមកទស្សនកិច្ចសិក្សាស្តីពី«សន្តិភាពនិងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀន ស្តីអំពី
## «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

**សួត វិចិត្រ**



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ និងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងថតរូបជុំគ្នា។ (សួត វិចិត្រ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍សិស្សានុសិស្សចំនួន ១៥នាក់ (ស្រី៨នាក់ និងប្រុស៧នាក់) មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ នៃស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីចូលរួមក្នុងវេទិកាថ្នាក់រៀន ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។

វេទិកានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទ្រឹស្តីមួយចំនួនទាក់ទងនឹងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ សិស្សានុសិស្សមានចំណេះដឹងជាមូលដ្ឋានទៅលើផ្នែកប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងរបបខ្មែរក្រហម ភាពផ្តាច់ការរបស់ថ្នាក់ដឹកនាំខ្មែរក្រហម ការធ្វើទារុណកម្មទៅលើប្រជាជនស្លូតត្រង់ ការជំរុញប្រជាជនឲ្យធ្វើការងាររួម ការហូបរួម និងការរស់នៅរួម ក្រោមការបំបិទសិទ្ធិសេរីភាព និងការបញ្ចេញមតិ ផ្សេងៗនៅក្នុងវណ្ណៈជាកសិករ។

បន្ទាប់មកទៀតបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការបង្រៀនបែបសហការទៅ

លើជំពូកសំខាន់ៗ ទាក់ទងនឹងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ព្រមទាំងនិយមន័យ ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់នៃអំពើនេះ ក៏ត្រូវបានចាប់ផ្តើមឡើងដោយបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ សិស្សានុសិស្សបានចោទសំណួរជាច្រើនទាក់ទងនឹងប្រធានបទថា ហេតុអ្វីបានជារបបខ្មែរក្រហមត្រូវបានបង្កើតឡើង? តើ ប៉ុល ពត និង ខៀវ សំផន ជានរណា? តើរបបខ្មែរក្រហមមានគោលបំណងសម្រាប់អ្នកចេះដឹង និងបំបិទសិទ្ធិសេរីភាពរបស់ប្រជាជនយ៉ាងណា? ហេតុអ្វីបានជាប្រជាជនមិនទទួលបានការបរិភោគអាហារគ្រប់គ្រាន់?

បន្ទាប់ពីបានចូលក្នុងវេទិកានេះ សិស្សានុសិស្សចំនួន២នាក់ បានមានចំណាប់អារម្មណ៍ និងការយល់ឃើញដូចខាងក្រោម៖

**រ៉ូ ម៉ីរី** ភេទប្រុស អាយុ១៥ឆ្នាំ យល់ឃើញថា «ប្រសិនបើកើតមានអំពើប្រល័យពូជសាសន៍ម្តងទៀត នោះប្រទេសរបស់យើងនឹងបំផ្លិចបំផ្លាញទាំងស្រុង ដោយសារអំពើនេះបានបង្ហាញពីការចាប់បង្ខំមនុស្សគ្រប់ៗគ្នាមិនឲ្យទទួលបានសេចក្តីសុខក្នុងការរស់នៅ មានតែភាពឈឺចាប់ ការបាត់បង់មនុស្សជាទីស្រឡាញ់ ជាពិសេស គឺរស់នៅក្រោមអ្នកមានអំណាច។ លើសពីនេះ ខ្មែរក្រហមបានប្រកាន់ខ្ជាប់នូវភាពផ្តាច់ការ មិនមានមនោសញ្ចេតនាចំពោះគ្នានឹងគ្នា កុមារៗមិនទទួលបានការអប់រំជ្រៅជ្រះ។ ក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងចូលរួមទប់ស្កាត់ការកកើតឧក្រិដ្ឋ-កម្មឃោរឃៅ នាពេលអនាគតតាមរយៈ: ការលុបបំបាត់អំពើហិង្សាចំពោះកុមារ និងស្ត្រីភេទ ចូលរួមសកម្មភាពការងារនៅក្នុងសង្គម ស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ការបង្រៀន និងអប់រំទៅដល់ក្មេងៗពីផលលំបាកនៃអំពើប្រល័យពូជសាសន៍ រួបរួមសាមគ្គីគ្នា និងសម្រុះសម្រួលជម្លោះដោយសន្តិវិធី»។

**ឆាយ សុធន** ភេទប្រុស អាយុ១៧ឆ្នាំ បានមានចំណាប់អារម្មណ៍ថា «បន្ទាប់ពីបានចូលរួមនៅក្នុងវេទិកានេះរួចមក ខ្ញុំបានឈ្វេងយល់អំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) និងគុណវិបត្តិនៃរបបនេះ។ ប្រសិនបើមានឧក្រិដ្ឋកម្មឃោរឃៅកើតឡើងពិតប្រាកដមែន ខ្ញុំគិតថា ឧក្រិដ្ឋកម្មនោះនឹងបំផ្លិចបំផ្លាញទៅលើក្រុមសាសនា ជាតិពន្ធុ បាត់បង់ធនធានមនុស្ស ខូចខាតរចនាសម្ព័ន្ធប្រទេសជាតិ សេដ្ឋកិច្ច ការអប់រំ និងវិស័យដទៃផ្សេងទៀតធ្លាក់ចុះ។ ក្នុងនាមខ្ញុំជាយុវជន ដើម្បីទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងនាពេលអនាគត យើងគួរតែឈ្វេងយល់ពីផលវិបាក និងចែករំលែកចំណេះដឹងទាំងនោះទៅកាន់យុវជនជំនាន់ក្រោយៗបន្តទៀត»។







សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ចូលរួមវេទិកាថ្នាក់រៀន ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។
(ហ៊ាន ពិសី/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនស្តីពី

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅស្រុកអន្លង់វែងការឈ្វេងយល់ពីរឿងរ៉ាវប្រវត្តិសាស្ត្រ គឺដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

*សួគ ទិចិត្រ*



សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស ១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង ចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង បានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ វេទិកាថ្នាក់រៀននេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងដល់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។

លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញផ្តោតទៅលើហេតុការណ៍ដែលបានកើតឡើងនាជំនាន់ខ្មែរក្រហម រួមមាន ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជន ការធ្វើទារុណកម្ម និងការសម្លាប់រង្គាល

ទៅលើប្រជាជន និងមន្ត្រីរដ្ឋការ លន់ នល់ ព្រមទាំងទិដ្ឋភាពផ្លូវច្បាប់នៅក្នុងដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ប្តឹងតុលាការខ្មែរក្រហម ដែលបានកាត់ទោសទៅលើមេដឹកនាំកំពូលៗ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហម។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបខ្មែរក្រហមបានជម្លៀសប្រជាជនទ្រង់ទ្រាយធំលើកដំបូង និងបានសម្លាប់រង្គាលទៅលើទាហាន នល់ នល់ និងអ្នកដែលពាក់ព័ន្ធនឹងរបបនេះ។ ទួលពោធិ៍ជ្រៃ គឺជាទីវាលដែលស្ថិតនៅកៀកនឹងទន្លេសាប ព្រៃនាម និងត្រូវបានស្គាល់ថា ជាទីកន្លែងដែលខ្មែរក្រហមកាប់សម្លាប់ទៅលើទាហាន លន់ នល់ និងប្រជាជនស៊ីវិលរាប់ពាន់នាក់។ មានការប៉ាន់ប្រមាណថា ទាហាន នល់ នល់ ចន្លោះពី ២ ០០០ នាក់ ទៅ ៨០០០ នាក់ ត្រូវបានសម្លាប់នៅទីនោះ។ សិស្សម្នាក់បោទសួរនៅក្នុងវេទិកាថា ហេតុអ្វីបានជាខ្មែរក្រហមបានដាក់គោលដៅនៃការសម្លាប់ទៅលើទាហាន និងមន្ត្រីរដ្ឋការក្នុងរបប លន់ នល់?

នៅក្នុងដំណើរការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបែងចែកសំណុំរឿងដាច់ដោយឡែកពីគ្នារួមមាន៖ សំណុំរឿង ០០១, ០០២, ០០៣ និង ០០៤ ។ សំណុំរឿង ០០១ ពាក់ព័ន្ធនឹងការជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១។ អ្នកទោសប្រមាណជាង១ម៉ឺននាក់ត្រូវបានធ្វើទារុណកម្មនៅក្នុងមន្ទីរស-២១ និងយកទៅសម្លាប់នៅវាលពិឃាដបឹងជើងឯក។

នៅក្នុងឆ្នាំ១៩៩៩ ឌុច ត្រូវបានចាប់ខ្លួនពីសំណាក់អាជ្ញាធរកម្ពុជា និងបញ្ជូនទៅឃុំឃាំងក្នុងតុលាការយោធារហូតដល់ឆ្នាំ២០០៧ មុនពេលបញ្ជូនខ្លួនទៅកាន់មន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមដីកាបង្គាប់របស់ចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០១។ នៅខែសីហា ឆ្នាំ២០០៨ ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយការជម្រះក្តីផ្នែកសំខាន់ៗត្រូវបានធ្វើឡើងនៅឆ្នាំ២០០៩។ នៅ



សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស ១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង ចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







ខែកក្កដា ឆ្នាំ២០១០ ឌុច ត្រូវបានជម្រះក្ដីនៅសាលាដំបូង។ នៅទីបំផុត ឌុច ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ឌុចបានស្លាប់ដោយសារជំងឺរលាកទងសួត នៅមន្ទីរពេទ្យមិត្តភាពខ្មែរ- សូវៀត កាលពីខែកញ្ញា ឆ្នាំ២០២០។

សំណុំរឿង០០២ ពាក់ព័ន្ធនឹងបទចោទប្រកាន់ទៅលើ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ។ សំណុំរឿង០០២ វគ្គ០២ ៖ នៅខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះវិសាមញ្ញបានបើកសវនាការជាលើកដំបូង ដើម្បីជំនុំជម្រះលើសំណុំរឿង០០២ វគ្គ០២ ដោយផ្ដោតទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ទាក់ទងនឹងក្រុមគោលដៅជាក់លាក់ ដូចជាជនជាតិចាម វៀតណាម អ្នកកាន់ព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នៅក្នុងសំណុំរឿង០០២ វគ្គ០២ នេះ មានតែ ខៀវ សំផន ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅក្នុងពន្ធនាគារ បន្ទាប់ពី នួន ជា បានស្លាប់កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ កន្លងទៅ។

សំណុំរឿង ០០៣ និង០០៤ ត្រូវបានបង្កើតឡើងនៅខែកញ្ញា ឆ្នាំ២០០៩ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាបញ្ជូនឲ្យស៊ើបសួរទៅកាន់សហចៅក្រមស៊ើបអង្កេត ស្នើឲ្យមានការស៊ើបអង្កេតលើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងជនសង្ស័យចំនួន ៥រូប រួមមាន មាស មុត និង ស៊ូ មេត ត្រូវបានដាក់បញ្ចូលឈ្មោះថា ជាជនសង្ស័យក្នុងសំណុំរឿង០០៣។ ចំណែកឯ អោ អាន, អ៊ឹម ចែម និង យឹម ទិត្យ ត្រូវបានដាក់បញ្ចូលឈ្មោះថាជាជនសង្ស័យក្នុងសំណុំរឿង០០៤។ ដោយឈរលើមូលដ្ឋានថាខ្វះដែនសមត្ថកិច្ចក្នុងការអនុវត្ត អង្គបុរេជំនុំជម្រះបានសម្រេចទម្លាក់ចោលការចោទប្រកាន់ទៅលើបុគ្គលខាងលើនេះ។

នៅផ្នែកចុងក្រោយនៃវេទិកា គឺវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញដល់សិស្សានុសិស្ស។ សិស្សម្នាក់ក្នុងចំណោម២៦នាក់យល់ឃើញថា ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺផ្ដើមចេញពីការមិនគាំទ្រនូវសកម្មភាពរើសអើង ឈ្វេងយល់ពីរឿងរ៉ាវប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ក្នុងសង្គម និងមិនគាំទ្រដល់ការបង្កើតឲ្យមានរបបកុម្មុយនីស្ត។



សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស ១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង ចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្ដីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «វេទិកាលើកកម្ពស់សិទ្ធិស្ត្រី»

**សួត វិចិត្រ**



នៅព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកា «លើកកម្ពស់សិទ្ធិស្ត្រី» ដោយមានប្រជាពលរដ្ឋចំនួន២៣នាក់ គឺមានស្រី២០នាក់ និងប្រុស៣នាក់ ក្នុងចំណោមប្រជាជនសរុបប្រមាណ ១០៧ គ្រួសារនៃភូមិយាងខាងត្បូង មកចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វេទិកា «លើកកម្ពស់សិទ្ធិស្ត្រី» នៅក្នុងស្រុកអន្លង់វែង ត្រូវបានរៀបចំឡើងដោយមជ្ឈ មណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០ ២៣នេះ។

ប្រជាពលរដ្ឋចំនួន ២៣នាក់ (ស្រី២០នាក់ និងប្រុស៣នាក់) ក្នុងចំណោមប្រជាជនសរុបប្រមាណ ១០៧ គ្រួសារនៃភូមិយាងត្បូង បានចូលរួមនៅក្នុងវេទិកានេះ ដែលផ្តោតលើប្រវត្តិសា ស្ត្រខ្មែរក្រហម ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសិទ្ធិរបស់ស្ត្រីក្នុងការទទួលព័ត៌មានការសិក្សា និងការអភិវឌ្ឍន៍សង្គម។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានដឹកនាំការពិភាក្សានេះ ដោយបង្ហាញអំពីការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងគម្រោងថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានអនុវត្តកន្លងមក ជាមួយប្រជាជននៅក្នុងភូមិយាងត្បូង និងទូទាំងស្រុកអន្លង់វែង។

បន្ទាប់មក លោកបានជ្រើសរើសផ្ទាំងពិព័រណ៍រូបថតដែលបង្ហាញអំពីការធ្វើការងារដោយបង្ខំនៅក្នុង

របបខ្មែរក្រហម រូបគ្រោងឆ្អឹង និងលលាដ៍ក្បាលជនរងគ្រោះ ការធ្វើកោសល្យវិច្ច័យលើគ្រោងឆ្អឹង និងលលាដ៍ក្បាលជនរងគ្រោះ និងដែនទីរណ្តៅសាកសពរួម ដើម្បីធ្វើការពិភាក្សាជាមួយអ្នកភូមិ។ ពិព័រណ៍ទាំងនេះគឺជាផ្នែកមួយដែលយកចេញពីពិព័រណ៍រួមដែលមានចំនួនប្រមាណជាង១០០ផ្ទាំង ដែលត្រូវបានដាក់តាំងបង្ហាញនៅក្នុងកម្មវិធី «ខួប២៨ឆ្នាំនៃទិវានយោបាយឈ្នះ ឈ្នះ» កាលពីចុងឆ្នាំ២០២២កន្លងទៅនេះ។

ពិព័រណ៍ទាំងនោះ បានរំពុកនូវការចងចាំដល់ស្ត្រីដែលធ្លាប់ឆ្លងកាត់ជំនាន់ខ្មែរក្រហម គឺបទពិសោធន៍ដ៏ជូរចត់ដែលខ្លួនយល់ថា ហាក់ទើបនឹងកើតឡើងថ្មីៗមកលើខ្លួននិងក្រុមគ្រួសារ។ ស្ត្រីភាគច្រើនបាននិយាយអំពីការជួបប្រទះនឹងការងារដោយបង្ខំ ដូចជា ការលើកទំនប់ជីកប្រឡាយ និងធ្វើជីដាក់ស្រែ ក៏ប៉ុន្តែដើម្បីអាចរស់រានមានជីវិត ស្ត្រីទាំងនោះបានខិតខំធ្វើការងារគ្រប់បែបយ៉ាងដែលអង្គការខ្មែរក្រហមបានតម្រូវ។

នៅពេលដែលការពិភាក្សាឈានដល់ដំណើរការកាត់ទោស មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ត្រីភាគច្រើនបាននិយាយថា ខ្លួនមិនធ្លាប់បានឮ ឬបានដឹងពីដំណើរការនេះពីមុនមកទេ។ ទោះជាយ៉ាងនេះក្តី ការចងចាំរបស់ស្ត្រីទាំងនោះក៏នៅតែបន្តអំពីការលះបង់ និងការចូលរួមរបស់ខ្លួនក្នុងបុព្វហេតុជាតិមាតុភូមិ។

## តើដាច់ឆ្ងាយពីដំណើរការរបស់តុលាការខ្មែរក្រហម និងធ្វើឱ្យជះឥទ្ធិពលដល់ស្ត្រីដែរឬទេ?

វេទិកានេះ បានផ្តល់នូវការពិភាក្សាអំពីទាក់ទងសិទ្ធិ និងប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេស គឺបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងភូមិ នៅពេលដែលបរិបទប្រវត្តិសាស្ត្រខ្មែរក្រហមបានធ្វើឲ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងរបៀបរបបការរស់នៅមួយចំនួន។

ការមិនអើពើឬដាច់ឆ្ងាយពីដំណើរការកាត់ទោសរបស់តុលាការខ្មែរក្រហម គឺជាការខុះចន្លោះមួយរបស់ស្ត្រីដែលបង្ហាញពីគម្លាតនៃការអប់រំឬរៀនសូត្រពិតប្រាកដមួយអំពីបទពិសោធន៍ដែលខ្លួនបានឆ្លងកាត់ពីជំនាន់ខ្មែរក្រហម និងការផ្លាស់ប្តូរផ្នត់គំនិតក្នុងពេលសុខសន្តិភាព។ ដំណើរការស្វែងរកយុត្តិធម៌ ក៏ជាផ្នែកមួយនៃការអប់រំ និងរៀនសូត្ររបស់មនុស្សក្នុងសង្គមអំពីកំហុសដែលបានកើតឡើង ជាពិសេស ទាក់ទងនឹងសិទ្ធិជាមូលដ្ឋានរបស់មនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត។

**យា មុំ** គឺជាស្ត្រីម្នាក់ដែលមានតួនាទីជាអនុភូមិក្នុងភូមិយាងត្បូង បាននិយាយនៅក្នុងវេទិកាសាធារណៈនេះថា ខ្ញុំចង់ឲ្យស្ត្រីៗនាំគ្នាខិតខំពង្រឹងសមត្ថភាព និងផ្លាស់ផ្នត់គំនិតអវិជ្ជមានរបស់ខ្លួនដើម្បីរៀនសូត្រពីចំណេះដឹងដែលថ្មីៗ មានភាពក្លាហាន និងរឹងមាំ ដើម្បីមានភាពស្មើគ្នាទៅនឹងបុរសនៅក្នុងសង្គម។ ស្ត្រីប្រៀបបានទៅនឹងមាតាដៃមួយរយ ឬមាតានៃពិភពលោក





នៅព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកា «លើកកម្ពស់សិទ្ធិស្ត្រី» ដោយមានប្រជាពលរដ្ឋចំនួន២៣នាក់ គឺមានស្រី២០នាក់ និងប្រុស៣នាក់ ក្នុងចំណោមប្រជាជនសរុបប្រមាណ១០៧ គ្រួសារនៃភូមិយាងខាងត្បូង មកចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកា «លើកកម្ពស់សិទ្ធិស្ត្រី» ដោយមានប្រជាពលរដ្ឋចំនួន២៣នាក់ គឺមានស្រី២០នាក់ និងប្រុស៣នាក់ ក្នុងចំណោមប្រជាជនសរុបប្រមាណ ១០៧ គ្រួសារនៃភូមិយាង ខាងត្បូង មកចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលអាចធ្វើការងារមួយរយជំពូក ខណៈពេលបុរសៗមួយចំនួនមិនបានមើលឃើញពីតម្លៃនៃការលះបង់ និងថែមទាំងបានប្រើប្រាស់អំពើហិង្សា ទាំងផ្លូវកាយ និងផ្លូវចិត្តទៅលើស្ត្រីទៀតផង។ ស្ត្រីត្រូវមានភាពម្ចាស់ការក្នុងការជ្រោមជ្រែង និងដឹកនាំគ្រួសារ ជាពិសេស គឺការអប់រំដល់កូនចៅ ឬយុវជនជំនាន់ក្រោយរបស់ខ្លួនឲ្យរៀនសូត្របានខ្ពង់ខ្ពស់ និងការប្រើប្រាស់ចំណេះដឹង និងប្រាជ្ញាដើម្បីកសាងធនធានមនុស្ស។ នៅពេលណាកើតមានអំពើហិង្សាក្នុងគ្រួសារ ខ្ញុំនឹងប្រើប្រាស់វិធានការសម្របសម្រួល និងវិធានការច្បាប់ដោយសហការជាមួយប្រជាការពារភូមិ និងអាជ្ញាធរមូលដ្ឋានដើម្បីអប់រំជាបន្ទាន់។ ទាំងនេះ គឺជាការផ្តល់ភាពកក់ក្តៅមួយដែលឆ្លើយតបទៅនឹងការទុកចិត្តរបស់ប្រជាជននៅក្នុងភូមិដើម្បីការចូលរួមក្នុងមូលដ្ឋានក្នុងការផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមាន និងការរស់នៅឲ្យមានភាពល្អប្រសើរ។

ផ្នែកបន្ទាប់មកទៀតនៃវេទិកានេះ ក៏មានការរួមបញ្ចូលនូវការពិភាក្សាអំពីគម្រោងអភិវឌ្ឍន៍សហគមន៍ដែលជាគម្រោងមួយផ្តោតសំខាន់ទៅលើការជំរុញឲ្យប្រជាជនក្នុងសហគមន៍ស្វែងរកចំណុចពិសេសក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីយកចំណុចពិសេស ទាំងនោះទាញរកចំណូលទ្រទ្រង់សហគមន៍របស់ខ្លួន។

ការអភិវឌ្ឍន៍នេះក៏រួមបញ្ចូលនូវភាពសន្សំសំចៃ និងការគិតយ៉ាងល្អិតល្អន់ ដើម្បីកុំឲ្យសេដ្ឋកិច្ចនៅក្នុងមូលដ្ឋានហូរចេញទៅខាងក្រៅ រួមមានទាំងការដាំដុះ និងបង្កបង្កើនផលជុំវិញផ្ទះជាដើម។

ជាចុងបញ្ចប់ ថ្នាក់ដឹកនាំភូមិយាងត្បូងក៏បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានបង្កើតវេទិកានេះឡើង ដោយបានជំរុញឲ្យមានការពិភាក្សាអំពីសិទ្ធិជាពិសេសទៅលើស្ត្រីនៅក្នុងមូលដ្ឋានស្របពេលដែលប្រជាជនកំពុងត្រូវការដោះស្រាយបញ្ហាទាំងនេះឲ្យមានភាពប្រសើរឡើងជាងមុន។

# វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅអន្លង់វែង

ស្ចក ទិចិត្រ



លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ពន្យល់អំពីនិយមន័យ«អំពើប្រល័យពូជសាសន៍» ទៅកាន់សិស្សានុសិស្សដែលចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ទៅកាន់សិស្សានុសិស្សចូលរួមចំនួន ១៥នាក់ មកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ ស្រុកអន្លង់វែង។ វេទិកានេះ បង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងដល់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទ្រឹស្តីមួយចំនួនទាក់ទងនឹងសន្តិភាព និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ដំបូងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានចែកជូនក្រដាសស្ទាបស្ទង់ចំណេះដឹងមុនវេទិកាចាប់ផ្តើមចំនួន១៥ច្បាប់ទៅកាន់សិស្សានុសិស្ស ដើម្បីវាយតម្លៃចំណេះដឹងមូលដ្ឋានមុនពេលដែលសិស្សានុសិស្សចូលរួមក្នុងវេទិកាប្រវត្តិសាស្ត្រនេះ។ បន្ទាប់មកលោក



សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍អង្គុយជារង្វង់លើកជាចម្ងល់ និងធ្វើឲ្យមានការពិភាក្សាគ្នាក្នុងក្រុមៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កាពិភាក្សាជាក្រុម និងមានការលើកជាសំណួររបស់សិស្សានុសិស្សដែលបានចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានពន្យល់លម្អិតអំពីនិយមន័យនៃអំពើប្រល័យពូជសាសន៍៖ «គឺជាអំពើទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងចេតនាបំផ្លិចបំផ្លាញចោលទាំងស្រុង ឬដោយផ្នែកចំពោះក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ ក្រុមសាសនា» ហើយក្រុមទាំងបួនខាងនេះ ក៏ត្រូវបានពន្យល់ពីភាពខុសគ្នាយ៉ាងលម្អិតបន្ថែមទៀត ។

បន្ទាប់មកទៀតបទបង្ហាញអំពី «ផែនការបួនឆ្នាំ (១៩៧៧-១៩៨០)» តម្រូវឲ្យសិស្សានុសិស្សយកចិត្តទុកដាក់ក្នុងការអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» តាមរយៈការបែងចែកក្រុមចំនួន៥ក្រុមផ្សេងៗពីគ្នា។ មេរៀននេះ មានគោលបំណងឲ្យសិស្សានុសិស្សនិយាយអំពីការយល់ឃើញផ្ទាល់ខ្លួនក្រោយអានខ្លឹមសារចប់។ ផែនការបួនឆ្នាំគឺបង្កើតឡើងដោយខ្មែរក្រហម និងមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជននានាទៅកាន់ទីជនបទដាច់ស្រយាល។ ផែនការនេះ មានបំណងប្រែក្លាយសង្គមកម្ពុជាឲ្យក្លាយទៅជាប្រទេសជឿនលឿនផ្នែកកសិកម្ម។ ខ្មែរក្រហមបង្ខំឲ្យប្រជាជនដាក់ទ្រព្យសម្បត្តិឯកជនទៅជាទ្រព្យសម្បត្តិរួម និងជ្រើសរើសការដាំដុះស្រូវជាអាទិភាពចម្បងសម្រាប់ជាតិចន្លោះឆ្នាំ១៩៧៧ ដល់ ១៩៨០។ ខ្មែរក្រហមបានកំណត់យកនូវទិន្នផលស្រូវជាមធ្យមចំនួន៣តោនក្នុង១ហិកតា ដែលជំរុញឲ្យមានការបង្ខំប្រជាជនធ្វើការងារហួសកម្លាំង និងគ្មានពេលសម្រាក។ គោលបំណងនេះមិនអាចសម្រេចបានទេ ដោយសារប្រជាជនមិនធ្លាប់ទទួលរងការបង្ខិតបង្ខំឲ្យធ្វើការងារបែបនេះពីមុនមក ការបំផ្លិចបំផ្លាញដោយភ្លើងសង្គ្រាម និងកង្វះខាតឧបករណ៍ធ្វើកសិកម្ម។ ផែនការបួនឆ្នាំ មានរួមបញ្ចូលទាំងគម្រោងដាំបន្លែបង្ការ ហើយខ្មែរក្រហមសង្ឃឹមថានឹងទាញយកអនុផលពីព្រៃឈើ ការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើជាដើម។ មេដឹកនាំខ្មែរក្រហមរំពឹងថា ប្រទេសកម្ពុជានឹងមានឯករាជ្យភាពពេញបរិបូណ៌ទាំងវិស័យសេដ្ឋកិច្ច និងវិស័យនយោបាយ។ ដោយផ្អែកលើគម្រោងផែនការនេះ ប្រជាជនបានទទួលរងទុក្ខលំបាក តាមរយៈរបបអាហារ និងការធ្វើការងារហួសកម្លាំង។ ប្រជាជនភាគច្រើនហូបតែបបរលាយពោត លាយដើមចេក និងលាយគល់ល្ហុង ហើយទទួលបានរបបអង្ករតិចជាងកន្លះកំប៉ុងក្នុងមួយថ្ងៃ ផ្ទុយទៅនឹងកម្មាភិបាល និងកងទ័ពខ្មែរក្រហមប៉ុណ្ណោះ ដែលមានបាយហូបគ្រប់គ្រាន់។ សិស្សានុសិស្សបានយល់ឃើញថា «ផែនការបួន

ឆ្នាំ (១៩៧៧-១៩៨០)» បានជំរុញឲ្យប្រជាជនទទួលរងអំពើឃោរឃៅ និងលំបាកវេទនាយ៉ាងខ្លាំងតាមរយៈការបង្ខំឲ្យធ្វើការហួសកម្លាំង និងបាត់បង់ភាពឯកជន និងសិទ្ធិសេរីភាពគ្រប់បែបយ៉ាង។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមបន្សល់ទុកនូវភាពអយុត្តិធម៌ដល់ប្រជាជនតាមរយៈការមិនខ្វាយខ្វល់ពីទុក្ខលំបាករបស់ប្រជាជន ការបំបែកបំបាក់ក្រុមគ្រួសារ និងគិតតែពីផែនការរបស់ខ្លួនតែប៉ុណ្ណោះ។ ខ្មែរក្រហមមិនបានប្រៀបធៀបការឈឺចាប់ និងសេចក្ដីស្រឡាញ់របស់ខ្លួន ប្រសិនជួបប្រទះនឹងការបែកបាក់ក្រុមគ្រួសារដូចប្រជាជននាសម័យនោះទេ។ សិស្សានុសិស្សអាចយល់កាន់តែទូលំទូលាយអំពីរឿងរ៉ាវដែលសង្គមរបស់ខ្លួនធ្លាប់បានឆ្លងកាត់ និងយល់ដឹងកាន់តែជ្រៅទៅលើភាពសម្បូរបែបរបស់មនុស្សនៅក្នុងសង្គម ដែលពាក់ព័ន្ធទៅនឹងការគោរពសិទ្ធិក្រមសីលធម៌ និងសុជីវធម៌នៅក្នុងសង្គម។ នៅក្រោយវេទិកាថ្នាក់រៀន សិស្សានុសិស្សទាំង ១៥នាក់ កើនចំណេះដឹង និងយល់ឃើញថាការទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺពិតជាមានសារសំខាន់សម្រាប់បុគ្គល សហគមន៍ និងសង្គមជាតិ ទោះបីក្នុងវិធីណាក៏ដោយ។ សិស្សានុសិស្ស១២នាក់ក្នុងចំណោម១៥នាក់ យល់ឃើញថា «ឧក្រិដ្ឋកម្មសង្គ្រាម» គឺអាចផ្ដល់ឧទាហរណ៍បានតាមរយៈ ក្រុមទាហានបានធ្វើទារុណកម្មអ្នកទោសសង្គ្រាមនៅពេលមានជម្លោះប្រដាប់អាវុធ។ បន្ទាប់ពីបានចូលរួមក្នុងវេទិកានេះ សិស្សានុសិស្សមានចំណាប់អារម្មណ៍ និងការយល់ឃើញដូចខាងក្រោម៖

**រុំ សារុន** ភេទស្រី អាយុ១៧ឆ្នាំ យល់ឃើញថា៖ « បន្ទាប់ពីបានចូលរួមក្នុងវេទិកានេះរួចមក ខ្ញុំបានរៀនសូត្រពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដូចជា៖ ការលុបបំបាត់សិទ្ធិសេរីភាពរបស់ប្រជាជនក្នុងរបបខ្មែរក្រហម, ប្រជាជនទទួលរងការគាបសង្កត់យ៉ាងធ្ងន់ធ្ងរ និងទុក្ខលំបាកវេទនា តាមរយៈការងារកសិកម្ម និងបែកបាក់ក្រុមគ្រួសារ។ តាមការរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំឃើញថា ខ្មែរក្រហមបានបំផ្លាញអាយុជីវិតមនុស្ស អ្នកមានចំណេះដឹង សេដ្ឋកិច្ច ប្រទេសជាតិគ្មានយុត្តិធម៌ បំផ្លាញទឹកចិត្តប្រជាជន ដោយធ្វើទារុណកម្ម បំផ្លាញវត្តអារាម សាលារៀន គ្រឹះស្ថានផ្សេងៗ។ ក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយ ដើម្បីចូលរួមទប់ស្កាត់ការកកើតឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត យើងត្រូវសិក្សាឈ្វេងយល់ឲ្យបានច្បាស់លាស់ពីប្រវត្តិសាស្ត្ររបស់ខ្លួន និងសាមគ្គីគ្នាដើម្បីស្តារ ឬលុបបំបាត់របបនោះ។ មួយវិញទៀត យើងត្រូវសិក្សារៀនសូត្រឲ្យមានចំណេះដឹង គិតគូឲ្យបានខ្ពស់ និងធ្វើជាពលរដ្ឋល្អនៅក្នុងសង្គម»។

**មឿន រក** ភេទប្រុស អាយុ១៦ឆ្នាំ មានចំណាប់អារម្មណ៍ថា៖ « ខ្ញុំបានយល់ដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាច្រើនដូចជា ការបោសសម្អាតទីក្រុង និងទីប្រជុំជននានា ការប្រមូលទ្រព្យសម្បត្តិឯកជនរបស់ប្រជាពលរដ្ឋដាក់រួម ការបង្ខំឲ្យប្រជាជនផលិតស្រូវដែលមានកម្រិតច្រើនលើសកំណត់ ការធ្វើការងារហួសកម្លាំង។ ប្រសិនបើឧក្រិដ្ឋកម្មឃោរឃៅកើតឡើង នោះនឹងបំផ្លាញដល់ប្រទេសជាតិ និងប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសនោះ ពីព្រោះសេដ្ឋកិច្ច គឺជាកត្តាដ៏សំខាន់ដែលអាចឲ្យប្រទេសជាតិរីកចម្រើនបាន។ មួយវិញទៀត វាក៏អាចឲ្យប្រទេសជាតិមានសន្តិសុខ គ្មានសណ្ដាប់ធ្នាប់ មានការកាប់សម្លាប់ និងប្រើអំពើហិង្សាដែលបណ្ដាលឲ្យមានការបាត់បង់ជីវិត។ ក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយ ដើម្បីចូលរួមទប់ស្កាត់ការកើតឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត យើងមិនត្រូវរើសអើងជនជាតិ ពណ៌សម្បុរ, មានភាពទទួលខុសត្រូវខ្ពស់ ចូលរួមគ្រប់សកម្មភាពជួយទប់ស្កាត់ដល់ការកកើតឧក្រិដ្ឋកម្មឃោរឃៅ, បេះដោះស្រាយបញ្ហាដោយសន្តិវិធី, លុបបំបាត់អំពើហិង្សា និងរួមគ្នាប្រឆាំងអំពើឧក្រិដ្ឋកម្មឃោរឃៅ»។

# ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំងអង្គការសហប្រជាជាតិ

## របស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ នៅអន្លង់វែង

*លី សុខឃាង*




១ បណ្ឌិត លី សុខឃាង ២ ភរិយា ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ៣ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ៤ ឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង ថតរូបជុំគ្នាបន្ទាប់ពីទស្សនកិច្ចអតីតផ្ទះប្រជុំរបស់តាម៉ុកនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្នគឺជាទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំងរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ បានធ្វើទស្សនកិច្ចពិសេសមួយទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដោយសារមានការគាំទ្រជាចម្បងពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានផ្តោតការងាររបស់ខ្លួនទៅលើការអប់រំអំពីអំពើប្រល័យពូជសាសន៍ដល់យុវជន។ ការអប់រំអំពីអំពើប្រល័យពូជសាសន៍គឺជាប្រធានបទដ៏លំបាកមួយ ជាពិសេសនៅអន្លង់វែង




១ ភរិយា ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន
២ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ៣ លោក វង់ សារ៉ាន អតីតទាហានខ្មែរក្រហម និងធ្លាប់ជាសហការីរបស់លោក ចន សាន់ដឺសុន នៅក្នុងសម័យអ៊ុនតាក់
៤ បណ្ឌិត លី សុខឃាង នៅឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




១ លោក វង់ សារ៉ាន ២ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ៣ បណ្ឌិត លី សុខឃាង ៤ ឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង នៅឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយសារតែប្រវត្តិរឿងរ៉ាវដ៏ស្មុគ្រស្មាញនៅតាមគ្រួសារនីមួយៗ ដែលបាននិងកំពុងបន្តនិយាយ និងពាំនាំទៅកាន់មនុស្សជំនាន់ក្រោយៗទៀត។ អស់រយៈពេលជាង២០ឆ្នាំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងធ្វើកិច្ចការនេះដោយមានការសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឲ្យប្រាកដថាប្រវត្តិសាស្ត្រនេះត្រូវបានបង្រៀនសម្រាប់មនុស្សគ្រប់ជំនាន់នាពេលអនាគត។

ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន បានទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ព្រមទាំងបានជួបជាមួយអតីតទាហានខ្មែរក្រហមដែរ។ ដំណើរទស្សនកិច្ចរបស់ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ទៅកាន់អន្លង់វែង ត្រូវបានធ្វើឡើងជាលើកដំបូងបង្អស់ ចាប់តាំងពីការដួលរលំតំបន់គស្ម៊ីចុងក្រោយនៃចលនាខ្មែរក្រហម កាលពីជាង២០ឆ្នាំមុន។ លោកឧត្តមសេនីយ៍ឯក ក៏ត្រូវបានអមដំណើរដោយភរិយារបស់លោក ព្រមទាំងលោកឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង ដែរ។

ដំណើរទស្សនកិច្ចបានចាប់ផ្តើមដោយមានការបង្ហាញពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំក៏បានរៀបរាប់ប្រាប់អំពីសកម្មភាពការងារផ្សេងៗរបស់មជ្ឈមណ្ឌល ដោយរាប់ទាំងកម្មវិធីអប់រំស្តីពីសន្តិភាពនិងសិទ្ធិមនុស្ស ដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានផ្តល់ជូនដល់កូនចៅរបស់អតីតសមាជិកខ្មែរក្រហម។ អន្លង់វែងមានប្រជាជនចំនួនប្រមាណជិត៦ម៉ឺននាក់ ដែល៨០ភាគរយនៃប្រជាជននៅទីនោះគឺជាអតីតសមាជិកខ្មែរក្រហម។ អន្លង់វែងបានធ្វើសមាហរណកម្មមកក្នុងសង្គមជាតិវិញនៅក្នុងឆ្នាំ១៩៩៨ ដែលមានរយៈពេល៥ឆ្នាំក្រោយពីអ៊ុនតាក់បានបញ្ចប់បេសកកម្មរបស់ខ្លួន។

ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ក៏បានផ្តោតការចាប់អារម្មណ៍លើផ្ទាំងពិព័រណ៍អចិន្ត្រៃយ៍របស់មជ្ឈ-មណ្ឌលដែរ ដែលមានបង្ហាញរូបភាពនិងព័ត៌មានស្តីពីដំណើរមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនកម្ពុជា កាលពីសម័យអ៊ុនតាក់។ នៅក្រោមការគ្រប់គ្រងរបស់អ៊ុនតាក់ ជនភៀសខ្លួនបានវិលត្រឡប់មកកាន់ភូមិឋានរបស់ខ្លួនវិញតាមរទេះភ្លើង ដែលបានដាក់តាំងបង្ហាញនៅលើពិព័រណ៍មួយផ្ទាំង។ ចំណែកឯ ពិព័រណ៍មួយ




① ឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង ② បណ្ឌិត លី សុខឃាង ③ កញ្ញា មេក វិន ④ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំងរបស់អាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ ទស្សនកិច្ចទីតាំងបូជាសព ប៉ុល ពត នៅលើខ្នងភ្នំដងរែក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសិស្សានុសិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង ថតរូបជុំគ្នានៅអតីតផ្ទះប្រជុំរបស់តាម៉ុកនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្នគឺជាទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៀតបានពណ៌នាអំពីរូបភាព ដែលបានសរសេរថា៖ «Benny Widyono ឈរក្នុងចំណោមកងទ័ពខ្មែរក្រហម នៅប៉ៃលិន ដែលជាទីស្នាក់ការកណ្ដាលរបស់ខ្មែរក្រហម នៅជាប់ព្រំដែនថៃ ជាតំបន់មួយដែលមមាញឹកជាមួយនឹងការដួញដូរត្បូងមានតម្លៃ និងព្រៃឈើជាមួយឈ្មួញជនជាតិថៃ។ ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បានអញ្ជើញ Benny Widyono អមដំណើរជាមួយទ្រង់ ដើម្បីត្រួតពិនិត្យតំបន់ខ្មែរក្រហម នៅខែកញ្ញា ឆ្នាំ១៩៩២»។ លោកឧត្ដមសេនីយ៍ឯកបានចាប់អារម្មណ៍ពិព័រណ៌ទាំងនេះ ដោយសារតែបានរំឭកឡើងវិញពីសម័យកាលដែលលោកឧត្ដមសេនីយ៍ឯក ដឹកនាំកងកម្លាំងអ៊ុនតាក់។

ឧត្ដមសេនីយ៍ឯក ចន សាន់ដឺសុន បានធ្វើដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រមួយចំនួនដែរ ដោយរាប់បញ្ចូលទាំងអតីតផ្ទះប្រជុំរបស់តាម៉ុក និងទីតាំងបូជាសព ប៉ុល ពត។ អតីតផ្ទះប្រជុំរបស់តាម៉ុក គឺជាគោលដៅទីមួយ ដែលបច្ចុប្បន្នគឺជាទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ មជ្ឈមណ្ឌលនេះបានប្រែក្លាយអតីតផ្ទះប្រជុំនេះឲ្យទៅថ្នាក់រៀនសម្រាប់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។ ដោយមានទីតាំងនៅលើខ្នងភ្នំដងរែក ថ្នាក់រៀននេះគាំទ្រដល់ការអប់រំពីអំពើប្រល័យពូជសាសន៍ដល់សិស្ស និងនិស្សិតប្រមាណជា៥០០នាក់ នៅក្នុងប្រទេសកម្ពុជា ព្រមទាំងនិស្សិតបរទេសដែរ។ កន្លងមក និស្សិតបរទេសប្រមាណជាជាង១០នាក់នៃសកលវិទ្យាល័យម៉ូណាសរបស់ប្រទេសអូស្ត្រាលីបានមកបំពេញបេសកកម្មសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រ ការផ្សះផ្សា និងជំងឺផ្លូវចិត្ត ព្រមទាំងព័ត៌មានស្ដីអំពីបរិស្ថាន និងធនធានរ៉ែនៅក្នុងមូលដ្ឋានទៀតផង។ និស្សិតទាំងអស់នោះក៏បានស្ដាប់ពុការនិយាយរៀបរាប់ផ្ទាល់ពីអតីតសមាជិកខ្មែរក្រហម និងបានពិភាក្សា ព្រមទាំងរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រវត្តិសាស្ត្រនៅក្នុងតំបន់។

គោលដៅទី២នៃដំណើរទស្សនកិច្ចគឺជាទីតាំងបូជាសព ប៉ុល ពត អតីតមេដឹកនាំខ្មែរក្រហម និងជាអតីតនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ដែលបានស្លាប់នៅក្នុងខែមេសា ឆ្នាំ១៩៩៨។ ខ្ញុំក៏បានជម្រាបគ្រួសៗជូនលោកឧត្ដមសេនីយ៍អំពីទីតាំងប្រវត្តិសាស្ត្រ និងរឿងរ៉ាវមួយចំនួនរហូតដល់ការស្លាប់របស់ ប៉ុល ពត។ បន្ទាប់ពីការដួលរលំជាផ្លូវការរបស់របបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ប៉ុល ពត និងសមាជិកទាំងឡាយបានបន្តការតស៊ូប្រដាប់អាវុធនៅតាមបណ្ដោយព្រំដែនកម្ពុជាថៃ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០។

នៅដើមទសវត្សន៍ឆ្នាំ១៩៩០ ចលនារបស់ ប៉ុល ពត បានទទួលរងនូវភាពឯកោជាលំដាប់ ហើយការគាំទ្រពីអន្តរជាតិចាប់ផ្តើមកាត់ផ្តាច់ ដែលស្របទៅនឹងសន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ប៉ុល ពត បានបន្តដកថយពីតំបន់តស៊ូនានា មកកាន់តំបន់អន្លង់វែង នៅឆ្នាំ១៩៩៣ ឬ១៩៩៤។ ប៉ុល ពត បានរួមកម្លាំងជាមួយ ឈិត ជឿន ហៅ តាម៉ុក ដែលជាមេបញ្ជាការនៅតំបន់អន្លង់វែង។ នៅទីបំផុត មេដឹកនាំទាំងពីរបានវាយប្រយុទ្ធគ្នា ដែលកាន់តែធ្វើឲ្យចុះខ្សោយដល់ចលនាខ្មែរក្រហម។ ក្រោយមក ប៉ុល ពត ត្រូវបាននាំយកទៅកាត់ទោសនៅក្នុងតុលាការប្រជាជន និងដាក់ឲ្យនៅឃុំខ្លួនក្នុងផ្ទះរហូតដល់គាត់ស្លាប់។



លោក វង់ សារ៉ែន ពេលបំពេញការងារជាមួយកងកម្លាំងរបស់អ៊ុនតាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ក៏បានជួបជាមួយ វង់ សារ៉ែន ដែលជាអតីតទាហានខ្មែរក្រហម និងធ្លាប់ជាសហការីរបស់លោកនៅក្នុងសម័យអ៊ុនតាក់។ ចលនាខ្មែរក្រហមនៅតែជាបញ្ហា បន្ទាប់ពីសម័យអ៊ុនតាក់។ ប្រទេសកម្ពុជាបានចំណាយពេលប្រាំឆ្នាំក្រោយមកទៀតដើម្បីបញ្ចប់នូវរាល់កម្លាំងសេសសល់របស់ចលនាខ្មែរក្រហម។

អន្លង់វែងបានក្លាយជាតំបន់តស៊ូចុងក្រោយនៃចលនានេះដែលបានធ្វើសមាហរណកម្មចូលមកក្នុងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ១៩៩៨ នៅក្រោមគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងឱកាសនោះដែរ វង់ សារ៉ែន ក៏បានសម្តែងនូវសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានជួបជាមួយ លោកឧត្តមនីយ៍ឯក ចន សាន់ដឺសុន នៅអន្លង់វែង។ អ្នកទាំងពីរបាននិយាយគ្នាប្រកបដោយភាពស្និទ្ធស្នាលរីករាយ ដោយរាប់ចាប់តាំងពីរយៈកាលដែលបានជួបគ្នា រហូតដល់គ្រាលំបាកដែលខ្មែរក្រហមធ្វើពហិការមិនអនុវត្តតាមកិច្ចព្រមព្រៀង។ អ្នកទាំងពីរបានអង្គុយជជែក និងចែករំលែកសាច់រឿងនៃទំព័រប្រវត្តិសាស្រ្តកម្ពុជា និងប្រវត្តិសាស្រ្តរបស់អាស៊ីអាគ្នេយ៍។


រូបឈរពាក់មួកនៅកណ្តាល៖ លោក វង់ សារ៉ែន ជាមួយកងកម្លាំងរបស់អ៊ុនតាក់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)
















# បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យកងពលតូចថ្មើរជើងលេខ ៨១

***បណ្ណាល័យប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្នុងកងពលតូចថ្មើរជើងលេខ ៨១ ក្នុងស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ។***

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងនៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពី ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង២៖០០ដល់ម៉ោង៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទង បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តាមរយៈទូរសព្ទលេខ៖ ០១២ ៥៧០ ៨៦៥ ឬ អ៊ីម៉ែល ៖
truthlysokkheang@dccam.org
សូមអរគុណ!











# សហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត

## ទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

សួគ វិចិត្រ




១ សាស្ត្រាចារ្យ សុងហូ កាង គឺជាសហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត នៃប្រទេសកូរ៉េខាងត្បូង ២ បណ្ឌិត លី សុខឃាង ៣ សហការីរបស់សាស្ត្រាចារ្យ សុងហូ កាង ធ្វើដំណើរមកទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដោយមានការទទួលស្វាគមន៍ពី បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាព អន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍ សាស្ត្រាចារ្យ សុងហូ កាង គឺជាសហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត នៃប្រទេសកូរ៉េខាងត្បូង បានធ្វើដំណើរមកទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ លោកសាស្ត្រាចារ្យមានការចាប់អារម្មណ៍ និងចង់ឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីងាយស្រួលក្នុងការដឹកនាំសិស្ស និងនិស្សិតមកពីប្រទេសកូរ៉េខាងត្បូងមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

រួមដំណើរជាមួយសហការីជនជាតិកូរ៉េខាងត្បូង សាស្ត្រាចារ្យ សុងហូ កាង បានធ្វើដំណើរមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២។ បច្ចុប្បន្ននេះ អន្លង់វែង គឺជាស្រុកមួយដ៏មានសក្តានុពលលើផ្នែកសេដ្ឋកិច្ច និងផ្នែកទេសចរណ៍

ក្នុងខេត្តឧត្តរមានជ័យ។ លើសពីនេះទៅទៀត តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ចំនួន ១៤ អាចផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដល់អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ។ មិនត្រឹមតែប៉ុណ្ណោះ តំបន់ប្រវត្តិសាស្ត្រអន្លង់វែងបានផ្សារភ្ជាប់ទៅនឹងប្រវត្តិសាស្ត្រយោធា ដែលធ្វើឲ្យតំបន់នេះកាន់តែមានការចាប់អារម្មណ៍ខ្លាំងពីសាធារណជន សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាបណ្តាប្រទេសអាស៊ាន និងនៅក្នុងពិភពលោក។ ស្រុកអន្លង់វែង គឺជាទីកន្លែងដែលផ្តល់នូវសន្តិភាព ការផ្សះផ្សា និងការរួមរស់ជាមួយរាជរដ្ឋាភិបាល បន្ទាប់ពីបញ្ចប់សង្គ្រាមរុំារ៉ៃនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។

ក្នុងដំណើរទស្សនកិច្ចនេះ លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានអត្ថាធិប្បាយអំពីគម្រោង និងផែនការនានាទាក់ទងនឹងការបង្រៀនប្រវត្តិសាស្ត្រ ការថែរក្សា និងអភិរក្សតំបន់ទេសចរណ៍ប្រវត្តិសាស្ត្របួងគោលដើម្បីអភិវឌ្ឍន៍ស្រុកអន្លង់វែង និងបានជូនលោកសាស្ត្រាចារ្យទៅសិក្សា និងពិនិត្យមើលទីតាំងប្រវត្តិសាស្ត្រសំខាន់ៗដូចជា សារមន្ទីរផ្ទះតាម៉ុក កន្លែងបូជាសពប៉ុល ពត និងផ្ទះប្រជុំរបស់តាម៉ុកលើកំពូលភ្នំដងរែក (ដែលបច្ចុប្បន្ននេះគឺជា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង)។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចនេះ លោកសុង ហូ កាង និងសហការី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចំពោះការទទួលស្វាគមន៍ និងការរាក់ទាក់យ៉ាងកក់ក្តៅបំផុត។









សាស្ត្រាចារ្យ សុង ហូ កាង គឺជាសហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត នៃប្រទេសកូរ៉េខាងត្បូង និងសហការីធ្វើដំណើរមកទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដោយមានការទទួលស្វាគមន៍ពីបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជា ហង់ ៖ កូន និង យាយរបស់ខ្ញុំ ស្លាប់ដោយអត់អាហារ



ជា ហង់ អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជា ហង់ ភេទស្រី អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកជីក្រែង ខេត្តសៀមរាប។ បច្ចុប្បន្ន ហង់ រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ហង់ បានចែករំលែកពីបទពិសោធន៍របស់ខ្លួនកាលពីជំនាន់ខ្មែរក្រហមថា «នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានរស់នៅ និងធ្វើការងារក្នុងសហករណ៍ដែលគ្រប់គ្រងដោយតា ព្រិល។ នៅពេលនោះ កម្មាភិបាលដឹកនាំបន្ទាប់ពី តាព្រិល ធ្លាប់បានប្រមាថដល់ខ្ញុំនិងសមាជិកទាំងអស់នៅក្នុងសហករណ៍ថា គាត់ចង់ឲ្យមិត្តទាំងអស់គ្នាស្លាប់គឺស្លាប់ ចង់ឲ្យរស់គឺរស់។ ខ្មែរក្រហមបានបង្ខំឲ្យខ្ញុំលើកទំនប់ដើម្បីទប់ទឹកស្ទឹង ដោយត្រូវដឹកយកដីអស់មួយជំហៀងភ្នំប៊ិត ក្នុងខេត្តបាត់ដំបង។

យើងបានជញ្ជូនដី និងថ្ម ដោយប្រើរទេះដែលកែច្នៃ ដាក់លើគន្លងផ្លូវសម្រាប់អូស ដូចទៅនឹងផ្លូវរថភ្លើង ដើម្បីជញ្ជូនដីមកក្រោម ដោយក្នុងមួយរទេះ មានមនុស្ស៨នាក់ នៅចាំអូសទាញ។ នៅពេលនោះអ្នកតាដែលថែរក្សានៅតំបន់មកពន្យល់សប្តិប្រធានសហករណ៍ថា ប្រសិនបើចង់ឲ្យទំនប់នោះជាប់ និងរឹងមាំ ត្រូវសែនក្បាលជ្រូកមួយគូ ប៉ុន្តែដោយសារខ្មែរក្រហមបោះបង់ជំនឿ និងការប្រណិប័តន៍គ្រប់យ៉ាង ដង្វាយ ទាំងនោះមិនត្រូវបានរៀបចំនោះទេ រហូតដល់ទំនប់នោះបាក់រលំអស់ទៅ។

នៅការដ្ឋានលើកទំនប់ យើងមិនទទួលបានអាហារហូបចុកគ្រប់គ្រាន់ទេ ដោយក្នុងម្នាក់ទទួលបានបបរមួយវែក ឬយ៉ាងច្រើនពីរវែកប៉ុណ្ណោះ។ ខ្មែរក្រហមតែងដើរឆែកឆេរប្រជាជនក្រែងលោលាក់ចានឆ្នាំងឬស្លាបព្រានៅតាមខ្លួន។ នៅពេលខ្លះដល់ម៉ោងហូបបាយ យើងមិនមានស្លាបព្រាឡើយ ដូច្នេះយើងត្រូវហូបបបរនឹងដៃក៏មាន។

ក្រោយមកកូនប្រុសរបស់ខ្ញុំ ដែលមានអាយុប្រហែល៥ឆ្នាំ រួមទាំងយាយម្នាក់ទៀតបានស្លាប់ដោយសារជំងឺ និងការអត់ឃ្លាន។ នៅពេលនោះ ខ្ញុំបានពឹងប្រធានសហករណ៍ឲ្យជួយចាត់កម្លាំងដើម្បីកប់កូននិងយាយរបស់ខ្ញុំ ប៉ុន្តែប្រធានសហករណ៍បានបដិសេធ ដោយនិយាយថា យើងមិនមានកម្លាំងកប់កូន និងជីដូនមិត្តឯងទេ សូម្បីកម្លាំងធ្វើការរកមិនចង់បានផង។ ខ្ញុំបានបីសពកូន និងជីដូនទៅកប់ក្បែរគ្នា។ ជីវិតខ្ញុំនៅពេលនោះ ប្រៀបដូចទៅនឹងមនុស្សដែលគ្មានវិញ្ញាណ ដោយសារបាត់បង់អ្វីៗគ្រប់យ៉ាង។

**សួត វិចិត្រ**

*រូបក្របមុខ៖*

*តាម៉ុក រួមជាមួយ នួន ជា និង ខៀវ សំផន កំពុងថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅក្នុងផ្ទះរបស់តាម៉ុក នៅក្នុងស្រុកអន្លង់វែង។*

*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ៖*

*ស្លាកសញ្ញាតំបន់ប្រវត្តិសាស្ត្រយោធា*

## អត្ថន័យរូបទណ្ឌដិមា និមិត្តសញ្ញារបស់តំបន់ប្រវត្តិសាស្ត្រយោធា

**និមិត្តសញ្ញាដោយ ឆាំង យុ – រចនាបទដោយ ឆ័យ ស័ក្ត**

*ទណ្ឌដិមាគឺ ជាសត្វមួយប្រភេទក្នុងចំណោម១៥ ដែលរស់នៅក្នុងព្រៃហេមពាន្ត ដូចមាននៅក្នុងនិទានបែបទេវកថានៃព្រះពុទ្ធសាសនារបស់ខ្មែរយើង។ រូបទណ្ឌដិមា ត្រូវបានចងក្រងនិងរំលេចរូបរាងផ្សេងៗគ្នានៅតាមបណ្ដាប្រទេសកាន់ព្រះពុទ្ធសាសនាដូចយើងមានដូចជា ថៃ ភូមា ស្រីលង្កា និងឥណ្ឌាជាដើម។ ការហៅឈ្មោះទៀតសោតក៏ប្រែប្រួលទៅតាមភាសារបស់ប្រទេសទាំងនោះដែរ រូបទណ្ឌដិមាត្រូវបានរំលេចជាគំនូរ ឬឆ្លាក់ជាស៊ីម៉ង់ត៍នៅតាមវត្តមួយចំនួននៅក្នុងខេត្តបាត់ដំបង ។ វត្តនេះធ្លាប់ជាបន្ទាយទាហានចាស់របស់សៀមកាលពីជំនាន់សៀមដណ្ដើមកាន់កាប់កម្ពុជាយើង។*

*ដើមឡើយ រូបទណ្ឌដិមា មានក្បាលនិងខ្លួនជាមនុស្ស ជើងជានាគ និងស្លាបជាហង្ស។ តែដោយសារការប្រែប្រួល រូបទណ្ឌដិមាមានក្បាលគ្រុឌ ស្លាបហង្ស ខ្លួនមនុស្ស និងជើងនាគ។ ក្នុងចំណោមសត្វទាំង១៥ជំពូក នៅក្នុងព្រៃហេមពាន្តដូចរៀបរាប់ខាងលើ ទណ្ឌដិមាមានភាពឆ្លាតវៃជាងគេបង្អស់ ដោយសារតែមានរូបរាងដូចមនុស្ស (ខ្លួន និងក្បាល)។ ទណ្ឌដិមាតែងតែកាន់លំពែងជាប់ជានិច្ច ដើម្បីការពារអ្នកផងទាំងពួងប្រកបដោយ ទឹកចិត្តស្មោះត្រង់ និងជួយយកអាសាអ្នកដទៃជានិច្ច។*

*ដោយឡែកទណ្ឌដិមាក្នុងរូបនេះ ដៃស្ដាំកាន់ព្រះខ័ន ព្រោះព្រះខ័នតំណាងឲ្យវណ្ណៈខ្ពង់ខ្ពស់ ឬថ្នាក់ដឹកនាំកំពូល រីឯលំពែងសម្រាប់ជនសាមញ្ញ (ថៃប្រើលំពែង ហើយឥណ្ឌាប្រើធ្នូ)។ ដៃឆ្វេងកាន់ផ្កាផ្គរលាន់ គឺតំណាងឲ្យតំបន់អន្លង់វែង។*

*ដូច្នេះហើយ ទណ្ឌដិមាកាន់ព្រះខ័នបង្ហាញពីអំណាច និងថាមពល ដែលឈ្នះ ឈ្នះ ជានិច្ចលើអស់ពពួកសត្វទាំងឡាយ។*


## មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Special Issue 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.